01068679 E1/262.1

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Feb-2015, 08:00
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី២៤៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាធូវ ម៉ាកាធី *(Mr. Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

កញ្ញា សុង ឆរ័ត្ន

លោក សាលីម ណាកចាវ៉ានី
*(Mr. Salim Nakhjavani)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡេ្បា ជុនធី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក សេង លាង | ខ្មែរ |
| លោក សាលីម ណាកចាវ៉ានី | អង់គ្លេស |
| លោក សួន វិសាល | ខ្មែរ |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក រី ពៅ (2-TCCP-303) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក រី ពៅ** (2-TCCP-303)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ២
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ....................ទំព័រ ៤
សួរដោយលោក ឡៅ ជុនធី ផ្តើមពី....................ទំព័រ ២៣
សួរដោយលោក សេង លាង ផ្តើមពី ....................ទំព័រ ២៨
សួរដោយលោក សាលីម ណាកចាវ៉ានី ផ្តើមពី....................ទំព័រ ៣៧
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ៤៣
សួរដោយលោក សួន វិសាល ផ្តើមពី ....................ទំព័រ ៤៦
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ៥៥

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហ័សនាម TCCP-303។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះមានរហស្សនាម 2-TCCP-303 ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំៗការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះមិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះអង្គជំនុំជម្រះសម្រេចលើពាក្យសុំរបស់ជនជាប់ចោទ នួន ជា អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថាមានដោយមានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការឲ្យមានប្រសិទ្ធភាពនាពេលខាងមុខ ខ្លួនសុំលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ហើយមេធាវីការពារក្តីរបស់គាត់បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការ

ដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការ ឬរូបខ្លួនឡើយ។ ហើយបានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ បានកត់សម្គាល់ឃើញថាស្ថានភាពសុខភាពរបស់ជនជាប់ចោទ មានការអាការៈឈឺចង្កេះខ្លាំង ហើយឈឺខ្នងពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថាសូមអង្គជំនុំជម្រះអនុញ្ញាតឱ្យ នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឱ្យលោកជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ហើយបង្គាប់ឱ្យបុគ្គលិកខាងផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តបង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី TCCP-303 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់បន្ទប់សវនាការ)*

[០៩:១១:០៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអ្វី?

**លោក រី ពៅ៖**

**ឆ៖** បាទ សូមគោរពលោកប្រធាន។ ខ្ញុំឈ្មោះ រី ពៅ។

**ស៖** អរគុណលោក រី ពៅ។ តើលោកចាំទេថា លោកកើតនៅឆ្នាំណា?

**ឆ៖** បាទ ខ្ញុំបាទកើតនៅឆ្នាំ១៩៥៧។

**ស៖** បាទអរគុណ។ ចុះលោកនៅចាំទីកន្លែងកំណើតរបស់លោកតើលោកកើតនៅទីកន្លែងណា?

**ឆ៖** បាទ កើតនៅភូមិព្រាល ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ។

**ស៖** ហើយចុះទីកន្លែងសព្វ -- លំនៅសព្វថ្ងៃ តើលោករស់នៅទីកន្លែងណា?

**ឆ៖** បច្ចុប្បន្ននៅភូមិព្រាល ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ។

**ស៖** ចុះស្រុកកំណើត កន្លែងដែលលោកកើតៗនៅឯណា? កើតនៅកន្លែងជាមួយគ្នាហ្នឹង ឬក៏កើតនៅកន្លែង នៅទីណាផ្សេង?

**ឆ៖** បាទ កើតនៅភូមិព្រាល ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ។

**ស៖** លោក រី ពៅ តើលោកប្រកបមុខរបរធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** បាទ សព្វថ្ងៃ ខ្ញុំកសិករ ធ្វើស្រែចម្ការ។

**ស៖** ចាប់ពីក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ តើលោករស់នៅទីណា? ហើយលោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** បាទ មុនឆ្នាំ១៩៧៥ ខ្ញុំរស់នៅភូមិព្រាល ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ។

**ស៖** យើងសួរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥ រហូតដល់មុន ០៧ មករា ឆ្នាំ១៩៧៩ តើលោកធ្វើអ្វី ហើយលោកនៅទីណា?

**ឆ៖** បាទ មុនថ្ងៃ០៧ -- មុនថ្ងៃ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំបានទៅរស់នៅប្រទេសវៀតណាម។ លុះដល់ខែ០២ ឆ្នាំ១៩៧៦ ត្រូវបានដូរវៀតណាម ជាថ្នូរជាវៀតណាមមករស់នៅកម្ពុជាវិញ។ នៅក្នុងភូមិត្នោតជុំ ឃុំខ្ពបត្របែក ស្រុកត្រាំកក់ បាទ។

[០៩:១៤:២៣]

**ស៖** បាទ អរគុណ។ ហើយលោក រី ពៅ តើលោកឪពុកបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** បាទ ឪពុកខ្ញុំឈ្មោះ រី កៅ។

**ស៖** អរគុណ។ ចុះម្តាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** បាទ ម្តាយឈ្មោះ ង៉ែត ស៊ីប។

**ស៖** ហើយប្រពន្ធរបស់លោក គាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ បច្ចុប្បន្នប្រពន្ធខ្ញុំឈ្មោះ ឈុំ វ៉ាន់ មានកូនបីនាក់។

**ប្រធានអង្គជំនុំ៖**

អរគុណលោក រី ពៅ។ ហើយលោក រី ពៅ ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណីនាចុង

ក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោក ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី លោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនានិងព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បើសិនបើលោកមានបំណងធ្វើដូច្នេះ។ ហើយក៏លោកមានសិទ្ធិនៅក្នុងការតាំងសំណួរផ្សេងៗផងដែរ បើសិនលោកមានបំណងធ្វើដូច្នេះ។

ហើយដោយអនុវត្តន៍តាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ មុនភាគីដទៃទៀតនៃរឿងក្តីនេះ។ អង្គជំនុំជម្រះ សូមជម្រាបថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរួមទាំងសហព្រះរាជអាជ្ញាមានពេលវេលាកន្លះថ្ងៃ គឺមួយព្រឹកនេះក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[០៩:១៦:១៨]

**កញ្ញាលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ជម្រាបសួរភាគីទាំងអស់ ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី! ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោក បន្តមកខ្ញុំប្រគល់វេទិកាជូនលោកមេធាវី ឡោ ជុនធី។

**ស៖** សំណួរទី១របស់ខ្ញុំ ចង់សួរលោកថានៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ តើលោករស់នៅទីណា?

**លោក រី ពៅ៖**

**ឆ៖** បាទ មុនថ្ងៃ១៧ ខែមេសា ១៩៧៥ ខ្ញុំរស់នៅភូមិព្រាល ឃុំសោម ស្រុកគីរីវង់ ខេត្តតាកែវ។

**ស៖** សូមអរគុណលោក។ តើលោកចាំទេថានៅពេលណាលោកទៅនៅកម្ពុជាក្រោម?

**ឆ៖** បាទ នៅក្នុងអំឡុងឆ្នាំ១៩៧៥ ខ្ញុំទៅរស់នៅកម្ពុជាក្រោម។

**ស៖** សូមអរគុណ។ តើលោកដឹងទេថាកាលទៅរស់នៅទីហ្នឹង គឺថាមិនៗយូរទេបន្ទាប់ពី១៧ មេសា ៧៥ គឺថាប្រហែលជាបន្តិចបន្តួចទេបន្ទាប់ពីហ្នឹង គឺលោកទៅនៅទីនោះអ៊ីចឹងទេ?

**ឆ៖** បាទ ជាការពិតណាស់។ លុះដល់ឆ្នាំ១៩៧៦ បានខ្ញុំត្រូវពួកទាហានខ្មែរក្រហមហ្នឹងយក

វៀតណាមទៅដូរយកខ្មែរពីក្រោមមករស់នៅកម្ពុជាវិញ។ ពេលនោះ ខ្ញុំមករស់នៅក្នុងភូមិត្នោតជុំ ឃុំខ្ពបត្របែក ស្រុកត្រាំកក់ ខេត្តតាកែវបាទ។

[០៩:១៨:៤៦]

**ស៖** សូមអរគុណលោក។ អ៊ីចឹង តើគ្រួសាររបស់លោក ហើយនិងលោកហ្នឹងរស់នៅទីណានៅចន្លោះឆ្នាំ៧៥ ហើយទៅដល់រយៈពេលដែលគេមានការផ្លាស់ប្តូរលោកមកវិញនោះ?

**ឆ៖** បាទ ពេលខ្ញុំផ្លាស់ប្តូរទីលំនៅ ត្រូវពួកខ្មែរក្រហមប្តូរយួនឲ្យមកខ្ញុំនៅកម្ពុជាហ្នឹង ខ្ញុំមករស់នៅក្នុងភូមិត្នោតជុំហ្នឹងបានរយៈពេលប្រហែលជា១០ថ្ងៃ គេចែកជាកម្លាំង។ អ៊ីចឹង ខ្ញុំទៅរស់នៅជាកងចល័តនៅក្បាលពោធិ៍។ ក្រោយមក ខ្ញុំបានធ្វើការ ប៉ុល ពត បានបង្ខំឲ្យខ្ញុំធ្វើការទាំងថ្ងៃទាំងឈប់ជីកប្រឡាយ លើកទំនប់ ធាក់រហាត់ គ្មានពេលស្រាក់ស្រាន្តដោយបង្អត់អាហារ គ្មានអាហារហូបគ្រប់គ្រាន់និងគ្មានសម្លៀកបំពាក់គ្រប់គ្រាន់បាទ។

**ស៖** សូមអរគុណ លោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំនឹងព្យាយាមសួរសំណួរជាក់លាក់ទៅកាន់លោកពាក់ព័ន្ធទៅនឹងកម្មវិធីផ្លាស់ប្តូរលោកនេះ។ ខ្ញុំចង់ដឹងថាហេតុអ្វីបានជាគ្រួសាររបស់លោកបានសម្រេចចិត្តចាកចេញក្នុងក្របខ័ណ្ឌនៃកម្មវិធីផ្លាស់ប្តូរមនុស្សនេះ?

**ឆ៖** បាទនៅសម័យនោះ ខ្ញុំបានរត់ទៅនៅប្រទេសវៀតណាម ប៉ុន្តែម្តាយឪពុកខ្ញុំដោយមានមនោសញ្ចេតនាស្រុកទេស គាត់ក៏ឮដំណឹងថាបានវិលមកខ្មែរវិញ ក៏គាត់បាននាំកូននាំចៅរួមជាមួយប្រជាជនជាច្រើនគ្រួសារបានមករស់នៅទឹកដីកម្ពុជាវិញ ដោយអត់ដឹងមូលហេតុនៃការកាប់សម្លាប់របស់ប៉ុល ពត បាទ។

[០៩:២១:០៦]

**ស៖** សូមអរគុណ។ ចុះមូលហេតុអីដែរដែលលោករត់គេចទៅនៅវៀតណាមហ្នឹង?

**ឆ៖** បាទពេល មុនពេលចុះរត់នៅវៀតណាមហ្នឹង គឺស្រុកខ្មែរយើងបានកើតសង្គ្រាម។ ប៉ុល ពត បានវាយគ្នាជាមួយទាហាន លន់ នល់។ ពេលនោះ ពេលកម្លាំងប៉ុលពតវាយដល់ណា គឺដុតផ្ទះសម្បែងរបស់ប្រជាពលរដ្ឋ។ អត់មានទុកផ្ទះឲ្យយើងរស់នៅបាន ទើបប្រជាជននៅតាមព្រំដែនរត់ចុះទៅវៀតណាម ព្រមៗគ្នាទាំងអស់។

**ស៖** ដូច្នេះប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺលោករត់ទៅវៀតណាម ហើយលោកស្នាក់នៅវៀត-ណាមពីរបីខែ ហើយរហូតដល់ខែកុម្ភៈ ឆ្នាំ៧៦ ដែលលោកនិងគ្រួសារនុង បានសម្រេចចិត្តថាត្រឡប់

ចូលមកកម្ពុជាវិញតាមរយៈកម្មវិធីដោះដូរ។ អ៊ីចឹង តើខ្ញុំយល់ពីលំដាប់លំដោយកាលបរិច្ឆេទហ្នឹងត្រឹមត្រូវទេ?

**ឆ៖** បាទជាការពិតណាស់អារឿង -- ពេលនោះខ្ញុំក៏អត់ដឹងពីនយោបាយរបស់ខ្មែរក្រហមដែរ ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ ដែលបានគេចភៀសខ្លួនទៅនៅប្រទេសគេ។ ក្រោយពីការដោះដូរហ្នឹង ក៏ខ្ញុំអត់មានស៊ីជម្រៅនឹងការប្តូរផ្លាស់ដែរ ដោយសារយើងនឹកឃើញថា ភូមិស្រុកកំណើតតែងមានមនោសញ្ចេតនានឹករឭក។ អ៊ីចឹងតែងវិលមកវិញ។

**ស៖** សូមអរគុណ។ តើលោកស្តាប់ឮនិយាយអំពីកម្មវិធីដោះដូរហ្នឹងយ៉ាងម៉េចដែរ? អ្នកណាដែលអ្នកនិយាយប្រាប់លោកអំពីថាមានការដោះដូរគ្នាអ៊ីចឹង?

[០៩:២៣:១១]

**ឆ៖** បាទ ព្រោះអីកាលនុងយួននិងខ្មែរហ្នឹង នៅត្រូវគ្នា។ ប៉ុល ពត ហើយ វៀតណាម ហ្នឹង តាមព្រំដែននៅត្រូវគ្នា។ អ៊ីចឹងការទំនាក់ទំនង អាហ្នឹងរឿងនយោបាយខ្ញុំអត់អាចដឹងបាន អត់ស៊ី ជម្រៅនឹងការដូរហ្នឹង ប៉ុន្តែក្រោយមកមានអ្នកភ្នាក់ងាររបស់ខ្មែរក្រហមហ្នឹង គឺទាហានខ្មែរក្រហមហ្នឹង បានទៅទំនាក់ទំនងជាមួយវៀតណាម ដឹកវៀតណាមពីស្រុកខ្មែរ យកទៅដូរខ្មែរយកពីក្រោមមកវិញ។

**ស៖** សូមអរគុណ។ តើលោកអាចពន្យល់ជូនតុលាការ ពាក់ព័ន្ធទៅនឹងព័តមានដែលៗថាមានការដោះដូរហ្នឹង លោកថាខ្មែរក្រហមទៅប្រាប់លោកអំពីកម្មវិធីដោះដូរ។ អ៊ីចឹងគេនិយាយអ្វីខ្លះដើម្បីជំរុញ ឬក៏លើកទឹកចិត្តលោកហ្នឹងឲ្យចូលមកកម្ពុជាវិញនុង?

**ឆ៖** បាទតាំងពីសម័យនោះ ពួកខ្មែរក្រហមហ្នឹង គេបានទំនាក់ទំនងបញ្ជោ។ ធម្មតាមន្ត្រីរាជការខ្ញុំមិនដឹងតិចនិករបស់គេទេ ប៉ុន្តែក្រោយមកបានមន្ត្រីរបស់វៀតណាមហ្នឹង រដ្ឋការរបស់វៀតណាមហ្នឹង ប្រាប់ថាបងប្អូនខ្មែរត្រូវវិលត្រឡប់ទៅភូមិកំណើតវិញ ដោយសារមានការដោះដូរ។ អ៊ីចឹង បងប្អូនដែលបានគេចភៀសខ្លួនទៅពីខ្មែរទៅ នាំគ្នាស្រុះស្រួលមូលមតិឃោបល់គ្នា បានព្រមព្រៀងវិលត្រឡប់មកភូមិកំណើតវិញ។

[០៩:២៥:០០]

**ស៖** តើលោកដឹងទេថា នៅក្នុងភូមិណាដែរដែលលោកត្រឡប់មកវិញហ្នឹង ហើយលក្ខខណ្ឌរស់នៅក្នុងភូមិហ្នឹងយ៉ាងម៉េចដែរ? អ៊ីចឹង មុនពេលដែលលោកចេញទៅវៀតណាមហើយនិងពេលដែលលោកត្រឡប់មកពីវៀតណាមវិញហ្នឹង នៅភូមិតែមួយហ្នឹងទេ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ មុនពេលខ្ញុំទៅនៅវៀតណាម គឺខ្ញុំទៅនៅភូមិរំពាយស្វាយ ឃុំឡេទ្រី ស្រុកស្វាយទង ក្រោយពីបានឡើងមកគឺមករស់នៅភូមិត្នោតជុំ ឃុំគោកត្របែក ស្រុកត្រាំកក់ ខេត្តតាកែវ បាទ។

**ស៖** ខ្ញុំនឹងនិយាយអំពីបញ្ហានេះនៅពេលក្រោយ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ឲ្យលោកពន្យល់ថា តើការវិលត្រឡប់មកកម្ពុជាវិញហ្នឹងប្រព្រឹត្តទៅយ៉ាងម៉េច? លោកអាចប្រាប់បានទេថា លោកត្រឡប់មកកម្ពុជាដោយជិះឡានកាំម៉ុង ជិះឡានតូច ហើយមានទាហានអមទេ? ហើយមានមកហ្នឹងតែម្នាក់ ឬក៏មានក្រុមគ្រួសារផ្សេងៗទៀតមកជាមួយលោកដែរ? សុំលោកពន្យល់អំពីការដែលលោកត្រឡប់មកពីវៀតណាមចូលមកកម្ពុជា?

**ឆ៖** បាទ នៅពេលគេដូរខ្ញុំឲ្យមកពីវៀតណាមហ្នឹង គឺមានបងប្អូនខ្មែរយើងជាច្រើនៗគ្រួសារ។ នៅពេលមកដល់ភ្នំដិន ពួកទាហានខ្មែរក្រហមគេបាននិយាយប្រាប់ថា៖ "បងប្អូនសម្រាកទីនេះមួយយប់ រង់ចាំអង្គការថ្នាក់លើចុះមកយក"។ លុះស្អែកឡើង ឃើញឡានមកដឹកពួកខ្ញុំ ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់គឺឡានកាលពីសម័យនោះមានម៉ាក សេ.អឹម.សេ បាទ ចំនួនជាង១០គ្រឿងបាទ។ អ៊ីចឹង វាដឹក ការដឹកជញ្ជូននេះគឺមិនមែនយកទៅប្រមូលផ្តុំមួយកន្លែងទេ។ ចែកវាបែងចែក ប្រាំឡានត្រង់នេះ ប្រាំឡានត្រង់នោះ។ អ៊ីចឹង វាមិនអាចនៅមូលគ្នា។

**ស៖** តើលោកចាំអំពីចំនួនមនុស្ស និងចំនួនគ្រួសារដែលមកពីវៀតណាមមកកម្ពុជាជាមួយនឹងលោកទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប។

**លោក រី ពៅ៖**

**ឆ៖** បាទកាលពីសម័យនោះ ខ្ញុំនៅចងចាំបានខ្លះ ដោយសារពេលនោះខ្ញុំដឹងចំនួនប្រជាពលរដ្ឋដែលចុះភៀសខ្លួនទៅនៅប្រទេសវៀតណាម គឺនៅក្នុងភូមិហ្នឹងមានប្រជាពលរដ្ឋចំនួន ១០០០គ្រួសារ គេដាក់ប្រមូលផ្តុំមួយកន្លែងងាយស្រួល។ កាលហ្នឹងមានផ្នែករដ្ឋាអាមេរិកាំង គេបើកអំណោយឲ្យជនភៀសខ្លួនទៅនៅវៀតណាមហ្នឹង។ អ៊ីចឹង ខ្ញុំដឹងថានៅក្នុងប្លុកហ្នឹងវាមានប្រហែលជា ១០០០គ្រួសារ ទៅ ១៥០០គ្រួសារបាទ។ អ៊ីចឹង ឡើងមកវាចន្លោះពេលហ្នឹងវាឡើងមក គេបែងចែកជាបីដង។ អ៊ីចឹងពេលឡើងមកសាមុនហ្នឹងគឺច្រើន សាក្រោយៗទៀតខ្ញុំឡើងមកហួសហើយ មិនដឹងគេទៅដឹកប៉ុន្មានទេ ប៉ុន្តែប៉ុន្មានដងទៀតទេ ប៉ុន្តែពេលនោះ គេប្រាប់ថាយើងទៅមួយវគ្គអ៊ីចឹង ហើយខ្ញុំមកមុនគេ មកវគ្គទី១។

[០៩:២៩:២០]

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំត្រឡប់មកពេលមុនហ្នឹងបន្តិច ខ្ញុំដឹងថា ពេលដែលលោកត្រឡប់មកហ្នឹង ខ្ញុំចង់ដឹងថាតើលោកមានអាចយកអីវ៉ាន់មកតាមខ្លួនបានទេ? ឧទាហ-រណ៍ដូចជា លោកអាចយកលុយ ទ្រព្យសម្បត្តិ សម្លៀកបំពាក់អី យកមកតាមខ្លួនបានទេ ពេលត្រឡប់ពីវៀតណាមមកកម្ពុជាវិញហ្នឹង?

**ឆ៖** បាទ នៅពេលត្រឡប់មកនោះ មកកម្ពុជាវិញ បងប្អូនប្រជាពលរដ្ឋទាំងអស់នាំគ្នាលក់គោលក់ក្របី ខ្លះលក់សេះអីចឹងទៅ ដើម្បីយកលុយវិលត្រឡប់មកភូមិកំណើតវិញ។ ក្រោយមកដល់កន្លែងគេឲ្យយើងស្នាក់នៅនេះ ពេលមកដល់ពួកខ្មែរក្រហមគេប្រមូលយកទ្រព្យសម្បត្តិទាំងអស់ តាំងពីមាសប្រាក់។ គេថានៅទីនេះមានអង្គការចិញ្ចឹមហើយ។ អីចឹងទ្រព្យសម្បត្តិ មាសប្រាក់ ដែលលក់គោលក់ក្របីបានហ្នឹង គឺពួកខ្មែរក្រហមប្រមូលយកទាំងអស់។ បាទ អត់មាននៅសេសសល់ទេ បាទ។

**ស៖** សូមអរគុណលោក។ តើលោកអាចរៀបរាប់អំពីការឆ្លើយកាត់ព្រំដែនបានទេ ពីព្រោះលោកប្រាប់ថាមានឡានមកច្រើន ហើយមានប្រហែលជា១៥០០គ្រួសារ។ អីចឹងពេលឆ្លងកាត់ព្រំដែនហ្នឹងយ៉ាងម៉េចដែរ ហើយមានគ្រួសារ តើពេលមកដល់ព្រំដែនហ្នឹងមានពីខាង -- គ្រួសារពីខាងកម្ពុជាយើងទៅព្រំដែន ទៅឆ្លងចូលវៀតណាមវិញទេ?

**ឆ៖** បាទ ពេលនោះ ក្រោយពីការដោះដូរហើយ គ្រាន់តែឆ្លងព្រំដែនហើយ គេបិទច្រកចេញ។ ច្រកចូល គេអត់ឲ្យឆ្លងកាត់ទេ គេមានតែឲ្យចូលមកក្នុង យើងខ្មែរមកខ្មែរ យួនទៅដោយយួន អីចឹងទៅ។ អីចឹងគេបិទអត់មានឲ្យដើររហេតរហូត។

[០៩:៣១:៤២]

**ស៖** នៅសម័យនោះ តើលោកមានឃើញគ្រួសារណាដើរបញ្ច្រាសទៅវិញទេ ឬក៏មានតែក្រុមគ្រួសារលោក ហើយនិងលោកទេ ឬក៏ក្រុមគ្រួសារផ្សេងទៀតមកពីវៀតណាម? អីចឹងលោកអត់មានឃើញពីខាងវៀតណាម ពីខាងខ្មែរយើងចូលទៅខាងវៀតណាមវិញទេ អីចឹងមែនទេ?

**ឆ៖** បាទជាការពិតណាស់ អត់មាន ព្រោះអីចូលមកដល់ព្រំដែនហ្នឹង ទាហានរបស់ខ្មែរក្រហមហ្នឹង គេហាមដាច់ខាតមិនឲ្យយើងដើរឆ្វេចឆ្វាច នៅទីនោះ គេមានការយាមរបស់គេតឹងរ៉ឹង ដោយគេបញ្ញត្តិថាមិនឲ្យយើងដើរចុះឡើងរហេតរហូត សាចុះសាឡើង អត់ គឺឲ្យនៅនឹងមួយកន្លែងបាទ។

**ស៖** អីចឹងតើនៅសម័យនោះ លោកនិងគ្រួសាររបស់លោក មានការភ្ញាក់ផ្អើលទេនៅពេលដែល

មកដល់កម្ពុជាវិញ? នៅពេលដែលមកដល់ ដូចលោកបានរៀបរាប់អ៊ីចឹងថា គេរឹបអូសលុយ យកអីវ៉ាន់អ៊ីចឹងៗពេលដែលលោកមកដល់ភ្លាមនោះ លោកមានអារម្មណ៍យ៉ាងម៉េចដែរ?

**ធ៖** បាទ ពេលមកដល់មុនដំបូងនឹកឃើញថា យើងបានវិលត្រឡប់មកភូមិកំណើតវិញហើយ តែក្រោយមក ពេលវាដឹកមកដាក់នៅភូមិឆ្នោតជុំហ្នឹង ក្រោយពីវាប្រមូលទ្រព្យសម្បត្តិអស់ម្នាក់ៗមានការស្ដាយក្រោយ មានការនឹកអាលោះអាល័យទៅដល់ការរស់នៅដែលបានសុខដុមរមនា ដោយហេតុថា ខ្មែរអត់មានដឹងនយោបាយខ្មែរក្រហមថា គេកាប់សម្លាប់ ឬគេវាយដំ ឬគេប្រើយើងឲ្យធ្វើការខុសម៉ោង ខុសពេលវេលាទេ។ អត់ដឹងថាគេមានសហករណ៍បាយរួមបាយអីទេបាទពេលនោះ ទាល់តែឃើញអ៊ីចឹងបានដឹង។

[០៩:៣៣:៥២]

**ស៖** សូមអរគុណលោក។ ខ្ញុំចង់ដឹងថាតើលោក ឪពុកម្ដាយលោក ឬក៏សមាជិកក្រុមគ្រួសារលោកមកកម្ពុជាវិញហ្នឹង គឺមានអត្តសញ្ញាណប័ណ្ណ មានលិខិតបញ្ជាក់អត្តសញ្ញាប័ណ្ណទេ ហើយនៅពេលប្រសិនបើមាន នៅពេលមកដល់នុ៎ង គេមានរឹបអូសយកលិខិតទាំងអស់នុ៎ងទេ?

**ធ៖** បាទ ខ្ញុំសូមជម្រាបជូនថា កាលពីយើងសម័យនោះ អត់មានអត្តសញ្ញាណ្ណប័ណ្ណទេ។ យើងមានចាស់ ដែលវ័យចំណាស់ចាប់ពីអាយុ២០ឡើងទៅគាត់មានកាត។ កាតខ្មៅមួយកាលនោះសម័យដើម មានតែកាត។ អ៊ីចឹងកាត ឬអ្វីដែលពាក់ព័ន្ធ គឺគេប្រមូលដុតចោលអស់។ គេអត់បានទុកបន្សល់ទុកឲ្យយើងនៅរក្សា ឬមួយរក្សាទុកដើម្បីអ្វីមួយទេបាទ។

**ស៖** ដើម្បីយល់ឲ្យបានច្បាស់ អ៊ីចឹងគេដុត លោកថាគេដុតឯកសារទាំងអស់ហ្នឹងគេដុតនៅពេលណាដែរ?

**ធ៖** បាទ ពេលគេប្រមូលពីយើងរួច គេដុតឲ្យយើងមើល អាកាត លិខិតបទដ្ឋាននានាដែលពាក់ព័ន្ធហ្នឹង គេដុតឲ្យយើងមើល។ រីឯប្រាក់ក៏គេដុតចោលដែរ ដោយឡែកមាស គេរក្សាទុកក៏ប៉ុន្តែមិនដឹងគេយកទៅណា ដោយសារគេប្រាប់ថានៅទីនេះមានអង្គការគ្រប់គ្រងហើយ អ៊ីចឹងខ្ញុំអត់ដឹងថាគេយកទៅណាទៅអីអត់មានដឹងទេ។ ហើយគេបានប្រជុំប្រាប់ថាពេលនេះ នៅទីនេះមានសហករណ៍មានអង្គការប្រមូលផ្ដុំ អ៊ីចឹងមិនបាច់ឲ្យពុកម៉ែបងប្អូនពិបាកអីទៀតទេ អ៊ីចឹងមកដឹងតែពេលឆ្អិនដឹងតែហូបទៅ កុំបាច់ខ្វាយខ្វល់រឿងដាំរឿងស្លអីបាទ។

[០៩:៣៦:១៣]

**សះ** លោកអាចជម្រាបបានទេថាលោកត្រឡប់មកពីវៀតណាមមកកម្ពុជាជាមួយអ្នកណាខ្លះដែលជាសមាជិកក្រុមគ្រួសារលោកហ្នឹង?

**ឆះ** បើឲ្យពណ៌នាខ្ញុំភ្លេចឈ្មោះអស់ហើយ ពេលនោះមនុស្សវាច្រើនពេកបាទ ខ្ញុំចាំ នៅចងចាំតែម្ដាយឪពុកខ្ញុំនិងក្រុមគ្រួសារខ្ញុំហ្នឹងបាទ។

**សះ** អ៊ីចឹងនៅពេលហ្នឹងពេលលោកត្រឡប់មកវិញហ្នឹងមានបងប្អូនបង្កើតលោកមកជាមួយលោកទេ?

**ឆះ** បាទ មកជាមួយបាទ។ ប៉ុន្តែមកដល់បានរយៈពេលប្រហែលជា១០ថ្ងៃហ្នឹង គឺគេបំបែកទៅជាកងប្រមូលផ្ដុំ។ អ៊ីចឹងស្ត្រីទៅដោយស្ត្រី កុមារា កុមារី យុវនារី យុវជន ទៅដោយឡែក បែងចែកដាច់ពីគ្នាស្រឡះបាទ អត់មាននៅក្បែរគ្នា ជិតគ្នាទេបាទ ម្ដាយឪពុកទៅដោយម្ដាយឪពុក ម្ដាយទៅដោយម្ដាយ ឪពុកទៅដោយឪពុកបាទ។

[០៩:៣៧:៤១]

**សះ** សូមអរគុណ។ ដូច្នេះលោកបានឆ្លើយថានៅពេលមកដល់កម្ពុជា លោករស់នៅជាមួយគ្រួសារបាន១០ថ្ងៃ ហើយក្រោយពី១០ថ្ងៃហ្នឹងមកគេបំបែកចេញពីគ្នា ហើយដាក់តាមកងផ្សេងៗគ្នា អ៊ីចឹងខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ ហើយប្រសិនបើត្រឹមត្រូវសូមលោកប្រាប់ឈ្មោះភូមិ ឬក៏ឃុំ ដែលគេបញ្ជូនលោកទៅក្រោយពីលោករស់នៅជាមួយគ្រួសារបាន១០ថ្ងៃហ្នឹង គេបញ្ជូនលោកទៅកាន់ភូមិ ឃុំណាដែរ?

**ឆះ** បាទ មុនពេលគេបញ្ជូនទៅមុនដំបូងគឺភូមិត្នោតជុំ ឃុំខ្ពបត្របែក ស្រុកត្រាំកក់ ខេត្តតាកែវបាទ។

**សះ** អ៊ីចឹងនៅពេលនោះ លោកនៅភូមិហ្នឹងតែម្ដង ឬក៏លោកអាចរស់នៅភូមិផ្សេង ឬឃុំផ្សេងទៀត?

**ឆះ** បាទ ពេលនោះគេឲ្យខ្ញុំទៅជាកងចល័ត ទៅជាយុវជនកងចល័តទៅនៅក្បាលពោធិ៍នៅពីខាងត្បូងខេត្តតាកែវហ្នឹង ទៅនៅធ្វើស្រែប្រាំង ជីកប្រឡាយ រែកដីនៅទីនោះបាទ។ ចំណែកឪពុកម្ដាយខ្ញុំមិនដឹងគេឲ្យទៅនៅកន្លែងណាខ្លះ ខ្ញុំអត់ដឹងទីលំនឹងរបស់គាត់ដែរបាទ។

[០៩:៣៩:២៥]

**សះ** ហើយក្នុងរយៈពេលហ្នឹងគឺនៅខែកុម្ភៈ ៧៦ លោកចូលមកកម្ពុជា។ អ៊ីចឹងតើពីពេលហ្នឹង

រហូតដល់ខែមករា ឆ្នាំ៧៩ហ្នឹង លោកមានបានជួនឪពុកម្ដាយលោកវិញទេ នៅពេលដែលលោកថាធ្វើការនៅក្នុងកងចល័តនោះ?

**ធ៖** បាទ ពេលនោះ កាលពីសម័យនោះគេមានបុណ្យបក្សកុម្មុយនីស្តគេ ហើយអ៊ីចឹងបុណ្យបក្សកុម្មុយនីស្តហ្នឹង ក្នុងរយៈពេលបុណ្យហ្នឹង គឺបីថ្ងៃគេឲ្យយើងមកជួបឪពុកម្ដាយ ប៉ុន្តែមិនស្ដីរក សួរនាំគ្នាទេ មានតែទឹកភ្នែក។ អត់បានសួរនាំ សួរហេតុផលអីទេ បានតែត្រឹមតែក្រឡេកឃើញគ្នា។ ព្រោះសម័យនោះ គេមានបក្សកុម្មុយនីស្តរបស់គេ មិនដឹងបុណ្យស្អីគេ ខ្ញុំក៏អត់ដឹងដែរ គេហៅថាបុណ្យបក្សកុម្មុយនីស្តអ៊ីចឹងបាទ។

**ស៖** ដូច្នេះលោកបានជួបឪពុកម្ដាយវិញ គឺម្ដង -- តែម្ដងទេក្នុងរយៈពេលហ្នឹង អ៊ីចឹងមែនទេ គឺថាលោកបានជួបវិញតែម្ដងគត់?

**ធ៖** បាទ ជាការពិតណាស់បាទ។

**ស៖** ឥឡូវនេះខ្ញុំចង់សួរសំណួរមួយចំនួនអំពីការប្រព្រឹត្តចំពោះលោកនៅត្រាំកក់ ដោយពួកខ្មែរក្រហម។ អម្បាញ់មិញនេះ លោកនិយាយថា លោកត្រលប់មកពីវៀតណាមវិញ អ៊ីចឹងពេលមកដល់ហ្នឹង ខ្មែរក្រហមមានចាត់ទុកលោកថាជាវៀតណាមទេ?

[០៩:៤១:២១]

**ធ៖** បាទ ពេលនោះ មុនដំបូង គេអត់ -- យើងអត់ដឹងអង្គការចាត់ចាត់តាំងរបស់គេហ្នឹង ការងារផ្ទៃក្នុងរបស់គេ ខ្ញុំអត់បានដឹងដែរ។ ក្រោយមក បានអាយើងសម័យនោះ គេចែកជាបីប្រភេទ។ ប្រភេទទី១ ១៧, ប្រភេទទី២ ខ្ញុំមកពីវៀតណាមហ្នឹង គេហៅថា ពួកអាយួនទេ។ ហើយបើអាទី១របស់គេហ្នឹងគឺមូលដ្ឋាន។ មូលដ្ឋានគេហ្នឹង អាក្មេងៗកម្ពស់ដូចថា អាយុប្រហែលជា១០ឆ្នាំអីហ្នឹង ហៅយើងសុទ្ធតែអាមីង ហៅសុទ្ធអាយ៉ងយួន ហៅសុទ្ធអានេះអានោះ។ អ៊ីចឹងសម័យនោះវាជូរចត់ណាស់ បើខ្ញុំនឹកឃើញដល់សម័យនោះបាទ។ វាគ្មានសុជីវធម៌នៅក្នុងខ្លួនទេបាទ។ វាចេះហៅមិត្តៗល្អ ប៉ុន្តែវាមិនមែនជាមិត្ត ទៅជាបាបមិត្តវិញបាទ។ អ៊ីចឹងវាផ្ទុយពីការហៅមិត្ត វាទៅជាបាបមិត្ត។

**ស៖** សូមអរគុណ។ ដូច្នេះប្រសិនបើខ្ញុំមិនច្រឡំទេ គឺថាមានបីប្រភេទ គឺពួក១៧ ពួកយួន ហើយនិងខាងមូលដ្ឋាន។ ហើយលោកហ្នឹងគេហៅលោកថាអាយួន។ អ៊ីចឹងទេ ត្រឹមត្រូវទេ ខ្ញុំយល់អ៊ីចឹង?

**ធ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** សូមអរគុណលោក។ តើលោកអាចពន្យល់អំពីលក្ខខណ្ឌរស់នៅរបស់ពួកអាយួននៅ

សហករណ៍ត្រាំកក់ទេ?

**ឆ៖** បាទ ការពីសម័យនោះ គេបែកចែកជាបីប្រភេទអ៊ីចឹង។ អ៊ីចឹងចំណែកពួកខ្ញុំដប់ -- មកពីយួន និងបងប្អូនចេញពីភ្នំពេញទៅ ប្រជាពលរដ្ឋ ប្រជាជន១៧មេសាហ្នឹង គេចាត់ទុកដូចជាខ្ញុំកញ្ជះដាច់ថ្លៃរបស់គេអ៊ីចឹង។ ជាឧបករណ៍មួយសម្រាប់គេរើគេតប់។ អ៊ីចឹងការហូប ការដេក ដើរ ឈរ អង្គុយ គឺក្រឹតវិន័យគេតឹងតែងណាស់។ អត់មានយើងដើររហេតរហូតបាន ឬមួយហូប បើសិនណាយើងចាប់ត្រីបាន ត្រូវយកទៅដាក់ក្នុងសហករណ៍។ បើយើងលួចលាក់ អាហ្នឹងគេចាប់ជាកម្លាំង មួយកងហារបស់គេអ៊ីចឹង គេឱ្យរកត្រីឱ្យយើងតែបុគ្គលម្នាក់ឯងហូបឱ្យអស់។ អាហ្នឹងកន្លែងខ្ញុំនៅគឺអ៊ីចឹងតែម្ដង។ សកម្មភាពរបស់វាធ្វើទារុណកម្មមកលើយើងខ្លាំងណាស់។

[០៩:៤៩:២៨]

**ស៖** សូមអរគុណ។ អ៊ីចឹងពួកយួន ដែលគេហៅលោកហ្នឹង ហើយនិងពួកអ្នក១៧មេសាហ្នឹង មានលក្ខខណ្ឌរស់នៅ ឬក៏ហូបចុកការងារអីដូចគ្នាទេ?

**ឆ៖** បាទ ប្រជាពលរដ្ឋ១៧ និងអ្នកមកពីយួនហ្នឹង ជីវភាពដូចគ្នា។ គឺបើ -- ព្រោះអីយើងនៅអង្គភាពតែមួយ។ អ៊ីចឹងបើ១០០នាក់ហ្នឹង បបរក្នុង១០០នាក់ហ្នឹង ១០កំប៉ុង គឺហូបដូចគ្នាទាំងអស់។ បើគ្មានបបរ ដំឡូងម្នាក់មួយកង់ហ្នឹង គឺមួយកង់ដូចគ្នា បាទជំនួសបាយបាទ។

**ស៖** សូមអរគុណ។ លោកបានឆ្លើយថាលោកជាសមាជិកកងចល័ត ហើយ១០ថ្ងៃក្រោយពីទៅដល់ត្រាំកក់ ខ្ញុំចង់សួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងកងចល័តហ្នឹង។ តើក្នុងកងចល័តរបស់លោកហ្នឹងមានមនុស្សប៉ុន្មាននាក់? ហើយអ្នកទាំងអស់ហ្នឹងមកពីណាខ្លះ? ហើយអ្នកដែលធ្វើការនៅក្នុងកងចល័តហ្នឹងមានអាយុប៉ុន្មានខ្លះដែរ?

**ឆ៖** បាទ នៅសម័យខ្មែរក្រហមហ្នឹង គេបែងចែកច្រើនៗប្រភេទបាទ។ វាមានកងកុមារ កងផលិត កងអ៊ីមេម៉ាយ កងកសិករ កងពូកសិករ កងពូពោះម៉ាយអ៊ីចឹងទៅ កងយុវជន កងផលិត អ៊ីចឹងវាច្រើនប្រភេទណាស់របស់គេ គេរៀបចំរចនាសម្ព័ន្ធរបស់គេច្រើនណាស់។ ប៉ុន្តែ ក្នុងមួយកងៗហ្នឹង វាគេហៅកង៥០ៗ កង៥០ហ្នឹង គឺមាន៥០នាក់ បើអ៊ីចឹងមនុស្សហ្នឹង១៧មេសា ហើយនិងអ្នកមកពីស្រុកយួនហ្នឹងគឺរស់នៅជាមួយគ្នា។ អ៊ីចឹងថ្នាក់ដឹកនាំរបស់វាមានមេកងពីរទៅបីនាក់ ពួកមូលដ្ឋានហ្នឹងគេអ្នកដឹកនាំយើង។ ហើយអ៊ីចឹងគេបញ្ជាលើយើងទាំងពីការធ្វើការ ទាំងពីដេកដើរឈរអង្គុយ បូករួមទាំងអស់នៅលើគេហ្នឹង។

[០៩:៤៧:០៤]

**ស៖** សូមអរគុណ។ តើខ្មែរក្រហមដឹងទេថាលោក ហើយនិងជនរួមជាតិផ្សេងទៀតជាខ្មែរក្រោម? ពួកគេមានមធ្យោបាយដឹងទេថាពួកលោកមកពីខាងណា១ ហើយថាឲ្យលោកជាពួកអាយួនអ៊ីចឹង?

**ឆ៖** បាទ បើតាមខ្ញុំពិនិត្យសកម្មភាពរបស់វា គឺវាលម្អិតណាស់បាទ។ យើងអ្នកមកពីភ្នំពេញ ១៧ហ្នឹងវាដឹង។ អ្នកមកពីយួនវាដឹង។ អ៊ីចឹង រាល់សកម្មភាពការងារ វា១ធ្វើទារុណកម្មមកលើយើង តែយួន ហើយនិងមកពីភ្នំពេញហ្នឹងបាទ។ ដោយឡែកអ្នកមូលដ្ឋានហ្នឹងគេអត់មានហាត់នឿយលំបាកលំបិនដូចយើងទេបាទ។

**ស៖** សូមអរគុណ។ អ៊ីចឹង តាមអ្វីដែលលោកសង្កេតឃើញនៅសម័យនោះ គឺថាខ្មែរក្រហមដឹងថាលោកជាយួនយ៉ាងម៉េច? ឧទាហរណ៍ដូចពេលលោកមកដល់កម្ពុជាវិញអ៊ីចឹង គេមានធ្វើបញ្ជីចុះឈ្មោះលោកទេ? តើលោកអាចឆ្លើយបញ្ជាក់បានទេ បានជាខ្មែរក្រហមដឹងថាលោកជាយួន?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:៤៨:៣១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម លោក លោកស្រីមេធាវី។ ខ្ញុំចាំបន្តិចមុននឹងខ្ញុំឈរឡើងមកនេះ ព្រោះថាខ្ញុំមិនច្បាស់ថាតើការសួរហ្នឹងប្រុងមានគោលដៅទៅដល់ចំណុចណាដែរ? ក្រៅពីការលើកឡើងពីចំណុចគួរឲ្យចាប់អារម្មណ៍មួយចំនួនតូចគឺថា សក្ខីកម្មនេះគឺហាក់ដូចជាការសួរជាទូទៅ។ ហើយខ្ញុំគិតថាផ្នែកនៃការជំនុំជម្រះបច្ចុប្បន្ននេះគឺនិយាយអំពីត្រាំកក់ ហើយនិងក្រាំងតាចាន់។ ហើយយើងក៏មានផ្នែកចម្លែក -- ផ្នែកដាច់ដោយឡែកមួយទៀតទាក់ទងទៅនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាម។ ហើយយើងទាំងអស់គ្នាក៏បានដឹងផងដែរអំពីប្រវត្តិសាស្ត្រដែលយើងដឹងនៅក្នុងដំណាក់កាលជំនុំជម្រះនិងដំណាក់កាលមុនការជំនុំជម្រះ បើសិនបើយើងមើលសេចក្ដីសម្រេចរបស់បុរេជំនុំជម្រះថ្ងៃ២៧ មេសា ឆ្នាំ២០១០ អ្វី១ទាក់ទងទៅនឹងការសួរ-ឆ្លើយទាក់ទងទៅនឹងការប្រព្រឹត្តចំពោះកម្ពុជាក្រោមនិងអ្នកដទៃទៀតហ្នឹង គឺវាធ្វើនៅក្នុងដំណាក់កាលស៊ើបអង្កេត។ ដូច្នេះអ្វីដែលខ្ញុំដឹង គឺថាខ្ញុំគ្រាន់តែស្នើសុំឲ្យមានការណែនាំ ថាតើឥឡូវនេះយើងកំពុងតែគេចចេញអំពីលទ្ធភាព

ដែលបានសម្រេចនៅក្នុងដីកាដំណោះស្រាយទាក់ទងទៅនឹងការប្រព្រឹត្តចំពោះកម្ពុជាក្រោម ឬក៏យ៉ាងដូចម្ដេចដែរ? ព្រោះថាវាមិនមែនជាផ្នែកនៃដីកាដំណោះស្រាយ មិនមែនជាផ្នែកនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់ប្រឆាំង នួន ជា និង ខៀវ សំផន នោះទេ។ ខ្ញុំមិនប្រាកដថា យើងកំពុងតែធ្វើដំណើរទៅដល់ទីណាទេ នៅពេលដែលសាកសួរសំណួរបែបនេះ គឺគ្រាន់តែថាយើងចង់ដឹងអំពីអ្វីដែលគាត់បានឃើញនៅក្រាំងតាចាន់ ក៏ដូចជាការប្រព្រឹត្តចំពោះប្រជាជននៅក្នុងស្រុកត្រាំកក់។ ប្រសិនបើយើងទៅឲ្យហួសពីចំណុច ឈានទៅដល់ការប្រព្រឹត្តចំពោះជនជាតិវៀតណាម ដូចដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែព្យាមបញ្ចូលទាំងកម្ពុជាក្រោម។ ខ្ញុំគិតថា យើងមានបញ្ហាលើអង្គច្បាប់។ ខ្ញុំមិនប្រាកដថាតើយើងគួរហៅថាយ៉ាងម៉េចជាបញ្ហាយុត្តាធិការ ឬក៏បញ្ហាអ្វីមួយទេ ព្រោះនៅក្នុងដីកាដំណោះស្រាយបានបញ្ជាក់ច្បាស់ ហើយបាននិយាយយោងយ៉ាងច្បាស់ថា មិនមានការចោទប្រកាន់ប្រឆាំងកូនក្ដីខ្ញុំ និង ខៀវ សំផន ចំពោះការប្រព្រឹត្តទៅលើប្រជាជនខ្មែរកម្ពុជាក្រោម។ ដូច្នេះខ្ញុំលើកឡើងនេះ គឺចង់ឲ្យមានការណែនាំទាក់ទងទៅនឹងប្រធានបទដែលស្ថិតនៅក្រៅ មិនត្រឹមតែក្រៅវិសាលភាពនៃការជំនុំជម្រះប៉ុណ្ណោះទេ ថែមទាំងក្រៅវិសាលភាពនៃដីកាដំណោះស្រាយទៀត។

[០៩:៥១:៣៨]

**កញ្ញា អង់តា ហ្គីសសេះ**

ជម្រាបសួរលោកប្រធាន។ សូមអរគុណដែលបានអនុញ្ញាតឲ្យខ្ញុំលើកឡើងមតិយោបល់។ ខាង ខៀវ សំផន យើងគាំទ្រទៅលើការលើកឡើងរបស់ លោក កូប៉េ ។ នៅក្នុងដីកាដំណោះស្រាយគឺអត់មាននិយាយអំពីចំណុចហ្នឹងទេ។ អ៊ីចឹង ខ្ញុំគិតថាយើងគួរតែគោរពទៅតាមអ្វីដែលបានកំណត់រួចមកហើយ។ អ៊ីចឹង គឺថាយើងមិនគួរលើកឡើងនូវចំណុចនេះនៅក្នុងសវនាការទេ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

លោកប្រធាន សូមអរគុណដែលផ្ដល់វេទិកាឲ្យខ្ញុំឆ្លើយតប។ យើងដឹងច្បាស់ហើយថា នៅក្នុងក្របខ័ណ្ឌនៃសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ខ្មែរក្រោមគេហៅផ្សាភ្ជាប់គាត់ទៅជាកម្ពុជាក្រោម -- ទៅជាវៀតណាម។ ដូច្នេះយើង អង្គជំនុំជម្រះ ជំនុំជម្រះការធ្វើទុក្ខបុកម្នេញទៅលើអ្វីដែលកើតនៅសហករណ៍ត្រាំកក់។ ដូច្នេះ ខ្ញុំអាចសួរសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីបំភ្លឺអំពីឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញ រួមទាំងការប្រព្រឹត្តចំពោះវៀតណាមដែលធ្វើឡើងនៅសហករណ៍ត្រាំកក់។ ដូច្នេះ ខ្ញុំអាចសួរសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីបំភ្លឺអំពីឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញ ព្រមទាំងការ

ប្រព្រឹត្តចំពោះវៀតណាមដែលធ្វើឡើងនៅសហករណ៍ត្រាំកក់។ ដូច្នេះ ខ្ញុំគិតថាខ្ញុំដូចជាអត់មានចាកចេញពីវិសាលភាពទេ។ យើងៗសួរសំណួរទៅកាន់ដើមបណ្តឹងនេះ គឺច្បាស់លាស់ណាស់ ពីព្រោះថាមានសេចក្តីសម្រេចដែលទទួលស្គាល់ថា ខ្មែរក្រោមមិនមែនជាក្រុមដាច់ដោយឡែកទេ។ អ៊ីចឹង ខ្ញុំសួរចង់ដឹង ថាតើខ្មែរក្រហមនេះគេចាត់ទុកថាជាវៀតណាម ហើយអ៊ីចឹងនៅពេលដែលមានឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញចំពោះលើគាត់នោះ ខ្ញុំគិតថាយើងអាចសួរបាន។ ហើយខ្ញុំគិតថា អង្គជំនុំជម្រះក៏ចង់សួរនាំដើមបណ្តឹងរដ្ឋប្បវេណីនេះដែរ។ ដូច្នេះ ខ្ញុំគិតថាអ្វីដែលខ្ញុំសួរនេះ គឺវាមានភាពពាក់ព័ន្ធ។ ដូច្នេះ សូមឲ្យលោកប្រធានមេត្តាអនុញ្ញាតឲ្យខ្ញុំបន្តសួរទៅទៀត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:៥៣:៣៥]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់លើកមតិមួយចំនួនផងដែរ ព្រោះថាមិត្តសហការី គឺថាមិត្តរបស់ខ្ញុំបានលើកឡើងខុសទាក់ទងទៅនឹងអ្វីដែលបានធ្វើនៅក្នុងការស៊ើបអង្កេត។ នេះគឺជាមិនមែនជាបញ្ហាពាក់ព័ន្ធទៅនឹងថាតើអ្វីដែលបានកើតឡើង ឬក៏មិនកើតឡើងនោះឡើយ។ វាជា -- វាៗពាក់ព័ន្ធទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមចំពោះខ្មែរក្រោម។ ដូច្នេះ វាអត់មានពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់ ឬក៏អ្វីនោះឡើយ។ ចំណុចទីពីរ គឺថាដីកាដំណោះស្រាយ ពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់ និងការប្រព្រឹត្តចំពោះប្រជាជនវៀតណាម គឺមានទាំងខ្មែរក្រោមផងដែរ។ ដូច្នេះ វាមិនមានបញ្ហាអ្វីនោះទេ ដែលថាសក្ខីកម្មរបស់សាក្សីនេះ គឺវាស្ថិតនៅក្នុងក្របខ័ណ្ឌរបស់ដីកាដំណោះស្រាយ។ ដូច្នេះ ខ្ញុំចង់យោងទៅលើកថាខណ្ឌ៣២០ នៃដីកាដំណោះស្រាយដែលនិយាយអំពីការចោទប្រកាន់ ចំពោះការប្រព្រឹត្តចំពោះខ្មែរក្រោមនៅក្នុងស្រុកត្រាំកក់ ក៏ដូចជាការផ្លាស់ប្តូរប្រជាជនកម្ពុជាក្រោម ជាមួយនឹងប្រជាជនវៀតណាម។ ដូច្នេះ ចំណុចចុងក្រោយមួយទៀត ដែលខ្ញុំចង់លើកឡើង គឺបញ្ហាក្រាំងតាចាន់។ អ្នកណាក៏ដោយដែលគេចោទប្រកាន់ ហើយចាប់បញ្ជូនចាត់ទុកថាជាខ្មែរក្រោមគឺសុទ្ធតែជាបញ្ហា ទោះបីថាពួកគេជាខ្មែរក្រោម ជាវៀតណាម ឬក៏ជាប្រជាជនមូលដ្ឋានក៏ដោយ។ ដូច្នេះ ខ្ញុំកាលដែលលើកឡើងចំណុចនេះវាហួសពីវិសាលភាពនៃដីកាដំណោះស្រាយ គឺជាការមិនអាចទទួលយកបាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកតបទៅនឹងសេចក្តីតបរបស់ភាគីម្ខាងទៀតទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៧:០៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ សម្រេចលើក្តីជំទាស់របស់ភាគី ឬតាំងសំណួរចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសម្រេចបដិសេធការលើកឡើងដោយមេធាវីការពារក្តីដោយសារមានមូលហេតុមួយចំនួន។ ជាដំបូងគឺ អង្គហេតុពាក់ព័ន្ធទៅនឹងសក្ខីកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីនេះបានលើកឡើងហ្នឹងគឺវាពាក់ព័ន្ធទៅនឹងជីវភាពរស់នៅនៅស្រុកត្រាំកក់ នៅសហករណ៍ត្រាំកក់។ ដូច្នេះ ចំណុចនេះមានភាពពាក់ព័ន្ធហើយ បើតាមអង្គជំនុំជម្រះនោះ។ ចំណុចទី២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្តៅទៅលើអង្គហេតុមួយចំនួនពាក់ព័ន្ធនឹងខ្មែរក្រោម។ ដូច្នេះយើងគិតថា សំណួរដែលសួរហ្នឹងក៏វាចូលទៅក្នុងវិសាលភាពដែរ ហើយចំណុចចុងក្រោយ អង្គជំនុំជម្រះសូមរំឭកថា ខ្លួននឹងសម្រេចថាអ្នកណាខ្លះដែលត្រូវចាត់ទុកចូលទៅក្នុងក្រុមវៀតណាម គឺថាវៀតណាម ជាសញ្ជាតិវៀតណាមតែម្តង ឬក៏មានអ្នកផ្សេងទៀតដែលគេចាត់ទុកថាជាជនជាតិវៀតណាមដែរ។ ដូច្នេះ បញ្ហាពាក់ព័ន្ធទៅនឹងការលំបាកនេះគឺ ពិតជាចូលទៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តីរបស់យើងនេះហើយ។ ដូច្នេះ យើងអនុញ្ញាតឲ្យសួរបន្តទៀតបាន។

[០៩:៥៨:៥០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី មុនពេលកាត់ផ្តាច់អម្បាញ់មិញនេះ ខ្ញុំសួរលោកនូវសំណួរមួយពាក់ព័ន្ធនឹងចំណុចចង់ដឹងថាតើខ្មែរក្រហមមានមធ្យោបាយអ្វីខ្លះ ដើម្បីដឹងថាអ្នកណាខ្លះជាខ្មែរក្រោម អ្នកណាខ្លះមិនមែនជាខ្មែរក្រោមនោះ? ខ្ញុំចង់ដឹងថា នៅពេលដែលលោកមកដល់ត្រាំកក់ តើលោកមាន

ឃើញគេធ្វើបញ្ជីឈ្មោះទេ? លោកមានបានឃើញផ្ទាល់ភ្នែកទេ ថាមានខ្មែរក្រហមធ្វើយ៉ាងម៉េចពាក់ព័ន្ធនឹងខ្មែរក្រោមហ្នឹង? គេមានចុះជាបញ្ជី ហើយគេចុះឈ្មោះថា ហ៎! ឈ្មោះ ក, ឈ្មោះ ខ អ៊ីចឹងជាខ្មែរក្រោម។ គេមានធ្វើអ៊ីចឹងទេ?

**ឆ៖** បាទ រាល់បញ្ហាហ្នឹងខ្ញុំអត់ដឹងដែរ ហ្នឹងការងារផ្ទៃក្នុងរបស់ខ្មែរក្រហម។ ពេលនោះ ព្រោះអីយើងជា បើយើងនិយាយទៅ គេចាត់ទុកយើងដូចជាសត្វធាតុអ៊ីចឹង គេអត់បាន អ្វីទាំងឡាយណាដែលគេធ្វើ គេមិនបានប្រាប់យើងឲ្យដឹង ឬមួយក៏គេអត់មានចេញកាយវិការអីឲ្យយើងចាប់អារម្មណ៍ដែរបាទ។

[១០:០០:១៧]

**ស៖** សូមអរគុណ។ មុននេះបន្តិចលោកនិយាយថា ក្នុងកងរបស់លោកនោះមានខ្មែរក្រោម និងអ្នក១៧ គឺអ្នកថ្មី។ ចុះលោកផ្ទាល់នុ៎ង លោកស្គាល់ខ្មែរក្រោមដែលស្ថិតនៅក្នុងកងរបស់លោក ហើយរស់នៅត្រាំកក់ទេ? លោកស្គាល់ច្បាស់ទេ?

**ឆ៖** បាទ កាលពីសម័យនោះ ដែលអ្នកនៅជាមួយខ្ញុំដូចជា កងចល័តដូចគ្នា ខ្ញុំមានស្គាល់ៗខ្លះ ហើយអ្នក១៧នុ៎ងក៏ខ្ញុំស្គាល់។ ក្រោយមករយៈពេល គិតទៅយើងជាង៣០ឆ្នាំហើយ យើងមានការភ្លេចភ្លាំងខ្លះហើយ ភ្លេចឈ្មោះខ្លះហើយ ប៉ុន្តែដល់ជួបគ្នាអ៊ីចឹងទៅបាននឹកឃើញអ៊ីចឹងទៅ និយាយពីប្រវត្តិមកខ្ញុំមានអារម្មណ៍ថា អ្ហូ! នៅជាមួយគ្នានៅសម័យអាពត។ អ៊ីចឹងបើយើងពិពណ៌នាឈ្មោះឲ្យអស់ក៏អត់នឹកអត់ឃើញទេបាទ។

**ស៖** សូមអរគុណ។ ខ្ញុំចង់ដឹងថា ក្នុងអំឡុងពេលដែលរស់នៅ លោករស់នៅត្រាំកក់ គឺពីខែមេសា -- សូមទោស ខែកុម្ភៈ ៧៦ រហូតទៅដល់៧៩ នុ៎ង លោកមានឃើញការចាប់ខ្លួនទេ?

[១០:០១:៥៦]

**ឆ៖** បាទ បើខ្ញុំ -- យើងរស់នៅកងចល័តពេលសម័យអាពត មិនមែនយើងនៅតែមួយកងហ្នឹងទេ។ កាលណាយើងចុះការដ្ឋានជីកព្រែក ជីកប្រឡាយហ្នឹង គឺប្រជាជនពលរដ្ឋទូទាំងខេត្តហ្នឹង ខេត្តតាកែវហ្នឹង ទៅកន្លែងណា ទីតាំងសំខាន់ៗគេប្រមូលផ្ដុំទៅ។ សម័យអាពតគេហៅថាវ៉ៃសម្រុកណ៎ា។ អ៊ីចឹងគឺប្រមូលទៅជីក ទៅធ្វើសកម្មភាពទាំងអស់នៅទីនោះ។ អ៊ីចឹងការវាយចាប់ចង វាធ្វើបាបហ្នឹងជារឿងហូរហែរាល់ថ្ងៃហ្នឹង ប៉ុន្តែគេអត់ថាយកទៅវ៉ៃចោល ឬយកទៅសម្លាប់ទេ គេថាយកទៅរៀនសូត្រ ហើយសម័យនុ៎ង ខ្ញុំឃើញគេចងជាហូរហែអ៊ីចឹង ប៉ុន្តែថា គេថាយកទៅរៀនសូត្រ ហើយអ៊ីចឹងយើងក៏មិនបានសួរនាំគេដែរ គ្រាន់តែឃើញអ៊ីចឹងភ័យរកតែព្រលឹង រកតែអាយុជីវិតដូចគ្នាហ្នឹង។ មាននរណា

បានទៅសួរនាំគេសម័យនោះ គេបិទសិទ្ធិយើងមិនឲ្យនិយាយស្ដី មិនឲ្យដឹងឮអីទាំងអស់។

**ស៖** នៅពេលដែលលោកដឹងថា លោកដឹងច្បាស់អំពីអ្វីដែលកើតឡើងចំពោះអ្នកដែលគេបញ្ជូនទៅអប់រំហ្នឹង លោកអាចបញ្ជាក់ឲ្យបានច្បាស់ទេថា លោកដឹងដោយវិធីណា ហើយមានអ្វីកើតឡើងចំពោះអ្នកទាំងអស់នោះដែរ?

[១០:០៣:២៥]

**ឆ៖** បាទ ការចាប់យកទៅអប់រំហ្នឹង ខ្ញុំអត់ដឹងថា គេយកទៅសម្លាប់ ឬមួយគេយកទៅណាទេ ប៉ុន្តែអង្គការនយោបាយរបស់គេហ្នឹង គេ ដូចថាពេលគេចាប់ចងអ្នកណាមួយក្នុងការដ្ឋានហ្នឹង គេថាយកវាទៅរៀនសូត្រ។ គេគ្រាន់តែប្រាប់ប៉ុណ្ណឹង ដល់គេយកទៅសម្លាប់ ឬមួយគេយកទៅធ្វើទារុណកម្មនៅកន្លែងណាខ្ញុំអត់បានដឹងដែរ ប៉ុន្តែគេគ្រាន់ប្រាប់ថាយកទៅរៀនសូត្រ។ អាហ្នឹងអាមេៗកង ប្រធានកងហា ប្រធានកងរយគេនុ៎ង បានគេដឹង ហើយដល់យើងសម្រាប់ជាប្រជាពលរដ្ឋទូទៅហ្នឹងអត់អាចដឹងទេបាទ។

**ស៖** សូមអរគុណ។ តើលោកបានឃើញផ្ទាល់ភ្នែកទេ នៅពេលដែលលោកនៅត្រាំកក់នោះ នៅសាកសព ឬក៏ឃើញមនុស្សកំពុងតែប្រកាច់ត្រដរខ្យល់ជិតស្លាប់នោះ?

**ឆ៖** បាទ បើខ្ញុំនិយាយពីសម័យអាពត ពេលគេបញ្ជូនខ្ញុំទៅនៅភូមិពងទឹក ៗហ្នឹងវាមិនឆ្ងាយពីក្រាំងតាចាន់ទេ ប៉ុន្តែសម័យនុ៎ង ខ្ញុំអត់ដឹងថាកន្លែងនេះក្រាំងតាចាន់ ឬមួយកន្លែងនេះទីតាំងរបស់ឈ្លបគេ ឬទ័ពគេក៏ខ្ញុំអត់ដឹងដែរ។ ពេលខ្ញុំទៅដល់នោះគេឲ្យខ្ញុំខាងភ្ជួររាស់ ហើយអ៊ីចឹងពេលបាយថ្ងៃម៉ោងប្រហែលជាមួយហ្នឹង ខ្ញុំដាក់គោពីនឹមហ្នឹង។ អ៊ីចឹងអាគោហ្នឹងវាស៊ីៗស្មៅអ៊ីចឹង វាដើរទៅៗវាជិតដល់ព្រៃ។ កាលពីសម័យអាពតនោះកន្លែងក្រាំងតាចាន់ហ្នឹងព្រៃធំណាស់។ អ៊ីចឹងខ្ញុំអត់ដឹងថា ចំណុចទីតាំងរបស់គេ ឬមួយក្រាំងតាចាន់ទេ។ អ៊ីចឹងពេលខ្ញុំទៅដេញគោ ទៅឃើញឈ្មោះ ចាន់ វានៅកងជាមួយខ្ញុំ។ ទៅគេវៃវាមិនពីថ្ងៃណាខែណា ក៏ខ្ញុំអត់ដឹងដែរ អត់បានចាំថ្ងៃខែដែរ។ ប៉ុន្តែទៅដល់វាមិនទាន់ដាច់ខ្យល់ងាប់ទេ ឃើញវាឈាមប្រលាក់ពេញខ្លួន ពេញមុខហ្នឹង វាប្រាប់ថា “ឲ្យទៅប្រាប់ម្ដាយខ្ញុំផង ខ្ញុំមិនរស់ទេ”។ ហើយឲ្យខ្ញុំចេញពីទីហ្នឹងឲ្យលឿន កន្លែងហ្នឹងគេនៅឈ្លបគេទៅហូបបាយអស់ហើយ អ៊ីចឹងគេឲ្យខ្ញុំឲ្យលឿន ហើយខ្ញុំក៏ភ័យតក់ស្លុតដែរ គ្រាន់តែឃើញអ៊ីចឹងប្រវេប្រវាដេញគោមកវិញ មកកន្លែងលំនឹងរបស់ខ្ញុំវិញ។ អ៊ីចឹងការឃើញហ្នឹង ខ្ញុំឃើញពិតប្រាកដមែន ប៉ុន្តែយើងមិនអាចនៅពិនិត្យពិច័យថា អ្នកនេះងាប់ អ្នកនេះរស់ មានប៉ុន្មាននាក់អី ក៏ខ្ញុំអត់ដឹងដែរ គ្រាន់តែឃើញថា ចាន់ហ្នឹង វារងគ្រោះដោយសារគេ

វាយ។ អ៊ីចឹងសម័យអាពត ហ្នឹងបើតាមខ្ញុំដឹង កាលណា -- ខ្ញុំដឹងតាមការប្រយោលរបស់អាពួកអាក្មេងៗមូលដ្ឋានតូចៗហ្នឹង វាថា ពួងឯដាក់តែមួយបំពង់សង្កែ ងាប់មិនងាប់ទុកចោលហ្នឹងហើយ។ អាហ្នឹងឮអាពួកមូលដ្ឋាននិយាយអ៊ីចឹងមែន។ អាហ្នឹងបើតាមដឹងៗរយៈអ៊ីចឹង។ តាមរយៈហ្នឹងបាទ។

[១០:០៦:៥៦]

**ស៖** សូមអរគុណលោក។ លោកនិយាយឈ្មោះ ចាន់ អ៊ីចឹង ចាន់ ហ្នឹងជាខ្មែរក្រោមដែរឬទេ?

**ឆ៖** បាទ ចាន់ ហ្នឹងវានៅកងចល័តជាមួយខ្ញុំ វាឡើងមកពីវៀតណាមដែរបាទ។ វាទៅ គេបែងចែកជាកងអ៊ីចឹង គេ -- ព្រោះអីយើងនៅកាលនោះនៅឯវៀតណាមនោះ គេហៅថា "ឃុំ" – គេហៅថា "ឃុំ" អាហ្នឹងភូមិ។ អ៊ីចឹងភូមិវាខុសៗគ្នា ដល់ពេលទៅ គេដាក់ច្របាច់យើងបញ្ចូលគ្នាទៅ ខ្ញុំស្គាល់វាតាមរយៈហ្នឹង។ ទៅជំនាន់អាពត គេដាក់ចម្រុះគ្នាអ៊ីចឹងមក អាអ្នកទៅពីឃុំន ហើយអ្នកមកពី១៧ហ្នឹង គេដាក់លាយឡំគ្នាអ៊ីចឹងមក។ អ៊ីចឹងយើងនៅរស់នៅយូរឆ្នាំអ៊ីចឹងទៅ ចេះតែស្គាល់គ្នាអ៊ីចឹងមក។ ដល់ពេលយើងបែកគ្នា គិតទៅ៣០ឆ្នាំៗជាងហើយ អ៊ីចឹងការភ្លេចភ្លាំងវាភ្លេចឈ្មោះអស់ហើយ បើឃើញមុខគ្នា ដូចខ្ញុំជម្រាបជូនខាងដើមអ៊ីចឹង ឃើញអ៊ីចឹងទៅ នៅចាំគ្នាសួរនាំគ្នាអ៊ីចឹងទៅ ដឹងវិញ។

**ស៖** សូមអរគុណ។ ហើយចុះពេលចុងក្រោយ តើមានរឿងអ្វីកើតឡើងចំពោះ ចាន់ ហ្នឹង?

**ឆ៖** បាទ ចាន់ ខ្ញុំឃើញគេយកទៅធ្វើទារុណកម្មអ៊ីចឹង ប៉ុន្តែមិនដឹងមូលហេតុអីដែលគេចាប់វាយកទៅវ៉ៃធ្វើទារុណកម្មហ្នឹង ក៏ខ្ញុំអត់ដឹងដែរ។ ទោះបីនៅកងជាមួយគ្នាហ្នឹង ដេកក្បែរគ្នា គេយកអត់មានឲ្យយើងដឹងទេ។ អ៊ីចឹងអានយោបាយរបស់ខ្មែរក្រហមហ្នឹងវាឃោឃៅណាស់។ ទោះបីយើងនៅក្បែរគ្នាហ្នឹង បើថាគេត្រូវហៅយើងទៅណើទីណាអ៊ីចឹង គេអត់មានមកហៅផ្ទាល់កំពុងនៅជុំគ្នាអ៊ីចឹងទេ គេមាននីរសាររបស់គេមួយ គេទៅកេះយើងខ្សោក គេថាមេកងឲ្យហៅអ៊ីចឹង។ ហើយអ៊ីចឹងអ្នករស់នៅជាមួយគ្នាហ្នឹងអត់ដឹងថាហៅទៅណាមកណាទេ ព្រោះអីនីរសារគេហៅ គេមកហៅអ៊ីចឹងទៅ ហើយយើងមិនបានចាប់អារម្មណ៍រឿងគេយកទៅសម្លាប់ ឬមួយគេយកទៅធ្វើទារុណកម្ម យើងអត់ដឹងដែរ។

[១០:០៩:២២]

**ស៖** សូមអរគុណ។ តាមការបកប្រែជាភាសាបារាំងមក ខ្ញុំយល់ថាលោកបានឃើញការធ្វើទារុណកម្មទៅលើ ចាន់។ អ៊ីចឹង តើខ្ញុំស្តាប់ឮហ្នឹងត្រឹមត្រូវទេ? ហើយបើសិនជាត្រឹមត្រូវថាលោកឃើញផ្ទាល់ភ្នែកថា គេធ្វើទារុណកម្ម ចាន់ មែនហ្នឹង។ អ៊ីចឹងលោកអាចឆ្លើយឲ្យបានជាក់លាក់លម្អិតជាងហ្នឹងបន្តិចបានទេ?

**ឆ៖** បាទ ដូចខ្ញុំចម្រាបជូនខាងដើមអ៊ីចឹង។ ខ្ញុំមិន -- ឃើញ ប៉ុន្តែខ្ញុំមិនបានលម្អិតនៅជុំវិញហ្នឹងថាខ្មោចនៅក្បែរហ្នឹងមានប៉ុន្មាននាក់ ហើយទីតាំងហ្នឹងមានឈ្លប ឬទ័ពគេសម្រាប់យកមនុស្សទៅធ្វើឃាតហ្នឹងប៉ុន្មាននាក់ ក៏ខ្ញុំអត់ដឹងដែរ ឃើញតែ ចាន់ ហ្នឹងនៅដេកនៅក្នុងរណ្ដៅគេៗជីកបណ្ដោយអ៊ីចឹង ប្រវែងជា២០ម៉ែត្រ កាលពីសម័យហ្នឹងនៅក្នុងព្រៃអ៊ីចឹង ដល់អ៊ីចឹងគ្រាន់វាស្រែកប្រាប់ខ្ញុំអ៊ីចឹងខ្ញុំភ្ញាក់កាលពីសម័យនោះ បើវាមានដូចថាអបិយជំនឿអ៊ីចឹង យើថាខ្មោចលងហើយ។ ប៉ុន្តែសម័យអាពតគេមិនឱ្យមានជឿមានអីទេ អ៊ីចឹងបាន -- ដល់អ៊ីចឹង វាអានឈ្មោះវាច្បាស់អ៊ីចឹង បានខ្ញុំដឹងថា ចាន់មែន។ ហើយបើយើងមិនៗ វាមកអានឈ្មោះមិនដឹងច្បាស់ ក៏មិនអាចថា ចាន់ដែរ ថាខ្មោចលងហើយ។

**ស៖** សូមអរគុណ។ លោកនិយាយថា ចាន់ ហ្នឹងនៅពេល -- លោកឃើញមានសាកសពជាច្រើនទៀត។ ហើយអ៊ីចឹងនៅក្នុង -- ខ្ញុំចង់ដឹងថានៅក្នុងរណ្ដៅដែលគេដាក់ ចាន់ ហ្នឹង លោកមានឃើញសាកសពផ្សេងទៀតជាច្រើនមែនទេ?

**ឆ៖** បាទ នៅពេលនោះ ខ្ញុំគ្រាន់តែចោលភ្នែកទៅឃើញខ្មោចដាប់នៅក្បែរៗហ្នឹងដែរ។ អ៊ីចឹងបានខ្ញុំថា ដូចខ្ញុំជម្រាបជូនខាងដើមអ៊ីចឹង គ្រាន់តែឃើញអ៊ីចឹង ចាន់ ហ្នឹងវាប្រាប់ថាមកឱ្យលឿន ខ្ញុំក៏មិនបាននៅរំពៃដែរ។ ហើយក៏មិនបាននៅប្រមើលមើលអីឱ្យសព្វជ្រុងជ្រោយដែរ។ ខ្ញុំរួតមកដើម្បីការពារអាយុជីវិតខ្ញុំដែរ ខ្លាចលោគេឃើញ ឈ្លបគេឃើញឬមួយគេទាន់ ខ្ញុំនឹងវាត្រូវស្លាប់ដែរពេលហ្នឹងជាមួយចាន់ ហើយ។

[១០:១១:៥០]

**ស៖** សូមអរគុណ។ ដោយសារតែពេលវេលាខ្លី ខ្ញុំសួរសំណួរបន្តទៀត ហើយចូលទៅប្រធានបទផ្សេង។ ដូច្នេះ ខ្ញុំចង់ដឹងថានៅក្នុងអំឡុងពេលដែលលោកនៅត្រាំកក់គឺក្នុងពីខែកុម្ភៈ ៧៦ រហូតទៅដល់ ៧៩ នោះ តើគេមានសុំឱ្យលោករៀបការទេ?

**ឆ៖** បាទ មុនពេលថ្ងៃរំដោះហ្នឹងនៅអង្គរនារាយណ៍ហ្នឹងគេហៅភូមិអង្គរនារាយណ៍ហ្នឹង មេឃុំគេៗរៀបចំ កាលពីសម័យអាពតគេហៅថាប្ដេជ្ញា អ៊ីចឹងគេឱ្យប្ដេជ្ញាហ្នឹង ប្ដេជ្ញាចិត្តហ្នឹង បើអ៊ីចឹងមានរូបខ្ញុំដែរ។ ប៉ុន្តែពេលនោះ ត្រូវឈឺៗគេផ្អាក សម័យអាពតផ្អាកមួយត្រូវផ្អាកទាំងអស់។ ដល់ផ្អាក ពេលខ្ញុំថាមិនបានទៅអ៊ីចឹង រំលងមកបានជាប្រហែល៦ឬ៧ថ្ងៃ វៀតណាមបុកចូលមក វាដាច់ស្រឡះអ៊ីចឹងទៅ។ វាអស់អាណត្តិវា ខ្ញុំបានមកនៅភូមិកំណើតរៀងៗខ្លួនអ៊ីចឹងទៅបាទ។

**ស៖** សូមអរគុណ។ តើលោកដឹងថានៅពេលហ្នឹងលោកត្រូវរៀបការជាមួយអ្នកណាទេ?

ហើយអ្នកដែលលោកត្រូវរៀបការជាមួយហ្នឹងក៏ជាខ្មែរក្រោមដែរមែនទេ?

**ឆ៖** បាទ អ្នកដែល--

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតបដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងការប្រើពាក្យខ្មែរក្រោម -- ស្ត្រីកម្ពុជាក្រោមព្រោះថាពាក្យនេះមិនមែនជាពាក្យដែលសាក្សីនិយាយ។ សាក្សីនិយាយថាកម្ពុជាក្រោម។ ខ្ញុំគិតថាសក្ខីកម្មនេះនិយាយអំពីខេត្តតាកែវ គាត់នៅព្រំដែន ហើយគាត់ត្រលប់មកតាកែវ។ ខ្ញុំមិនបានឮគាត់និយាយពាក្យកម្ពុជាក្រោមនោះទេ។ ដូច្នេះ ការណ៍ដែលប្រើប្រាស់ពាក្យ ឬក៏ការណ៍ដែលយកពាក្យកម្ពុជាក្រោមមកប្រើ គឺជាការធ្វើឲ្យខុសទៅលើភស្តុតាង។ ដូច្នេះ ខ្ញុំជំទាស់ទៅលើការប្រើប្រាស់ពាក្យនេះ។

[១០:១៤:២៥]

**លោក គង់ សំអុន៖**

បាទ ខ្ញុំសូមគាំទ្រចំពោះលោកមេធាវី កូប៉េ។ ហើយខ្ញុំយល់ថាវាជាសំណួរនាំមុខដោយសារសាក្សីមិនបាន -- ដើមបណ្ដឹងរដ្ឋប្បវេណីមិនបាននិយាយអំពីការរៀបការជាមួយនារីខ្មែរក្រោមទេ ហើយមេធាវីនាំមុខបានបង្ហាញចំណុចនេះ។ បាទ សូមអរគុណ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

អ៊ីចឹង ខ្ញុំសូមរៀបចំសំណួរឡើងវិញលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** តើលោកដឹងថាលោកត្រូវរៀបការជាមួយអ្នកណាទេ?

**លោក វី ពៅ៖**

**ឆ៖** បាទសម័យនោះគេឲ្យខ្ញុំរៀបការជាមួយនារីនុង៎មកពីភូមិកំណើត ស្រុកកំណើតជាមួយខ្ញុំដែរ ត្រូវជាបងប្អូនខ្ញុំដែរ។ អ៊ីចឹង នារីនោះឈ្មោះនារី រិន បាទ។ តែមិនបានសម្រេចទេ ដោយពេលនោះខ្ញុំឈឺ ហើយក្រោយមកត្រូវយើងរំដោះអ៊ីចឹងទៅ វាមិនបានទទួលជោគជ័យដូចគម្រោងដែលគេបានរៀបចំនោះទេបាទ។

**ស៖** សូមអរគុណ។ តើលោកបានឃើញគេរៀបការទេ ខ្ញុំមិនចង់និយាយពីការរៀបការរបស់

លោកទេ។ ខ្ញុំចង់និយាយពីការផ្សេងដែលលោកធ្លាប់ឃើញមានពិធីរៀបការផ្សេងទៀតទេ?

**ឆ៖** បាទ កាលពីសម័យ ប៉ុល ពត នុង កាលណា ព្រោះអីវាមានកម្មវិធីប្ដេជ្ញាចិត្តជារៀងរាល់ឆ្នាំ។ មួយឆ្នាំៗម្ដងអ៊ីចឹងទៅ។ អ៊ីចឹង ឧទាហរណ៍ ខ្ញុំសម័យនោះ បើសិនណាក្នុងកងចល័តរបស់យើងហ្នឹងមាន១ពីរឬបីគូ អាហ្នឹងបានយើងមានមុខទៅចូលរួម គេហៅយើងទៅចូលរួមស្ដាប់។ អ៊ីចឹងមកក្នុងកងរបស់យើងគ្មានអ្នកប្ដេជ្ញាទេ គេអត់ឲ្យទៅចិត្តទេ។

[១០:១៦:៤២]

**ស៖** សូមអរគុណ ខ្ញុំមានសំណួរចុងក្រោយ។ លោកឆ្លើយថា -- លោកគេហៅថា "អាយួន"។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើអ្នកដែលគេហៅអាយួនហ្នឹង រៀបការបានតែជាមួយគ្នាឯងដែលអាយួនដូចគ្នាហ្នឹង ឬក៏អាចរៀបការជាមួយអ្នកផ្សេងទៀតបាន?

**ឆ៖** បាទកាលពីសម័យនោះ បើតាមខ្ញុំពិនិត្យឃើញ ប្រជាពលរដ្ឋ១៧មេសា និងអ្នកមកពីយួនអាហ្នឹងគេថាប្រវត្តិរូបប្រហែលគ្នា អ៊ីចឹងគេអាចតម្រូវឲ្យប្ដេជ្ញាចិត្តបានបាទ ហើយបើផ្នែកគេមូលដ្ឋានគេមិនមកបៀតបៀនយើងទេ គេតែគ្នាគេហ្នឹងបាទ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។

លោកប្រធាន ខ្ញុំបញ្ចប់ការសួរសំណួរហើយ ខ្ញុំសូមប្រគល់វេទិកានេះ ជូនលោកមេធាវី ឡោ ជុនធី បន្តទៀត។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់និងសាមសិបនាទី។ បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៨ នាទី ដល់ម៉ោង ១០:៣៥ នាទី)*

[១០:៣៥:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ហើយជម្រាបថា រួមទាំងសហព្រះរាជអាជ្ញាមានពេលតែមួយម៉ោងទៀតប៉ុណ្ណោះ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីនៅក្នុងអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា។ នៅពេលនេះសូមគោរពអង្គជំនុំជម្រះទាំងមូល សូមគោរពអ្នកដែលទស្សនានៅទីនេះ ហើយនិងទស្សនាតាមប្រព័ន្ធផ្សព្វផ្សាយនានា។ នៅពេលនេះ ខ្ញុំបាទសុំធ្វើសំណួរមួយចំនួនដែលលោកដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ដែលមកថ្លែងសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សំណួររបស់ខ្ញុំមានបីផ្នែក ផ្នែកទី១ ដែលខាងសហមេធាវីខ្ញុំបានលើកឡើងហើយ ដែលពាក់ព័ន្ធនឹងការដោះដូរប្រជាជនខ្មែរយើងជាមួយនឹងប្រជាជនខាងវៀតណាម។ ចំណុចទី២ ខ្ញុំចង់ដឹងអំពីការពាក់ព័ន្ធនឹងការធ្វើការដោយបង្ខំ ហើយចំណុចទី៣អាចពាក់ព័ន្ធនឹងការសម្លាប់បងប្អូនរបស់លោក។

ចំណុចទី១ អ្វីដែលពាក់ព័ន្ធនឹងការដោះដូរនេះ ខ្ញុំចង់ដឹងថាអ៊ីចេះថា តើនៅពេលដែលលោកនៅក្នុងប្រទេសវៀតណាមហ្នឹង តើខាងប្រព័ន្ធផ្សព្វផ្សាយវៀតណាមហ្នឹងបានប្រាប់ជម្រាបទៅលោកថាយ៉ាងដូចម្តេច បានលោក និងក្រុមគ្រួសារលោកយល់ព្រមត្រឡប់មកស្រុកខ្មែរយើងវិញ?

[១០:៣៨:០៩]

**ឆ៖** បាទ សូមគោរពលោកប្រធាន។ នៅពេលនោះ សម័យនោះ កាលឡើងមកខ្ញុំក៏អត់ដឹងថាការដូរ ឬមួយគេមានកម្មវិធីគេដោយរបៀបណាក៏ខ្ញុំអត់ដឹងដែរ ប៉ុន្តែនៅខាងវៀតណាមហ្នឹងគ្រាន់តែប្រាប់ថាបងប្អូនខ្មែរដែលភៀសខ្លួនមកនៅក្នុងប្រទេសគេ ក្នុងទឹកដីរបស់គេហ្នឹង ឥឡូវគេបានដូរវៀតណាមយកថ្នូរពីវៀតណាម គឺខ្មែរមកកម្ពុជាវិញ បាទ គ្រាន់តែប្រាប់តែប៉ុណ្ណឹង។

**ស៖** គឺថាតើនៅវៀតណាមនោះ ពេលដែលបងប្អូនខ្មែរយើងជម្លៀសចូលទៅប្រទេសវៀតណាម

តើនៅក្នុងប្រទេសវៀតណាមហ្នឹង គេបង្កើតជាជំរំដាក់ ឬក៏យ៉ាងម៉េចកន្លែងនៅនោះ? ហើយជីវភាពរបស់យើងនៅនោះយ៉ាងម៉េច?

**ឆ៖** បាទ កាលពីសម័យនោះ តាមខ្ញុំដឹង យើងទៅនៅវៀតណាមគេហៅយើងជនភៀសខ្លួន អ៊ីចឹងទៅនៅគេអត់មានឲ្យនៅរប៉ាត់រប៉ាយទេ គេដាក់ទៅតាមជំរំគេ តំបន់គេ ងាយស្រួលគេគ្រប់គ្រង។ អ៊ីចឹង សម័យនោះមានៗខាងផ្នែករដ្ឋាភិបាលអាមេរិកាំង អ៊ីចឹងបានជំនួយមកពីហ្នឹង ដូចជាអង្ករ ដូចជាថ្នាំពេទ្យ ម្ហូបអាហារ សព្វបែបយ៉ាង គេចែកជូនឲ្យប្រជាពលរដ្ឋយើងភៀសខ្លួនទៅហ្នឹង គឺហូបគ្រប់គ្រាន់ បរិបូរបាទ។

**សៈ** បាទអរគុណ។ ចុះនៅពេលដែលមានការបញ្ជូនមកហ្នឹង តើគេ ដូចថាគេទៅចុះបញ្ជីនរណាខ្លះចង់មក នរណាខ្លះអត់ចង់មក។ តើ ខ្ញុំចង់ដឹងថាតើនៅពេលនោះ មានក្រុមគ្រួសារណាដែលមិនចង់មកដែរអត់ទេ?

**ឆ៖** បាទ ពេលនោះមានបងប្អូនយើងខ្លះ គេអត់មកដែរបង លោកប្រធាន។ គេរស់នៅទីនុំងរហូតមកដល់សព្វថ្ងៃអ៊ីចឹងដែរ។ អ្នកដែលគេមាន កាលពីដើមគេមានកេរមរតកពីដូនតាមក គេចុះពីហ្នឹង ទៅគេមានកេរមរតក មានស្រែ មានចម្ការរបស់គេនៅនុំង ហើយអ៊ីចឹងគេអត់មក។ គេនៅយកកេរតំណែលដូនតាគេ គេដើម្បីមានស្រែ មានភ្លឺ មានអីអ៊ីចឹងគេ--

**សៈ** បាទ អរគុណ។ ចំណុចមួយទៀត ថាតើពេលដែលគេបញ្ជូនបងប្អូនខ្មែរយើងមកហ្នឹង បងមានឃើញថា ការផ្លាស់ប្តូររវាងប្រជាជនខ្មែរ និងប្រជាជនវៀតណាមហ្នឹងនៅព្រំដែនហ្នឹងមានបានឃើញទេ? តើគេផ្លាស់ប្តូរយ៉ាងម៉េច ហើយនៅពេលនោះ ដែលតាមច្រកមួយណាច្បាស់លាស់បាទ?

[១០:៤១:៥៩]

**ឆ៖** បាទ ពេលនោះ គេផ្លាស់ប្តូរតាមច្រកទ្វារអន្តរជាតិថ្នល់ដាច់ បច្ចុប្បន្នហ្នឹង គេហៅទ្វារអន្តរជាតិ។ កាលពីសម័យដើម គេហៅថា "ថ្នល់ដាច់ៗ"ទទេទេបាទ។ ហើយអ៊ីចឹងផ្លាស់ប្តូរតាមហ្នឹង។ ហើយអ៊ីចឹងវៀតណាមវាទៅមុនយើងប្រហែលជាបីថ្ងៃ បានយើងឡើងមក ព្រោះអីវៀតណាម គេកាលណាអត់មានថ្នូរឲ្យគេ គេអត់ឲ្យយើងមកដែរហ្នឹង។ កាលណាបានប្រជាពលរដ្ឋគេទៅដល់ដៃគេហើយបានគេឲ្យយើងមក។

**សៈ** អរគុណ។ ចំណុចទី២ ដែលខ្ញុំចង់ដឹង គឺថានៅពេលដែលលោកពូអញ្ជើញមកដល់ស្រុកខ្មែរយើងវិញនេះ ប្រហែលជាក្នុងខែ ឆ្នាំ១៩៧៦បាទ មកវិញ នៅពេលនោះ គេបញ្ជូនទៅកងចល័ត។ តើ

កងចល័តលោកពូនៅកន្លែងណាដែរ? នៅម្តុំណា? ហើយធ្វើនៅ -- ធ្វើហ្នឹងគឺធ្វើអីគេ?

**ឆ៖** បាទ ពេលទៅដល់មុនដំបូង គឺខ្ញុំទៅនៅភូមិត្នោតជុំ ឃុំខ្ពបត្របែកហ្នឹង អ៊ីចឹងគេបែងចែកកម្លាំងខ្ញុំហ្នឹងជាកងចល័ត ឲ្យទៅចូលជាយុវជនកងចល័ត។ អ៊ីចឹងគេជម្លៀសខ្ញុំឲ្យទៅនៅក្បាលពោធិ៍ៗហ្នឹងនៅពីខាងត្បូងខេត្តតាកែវ។ អ៊ីចឹងធ្វើស្រែប្រាំង ធាក់រហាត់ ជីកប្រឡាយ រែកជី រែកដី សព្វសារពើទាំងអស់។ អ៊ីចឹងការទៅដល់ហ្នឹង មុនដំបូងពួកខ្ញុំអត់ដឹងថាគេបាយចែក ឬមួយបាយវាល់អីទេ។ ពេលទៅដល់ដំបូងហ្នឹង ហេវ ចុះយើងទៅដល់មុនដំបូង រៀងឃោរៗឃោយ៉ាដាក់គេដែរ ជេរអាចុងភៅហ្នឹងរញ៉េចរញ៉ៃចដែរ ឬ ថា “យើះ! ពួកអានេះ គ្រាន់ធ្វើបាយស៊ីក៏យឺតយ៉ាវមាំម្ល៉េះ មិនដឹងពួកអញមកពីហាត់” ស្មានតែគេធម្មតានោះ ដល់ហើយបានអ្នកគេនៅនុ៎ង ចាស់ៗគេប្រាប់ថា មិនបានទេកុំឮមាត់ តិចបាត់ខ្លួន។

[១០:៤៤:១៥]

**ស៖** បាទៗ អរគុណ។ ចំណុចសំខាន់អ៊ីចេះ នៅពេលដែលលោកពូចូលទៅក្នុងកងចល័តនោះណា ថាតើគេឲ្យយើងធ្វើការហ្នឹង ឧទាហរណ៍ថាចេញពីព្រលឹមរហូតដល់ព្រលប់អ៊ីចឹង មានពេលសម្រាក ឬមួយយ៉ាងម៉េច? ហើយអាហារហូបចុកហ្នឹងយ៉ាងម៉េច? ឯការឈឺថ្កាត់ហ្នឹងវាមានថ្នាំព្យាបាលដែរឬអត់? តើគេប្រើថ្នាំអីខ្លះ? មានការទទួលខុសត្រូវយ៉ាងម៉េចពេលនុ៎ងបាទ?

**ឆ៖** បាទ ខ្ញុំទៅដល់នៅក្បាលពោធិ៍ហ្នឹងមុនដំបូង ព្រោះអីយើងទៅមុនដំបូង អ្នកអត់បាយហ្នឹងដូចថាមិនដែលអត់ អ្នកធ្លាប់ហូបឆ្អែត អ្នកមិនដែលពិបាក អ៊ីចឹងទៅមុនដំបូងមានអ្នកឈឺច្រើនណាស់ អ៊ីចឹងឈឺ ពេលហ្នឹងអ្នកខ្លះរត់ ប៉ុន្តែក្នុងចំណោមទៅជាមួយខ្ញុំហ្នឹង អ្នករត់២០នាក់ រត់រួចតែម្នាក់ទេ។ ហើយការធ្វើពលកម្មគឺពេលទៅដល់មុនដំបូងគឺថាធ្វើពី ក្រោកពីព្រលឹមអ៊ីចឹង ដល់ម៉ោងដប់មួយ វាឲ្យបាយហូបហើយ។ ដល់យូរទៅម៉ោងមួយដណ្តប់ហ្នឹងក៏គ្មានទាន់បានបាយដែរ រហូតដល់ម៉ោងពីរដណ្តប់ដល់យូរៗទៅវាថាមិនបាច់មើលបាយទេ មើលការងារ បើការងារហើយចាំគិតបាយ អ៊ីចឹងរហូតដល់ម៉ោងពីរ ម៉ោងបី។ អ៊ីចឹងមួយថ្ងៃហ្នឹង ២៤ម៉ោង ខ្ញុំនិយាយ ២៤ម៉ោង មួយយប់មួយថ្ងៃហ្នឹងយើងអាចហូបបានតែពីរដងទេ។ ម៉ោង រយៈពេលម៉ោងបីហ្នឹងយើងហូបម្តង ដល់ក្រោយមកដល់ពេលល្ងាចម៉ោងពីរដណ្តប់យប់ហ្នឹងបានៗហូប។ អ៊ីចឹងគេថាការងារ គេឲ្យមើលការងារ ការស្ទូងដក ការសាបព្រោះធាក់រហាត់ហ្នឹង គេឲ្យមើលទឹកកាលណាបើទឹកពេញអាហ្នឹងចាំហេវបាយ បើកាលណាទឹកមិនទាន់ពេញកុំហេវ។ គេនិយាយតែប៉ុណ្ណឹង។

[១០:៤៦:២៥]

**ស៖** បាទៗសូមអរគុណ។ ចំណុចសំខាន់មួយទៀត លោកពូបានលើកអម្បាញ់មិញ ប៉ុន្តែមិនខ្ញុំមិនទាន់បានចម្លើយ។ ថាពេលដែលយើងឈឺថ្កាត់អីហ្នឹងគេ ប្រើឱសថយ៉ាងម៉េច ឬក៏គេព្យាបាលយើងម៉េច ឬមួយគេ មិនយកចិត្តទុកដាក់អីទាល់តែសោះ?

**ឆ៖** បាទកាលពីសម័យនោះ កាលណាបើយើងឈឺ កាលនៅកន្លែងខ្ញុំហ្នឹង ការដ្ឋានរបស់ខ្ញុំហ្នឹងកាលណាបើយើងឈឺ ហើយយើងហូបបាយបាន គេថាយើងឈឺសតិអារម្មណ៍។ អ៊ីចឹងគេថាហ្នឹងខ្លាំងៗបង្កប់ស៊ីរូងផ្ទៃក្នុងរបស់គេ។ អ៊ីចឹងមនុស្សម្នាក់ៗគ្មានអ្នកណាចង់ឈឺទេ ទោះបីជាឈឺយ៉ាងណាក៏ខំទៅធ្វើការដែរ ដើម្បីឱ្យបានបាយហូបបាទ។ អ៊ីចឹងរឿងពេទ្យ រឿងហ្នឹអី អត់ ខ្ញុំមិនដែលឃើញមានពេទ្យទេនៅក្បាលពោធិ៍ហ្នឹង តែឈឺៗអ៊ីចឹង គ្នាយើងហ្នឹង បើថាវាហត់ហេវខ្លាំងពេក ទៅលបនៅក្នុងព្រៃកក់កោសខ្យល់ឱ្យគ្នាអ៊ីចឹងទៅ។ អត់មានថ្នាំមានសង្កូវអីមកបៀតបៀន ហើយទៅប្រាប់គេៗថាយើងសតិអារម្មណ៍។ ហើយកាលណាសតិអារម្មណ៍ អាហ្នឹងអង្គការមានកន្លែងឱ្យនៅហើយគេប្រាប់ គេនិយាយតែប៉ុណ្ណឹង។

**ស៖** ខ្ញុំចង់ដឹងថាគេប្រើថ្នាំអី បាទ?

[១០:៤៨:០៣]

**ឆ៖** បាទ បើខ្ញុំនៅកងយុវជន សម័យអាពត ខ្ញុំមិនដែលឃើញមានថ្នាំ មានការងារព្យាបាលដូចថាអ្នកជំងឺ អ្នកអី នៅក្នុងកងយុវជនខ្ញុំមិនដែលមានអ្នកទៅដេកពេទ្យទេ ព្រោះអីគេមិនឱ្យទៅដេកពេទ្យ ឬមួយគេមិន ឈឺយ៉ាងណាក៏គេមិនដែលយកទៅព្យាបាលតាមមន្ទីរពេទ្យ ឬមួយតាមគ្លីនិកផ្សេងៗដែរ។ អ៊ីចឹងកាលណាឈឺ បើយើងឈឺ អត់បាយងាប់ហ្នួង ព្រោះអីវា អាហ្នឹងផ្តាច់ការថាអានៅតំបន់ខ្ញុំហ្នឹងគេថា សម័យហ្នឹងគេថា កង់ប្រវត្តិសាស្ត្រ តែវិលៗហើយ តែខ្លាស់បាក់ តែខ្លាស់ជើងបាក់ជើងខ្លាស់ដៃបាក់ដៃ។ អ៊ីចឹងកន្លែងតំបន់ខ្ញុំនៅ គឺស្រុកត្រាំកក់ហ្នឹង ស្ថានភាពតឹងរ៉ឹងណាស់បាទ។

**ស៖** បាទសូមអរគុណ។ ខ្ញុំមានបរិបទមួយទៀត តើលោកពូមាន--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ។ សូមអភ័យទោសចំពោះការរំខាន។ តើ -- លោកប្រធានសូមឱ្យបង្គាប់ឱ្យសាក្សី

និយាយតែ -- រដ្ឋបណ្ដឹងរដ្ឋប្បវេណីនិយាយតែអ្វីដែលគាត់បានឮ បានឃើញតែប៉ុណ្ណោះ។ មិនត្រូវនិយាយថាគេៗគេយ៉ាងដូច្នេះទេ គឺនិយាយតែអំពីព្រឹត្តការណ៍ដែលគាត់បានឃើញដោយផ្ទាល់តែប៉ុណ្ណោះ។ សូមអរគុណ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** បាទសូមអរគុណលោកប្រធាន។ សំណួរខ្ញុំអម្បាញ់មិញខ្ញុំ សួរលោកពូពាក់ព័ន្ធនឹង តើលោកពូមានបងប្អូនជីដូនមួយដែលគេត្រូវជម្លៀសចេញពីភ្នំពេញដែលឬអត់ទេ?

**លោក វី ពៅ៖**

**ឆ៖** បាទ ខ្ញុំមានបងប្អូនជីដូនមួយត្រូវជាពូហ្នឹងពីរនាក់។ អ៊ីចឹងពេលជម្លៀសចេញហ្នឹង ក្រោយថ្ងៃយើងរំដោះហើយ បានដឹងថា បានដឹងទទួលដំណឹងថាគាត់ស្លាប់ គាត់ទៅលើកទ្រូ។ អ៊ីចឹងខ្មែរក្រហមវាចោទប្រកាន់គាត់ថាទៅលួចគេ អ៊ីចឹងគេវាយគាត់ចោល។ ពូហ្នឹងឈ្មោះ ស៊ន ង៉ុក បាទ។ គេយកគាត់ទៅវាយចោលហ្នឹង ក្រោយថ្ងៃរំដោះហើយបានខ្ញុំដឹងបាទ។

[១០:៥០:៤០]

**ស៖** អរគុណ។ ចុះមានក្រុមគ្រួសារណាផ្សេងទៀតអត់ទេ ដែលបងប្អូនពូហ្នឹង?

**ឆ៖** បាទ ក្នុងសម័យប៉ុតពតហ្នឹង ខ្មែរក្រហមហ្នឹង បើតាមការបាត់បង់ ខ្ញុំបាត់បង់តែប្អូនប្រុសមួយទេ។ ពេលខ្ញុំឡើងទៅហ្នឹង ប្អូនខ្ញុំវាអាយុមិនទាន់បាន១ឆ្នាំទេ។ អ៊ីចឹងពេលទៅដល់ហ្នឹង គឺដូចថាគេពង្រាត់និរាសព្រាត់ប្រាសអ៊ីចឹងទៅណា អ៊ីចឹងប្អូនហ្នឹង កាលនោះគេឲ្យយាយៗទទួលបន្ទុកខាងមើលចៅខាងមើលក្មេង អ៊ីចឹងគេដាក់ទៅខាងយាយៗ មិនដឹងវាឈឺដោយប្រការណាមួយខ្ញុំមិនអាចដឹងដែរបាទ។

**ស៖** បាទៗ អរគុណៗច្រើន។ ខ្ញុំមានសំណួរចុងក្រោយមួយ សំណួរចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់ដឹងថានៅពេលដែលក្រោយពីបែក៧៩មក លោកពូបានជួបអ្នកដែលត្រលប់ពីវៀតណាមហ្នឹងបាទ មកហ្នឹងអាចនៅសល់ប៉ុន្មានអីប៉ុន្មានដែរ អាចថាមកហ្នឹង ដូចថា១២០០នាក់គ្រួសារអ៊ីចឹង មកទាំងអស់ហើយក្រោយពី៧៩ហ្នឹង ត្រូវបាត់ពួកគាត់ទាំងអស់ឬមួយនៅសល់ខ្លះ? បាទ សំណួរចុងក្រោយ។

[១០:៥២:១៨]

**ឆ៖** បាទ បើតាមខ្ញុំការឃ្លាំមើល ហើយការពិនិត្យឃើញផ្ទាល់ អ៊ីចឹងពេលយើងផ្លាស់ប្ដូរមកហ្នឹង គឺអ្នកស្រុកនៅភូមិខ្ញុំហ្នឹង វាមានច្រើនណាស់។ អ៊ីចឹងក្រោយពេលថ្ងៃរំដោះហើយ ខ្លះបាត់ទាំងគ្រួសារៗ ខ្លះណានៅសល់តែកូនម្នាក់អ៊ីចឹងទៅ ច្រើនៗគ្រួសារបាទ។ អ៊ីចឹងការដែលវាយកទៅសម្លាប់

ដោយប្រការណា បង្អត់បាយ ឬមួយយកទៅព្យាបាទដោយអំពើអមនុស្សធម៌ផ្សេងៗទៀត ក៏ខ្ញុំមិនដឹងថាគាត់នៅទីកន្លែងណាដែរណ៎ា អាហ្នឹងខ្ញុំអត់ដឹងដែរ។ ប៉ុនក្រោយថ្ងៃរំដោះហើយ ឃើញបាត់មនុស្សច្រើន។

**លោក ឡៅ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

បាទ អរគុណលោកប្រធាន។ សូមគោរពលោកលោកស្រីចៅក្រម។

**ស៖** សូមគោរពលោកដើមបណ្តឹងរដ្ឋប្បវេណី! ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងនៃការិយាល័យសហព្រះរាជអាជ្ញា។ ថ្ងៃនេះ ខ្ញុំមានសំណួរមួយចំនួនចង់សួរឲ្យលោកជួយបញ្ជាក់ដល់អង្គសវនាការទាំងមូល។ ហើយខ្ញុំចាប់ផ្តើមសំណួរដំបូងគឺ លោកបានមានប្រសាសន៍ថានៅពេលដែលលោកមកដល់ប្រទេសកម្ពុជា គឺគេឲ្យលោកទៅរស់នៅក្នុងឃុំខ្ពបត្របែក។ តើជាការត្រឹមត្រូវដែរឬទេ?

**លោក វី ពៅ៖**

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប។ ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

[១០:៥៤:១២]

**លោក វី ពៅ៖**

**ឆ៖** បាទ ជាការពិតណាស់លោកប្រធានបាទ។

**សួរដោយលោក សេង លាង៖**

**ស៖** លោកអាចប្រាប់បានទេថាតើមេឃុំខ្ពបត្របែកហ្នឹងឈ្មោះអ្វី?

**ឆ៖** បាទ បើតាមខ្ញុំដឹង មេឃុំជំនាន់អាពតហ្នឹង គេហៅ តាចំៗ បាទ។

**ស៖** អរគុណ។ នៅតំបន់របស់លោក ៗដែលឮគេហៅឈ្មោះ តាម៉ុក ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ។

**លោក រី ពៅ៖**

**ឆ៖** បាទ បានឮ។ តាម៉ុកហ្នឹង បង-- ត្រូវជាបងប្អូន តាចំ បាទ។

**សួរដោយលោក សេង លាង៖**

**ស៖** តាម៉ុក ជាអ្នកណា?

**ឆ៖** បាទ តាម៉ុក ហ្នឹងកាលពីសម័យនោះ គេហៅប្រធានតំបន់បាទ។

**ស៖** អរគុណ។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក គឺឯកសារ D22/2162 ត្រង់ ERN ជាភាសាអង់គ្លេស 01047835, ERN ជាភាសាខ្មែរ 00546441 រហូតដល់ 42, ERN ជាភាសាបារាំង 01047835-36។ ខ្ញុំសូមដកស្រង់ លោកបាននិយាយថា "បន្ទាប់ពីមកដល់ស្រុកត្រាំកក់ គេបំបែកលោកចេញពីគ្រួសារ ហើយឲ្យទៅធ្វើការនៅក្នុងកងចល័តមួយ។ នៅទីនោះពួកគេបង្ខំឲ្យខ្ញុំធ្វើការយ៉ាងទម្ងន់ដូចជា រែកដីទំនប់ រែកដី ជីប្រឡាយ គ្មានពេលសម្រាក"។ សូមលោកអាចបញ្ជាក់លម្អិតបានទេថា តើនៅពេលដែលលោកទៅធ្វើការនោះ លោកអាចចាំបានទេថា តើគេឲ្យលោកទៅធ្វើការនៅការដ្ឋាននៅកន្លែងណាខ្លះ?

**ឆ៖** បាទខ្ញុំសូមជម្រាបជូនថា កាលពីសម័យនោះ យើងធ្វើតាមតំបន់ ឧទាហរណ៍ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង។ បើយើងទៅក្បាលពោធិ៍ ធ្វើនៅចំណុចក្បាលពោធិ៍ហ្នឹង។ អ៊ីចឹងភូមិសាស្ត្រក្បាលពោធិ៍ហ្នឹង យើងមានដី ឧទាហរណ៍មានចំណុះឲ្យក្បាលពោធិ៍ហ្នឹងមានប៉ុន្មានភូមិ ឬមួយប៉ុន្មានឃុំ ជុំវិញការដ្ឋានហ្នឹង គឺយើងធ្វើទាំងអស់ ចូលរួមទាំងអស់បាទ។

[១០:៥៦:៥៥]

**ស៖** តើនៅក្បាលពោធិ៍ហ្នឹង មានកន្លែងកិនស្រូវដែរឬទេ?

**ឆ៖** បាទសម័យអាពត នៅក្បាលពោធិ៍មានកន្លែងបុកអង្ករ កន្លែងកិនស្រូវ កន្លែងកាលនោះគេធ្វើម៉ាស៊ីនបុកស្រូវដោយដៃ បាទមាន។

**ស៖** អរគុណ លោក។ ឥឡូវនិយាយអំពីការលើកទំនប់ ជីកប្រឡាយវិញ ថាតើក្នុងមួយថ្ងៃ តើលោកជីកដីប្រហែលប៉ុន្មានដែរ?

**ឆ៖** បាទ ខ្ញុំមិនអាចគណនាបាន ឬប្រហែលប៉ុន្មាន ឬទំហំប៉ុន្មានអីប៉ុន្មានទេ ប៉ុន្តែបើយើងរស់នៅក្នុងកងហ្នឹង អាហ្នឹងគេថាអ្នកគោរពអង្គការវិន័យហ្នឹង គឺចេះតែធ្វើអ៊ីចឹងទៅ ធ្វើអត់ដឹងអត់ដឹងថ្ងៃ អត់ដឹងពេលវេលាម៉ោងសម្រាកទេ។ ហើយបើអ្នកណាខុសវិន័យរបស់គេ គឺគេទណ្ឌកម្មឲ្យរែកតែ ៤ម៉ែត្រ ឬ៣ម៉ែត្រអីក្នុងមួយថ្ងៃហ្នឹងឲ្យហើយ អាហ្នឹងគឺត្រូវតែហើយ។

**ស៖** បាទ តើគេមានកំណត់ចំនួនកូតាប៉ុន្មានដែរទេ ដែលត្រូវតែឲ្យគ្រប់ម្នាក់ៗធ្វើហ្នឹង?

[១០:៥៨:៤១]

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនេះ យើងមិនបានសម្រេចឲ្យបានច្បាស់លាស់ លើការកត់សម្គាល់របស់លោកមេធាវី វ៉ិចទ័រ កូប៉េ គាត់បានប្រើពាក្យមួយចង់ឲ្យយើងណែនាំដើមបណ្តឹងរដ្ឋប្បវេណី ឲ្យឆ្លើយឲ្យច្បាស់លាស់ ថាគេហ្នឹងអ្នកណា? ឥឡូវនេះ មិនត្រឹមតែដើមបណ្តឹងរដ្ឋប្បវេណីទេ ភាគីពាក់ព័ន្ធក៏បានប្រើពាក្យ “គេ” មិនដឹងថាអ្នកណាពិតប្រាកដ។ តើលោកអាចតាំងសំណួរឲ្យបានជាក់លាក់ទេ ថ្នាក់ដឹកនាំកម្មាភិបាល មេភូមិ មេយុវជន ឬក៏អ្នកណា ដែលមានការប្រើប្រាស់គាត់ឲ្យការងារនេះ វាប្រសើរជាងឲ្យប្រើពាក្យ “គេ” ដែលវាអត់ដឹងជាក់លាក់ថា ចង់ចង្អុលថាបុគ្គលណាមួយ ឬក៏ក្រុមណាមួយជាក់លាក់នៅក្នុងដំណើរការនៃការដ្ឋានការងារនោះ ឬក៏ទីតាំងដែលដំណើរការសហករណ៍។ សូមរៀបចំសំណួរឲ្យបានល្អ ដើម្បីដើមបណ្តឹងរដ្ឋប្បវេណីរូបនេះឆ្លើយតបសមស្របទៅតាមនុង់ដែរ។ យើងប្រើពាក្យ “គេ” ហើយដល់ពេលគាត់ឆ្លើយតបមកវិញ អាចមក “គេ” ទៅវិញដែរ។ ហើយអ៊ីចឹងរកប្រធានបទ ឬកម្មបទនេះមិនឃើញទេ ថាអ្នកណាច្បាស់លាស់នោះទេ។

[១០:៥៩:៥៤]

**លោក សេង លាង៖**

អរគុណលោកប្រធាន។ ខ្ញុំសុំរៀបចំសំណួរឡើងវិញ។

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំចង់បញ្ជាក់ថា “គេ” នៅទីនេះ គឺសំដៅទៅលើមេដឹកនាំកងចល័តរបស់លោកហ្នឹង ដែលជាអ្នកគ្រប់គ្រងការងារហ្នឹង។ តើមេដឹកនាំកងចល័តហ្នឹង គេមានកំណត់ទេ? កំណត់ថា តើម្នាក់ៗត្រូវមានកូតាប៉ុន្មាន? ត្រូវរែកប្រចាំ សម្រាប់មួយថ្ងៃហ្នឹង?

**លោក រី ពៅ៖**

**ឆ៖** បាទ ខ្ញុំសូមអធ្យាស្រ័យដែរដល់លោកប្រធានបាទ។ ខ្ញុំមិនមែននិយាយដើម្បីដេញដោល ដើម្បីប្រឆាំងទេ។ អ៊ីចឹងការនិយាយស្តី កាលពីសម័យខ្មែរក្រហម វាហៅពួកខ្ញុំសុទ្ធតែ "អាមីង" ទោះបីខ្ញុំចាស់ខ្ញុំក្មេង ឥឡូវខ្ញុំហៅពួកគេ ព្រោះអីវាបាត់បង់យូរហើយ អ៊ីចឹង ខ្ញុំមិនចាំឈ្មោះមេៗវាគ្រប់ទាំងអស់ទេ។ អ៊ីចឹង យើងថា"ពួកគេ" អ៊ីចឹងក៏វាមិនខុសឆ្គងអីដែរបាទ។

**ប្រធានអង្គជំនុំ៖**

លោកចាំស្តាប់សំណួរៗគេសួរអំពីបញ្ហាអី លោកឆ្លើយបញ្ហាហ្នឹង។ ប្រសិនបើសំណួរគេសួរថា ថ្នាក់ដឹកនាំកងចល័ត លោកឆ្លើយតបក្នុងកម្រិតថ្នាក់ដឹកនាំកងចល័ត មេឃុំ ឬក៏មេភូមិ មេកង គឺឆ្លើយតបអ៊ីចឹង។ ហ្នឹងទី១។ ទី២ សំណួរអំមិញគេសួរថា តើគាត់ប្រើពាក្យ "កូតា"។ យើងក៏ពិបាកយល់ដែរ កម្រិតខ្ពស់ពេកនៃភាសា បើយើងថាបរិមាណ ឬក៏ចំណុះដីហ្នឹងប៉ុន្មានម៉ែត្រគូប ប៉ុន្មានការេអ៊ីចឹង នៅក្នុងការធ្វើការដ្ឋានការងារហ្នឹងមួយថ្ងៃហ្នឹង វាអាចស្តាប់បាន។ ប៉ុន្តែលោកឆ្លើយអំមិញគឺមិនត្រូវទេ។

ហើយទី២ សំណួរនេះ សំណួរច្រំដែលផង ព្រោះគាត់បានឆ្លើយហើយថា បរិមាណដែលកំណត់ឲ្យធ្វើហ្នឹងគឺគាត់មិនអាចគណនាបានទេ គណនាបានលើកលែងតែបុគ្គលណាដែលត្រូវមេ ថ្នាក់ដឹកនាំហ្នឹងគេដាក់ពិន័យ ទើបគេកំណត់ថា តម្រូវឲ្យរែកដី ២ម៉ែត្រគូប ឬក៏ ៣ម៉ែត្រគូបក្នុងមួយថ្ងៃអ៊ីចឹង។

សូមរៀបចំសំណួរឲ្យច្បាស់ដើម្បីឲ្យសាក្សីដើមបណ្តឹងរដ្ឋប្បវេណីគាត់ងាយយល់។ ប្រើពាក្យសាមញ្ញបានហើយព្រោះគាត់ជាពលរដ្ឋសាមញ្ញទេ។

**សួរដោយលោក សេង លាង៖**

អរគុណលោកប្រធាន។

**ស៖** ខ្ញុំសូមឆ្លងទៅសំណួរបន្ទាប់ទៀត។ ថានៅពេលដែលលោកធ្វើការនៅក្នុងកងរបស់លោកនោះ តើលោកអាចចាកចេញទៅណាមកណាតាមចិត្តដែលលោកចង់បានដែរឬទេ?

**លោក រី ពៅ៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនថា កាលពីសម័យនោះ អ៊ីចឹងការយើងធ្វើកំពុងពលកម្មនៅក្នុងការដ្ឋានហ្នឹង បើយើងត្រូវបត់ដៃ ឬបត់ជើងអី គេឲ្យយើងជម្រាបមេពួក ឬមេក្រុមរបស់គេ ថាខ្ញុំទៅបត់ជើង ឬមួយបត់ដៃ ហើយរយៈពេលប៉ុន្មាននាទី ឬប៉ុន្មានម៉ោង។ កាលណាបើយើងទៅយូរ ហ្នឹងគេថាយើងសតិអារម្មណ៍។

**ស៖** ចុះបើសិនជាយើងល្មើស តើមានទណ្ឌកម្មណាអាចត្រូវដាក់មកលើយើងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយតបនឹងសំណួរបែបឧបមានវិធីទេ។

**សួរដោយលោក សេង លាង៖**

**ស៖** តើលោកអាចប្រាប់ទេថានៅសម័យ នៅក្នុងកងរបស់លោកហ្នឹងមានអ្នកណាដែលល្មើសចាកចេញទៅណារហេតរហូតដោយគ្មានរាយការណ៍ទៅថ្នាក់លើ?

[១១:០៤:០០]

**លោក វី ពៅ៖**

**ឆ៖** បាទ កាលពីសម័យនោះ សម័យខ្មែរក្រហម គេយកទ្រឹស្ដីមួយគេថា "អង្គការចាត់តាំង"។ បើយើងដើរក្រៅអង្គការចាត់តាំង ក្រៅពីភារកិច្ចដែលគ្មានអង្គការចាត់តាំង អាហ្នឹងគឺគ្មាននរណាប៉ានដើរ។ បើទីតាំងយើង ឧទាហរណ៍ទីតាំងនៅចំណុចណាមួយ អ៊ីចឹងគេដាក់គោលដៅឲ្យដើរចម្ងាយ ១៣០ ម៉ែត្រ ឬ ១០០ម៉ែត្រពីទីតាំងហ្នឹង។ គេអត់មានឲ្យដើរទៅគម្លាតឆ្ងាយទេ។

**ស៖** សំណួររបស់ខ្ញុំចង់បញ្ជាក់ថា តើមាននៅសម័យនោះ តើមានសមាជិកកងចល័តណាម្នាក់ដែលរំលោភទៅលើបំរាមហាមឃាត់របស់ពួកខ្មែរក្រហមដែរឬទេ? ហើយបើមាននោះ តើមានរឿងអ្វីកើតឡើង?

**ឆ៖** បាទ សម័យនោះ ទាំងគេទាំងខ្ញុំ អ៊ីចឹងការគោរពវិន័យរបស់អង្គការចាត់តាំងរបស់គេហ្នឹងគឺគ្មានអ្នកណាប៉ានដើរឆ្វេចឆ្វាចទេ មនុស្សម្នាក់ៗភ័យខ្លាចតែអារឿងស្លាប់ រឿងគេយកទៅសម្លាប់ ឬមួយគេយកទៅដោយសម្ងាត់ ដោយយើងមិនដឹងខ្លួន។ អ៊ីចឹង គឺគ្មានអ្នកណាប៉ានដើរសេរី ប៉ានធ្វើខុសពីគោលការណ៍នៃច្បាប់របស់គេទេបាទ។

**ស៖** តាមដែលខ្ញុំដឹង តាមចម្លើយរបស់លោក លោកបានឆ្លើយថាហូបមិនឆ្អែតទេនៅពេលនោះ តើជាការត្រឹមត្រូវដែរឬទេ? បើហូបមិនឆ្អែត តើមានអ្នកណាតវ៉ា--

[១១:០៥:៥៦]

**ប្រធានអង្គជំនុំ៖**

លោកអត់ទាន់ឆ្លើយផងបាទ។ ឆ្លើយអំពីមិញពីអ្នកហ្នឹងទេ។ ក្នុងអង្គ -- ប្រព័ន្ធភាគីដទៃទៀត អ្នកបកប្រែភាសាក៏មិនទាន់បានស្ដាប់ដែរ។

លោកឆ្លើយតបរង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ។

**លោក វី ពៅ៖**

**ឆ៖** បាទ ជាការពិតណាស់សម័យនោះ។

**សួរដោយលោក សេង លាង៖**

**ស៖** បើហូបមិនឆ្អែត តើមានអ្នកណាម្នាក់តវ៉ាពីបញ្ហានេះដែរឬទេ ជាមួយនឹងអង្គការថ្នាក់លើ?

**ឆ៖** បាទ កាលពីសម័យនោះ ខ្ញុំសូមជម្រាបជូនលោកប្រធានឲ្យបានជ្រាបថា កាលពីសម័យនោះ គ្មានអ្នកណាម្នាក់ប៊ានតវ៉ាទេ។ កាលណាអ្នកណាប៊ានតវ៉ា ប៊ានរឹងរូស គេថាយើងហ្នឹងខ្មាំងក្នុងសហករណ៍។ អ៊ីចឹងរស់អត់បានយូរទេ គឺគេមានវិធានការយកទៅដោយមិនដឹងខ្លួនបាទ។

**ស៖** តាមដែលលោកដឹង តើមានសមាជិកកងចល័តរបស់លោកណាម្នាក់ស្លាប់ដោយសារអត់អាហារដែរឬទេ?

**ឆ៖** បាទ សម័យនោះមានកងយុវជនរបស់ខ្ញុំហ្នឹង នៅអូរក្រូចហ្នឹង មានអ្នកអត់បាយហ្នឹង អត់បាយស្លាប់ហ្នឹងពីរនាក់ដែរ។ អ៊ីចឹងគេបន្តប់បន្លែ គេថាមកពីខ្យល់គ ប៉ុន្តែអ្នកហ្នឹងកាលពីសម័យនោះវាកើត វាត្រូវមុតចប អ៊ីចឹងវាទៅ ចេញទៅជាដំបៅ ទៅជាមហារីក។ អ៊ីចឹងគេឲ្យហូបអត់ឆ្អែតទេ។ កាលណាហូប យើងឈឺហើយហូបបាយ គេថាយើងសតិអារម្មណ៍។ អ៊ីចឹងគេចេះតែបន្ថយៗអាហារ អ៊ីចឹងរហូតដាច់ពោះស្លាប់នៅអូរក្រូចបាទ។

[១១:០៨:០០]

**ស៖** អរគុណលោក ខ្ញុំបន្តទៅសំណួរមួយទៀត តើក្នុងរបបខ្មែរក្រហមនោះ នៅក្នុងតំបន់របស់លោក លោកដែលពាក្យថា "សហករណ៍" ដែរឬទេ?

**ឆ៖** បាទ នៅសម័យអាពត គេបង្កើតជារោងសហករណ៍ ខ្ញុំបានឮបាទ។

**ស៖** លោកដឹងថាសហករណ៍បង្កើតឡើងនៅឆ្នាំណាដែរ?

**ឆ៖** បាទ ក្នុងអំឡុងឆ្នាំណាៗ ខ្ញុំអត់ដឹងទេ ប៉ុន្តែពេលខ្ញុំឡើងទៅរស់នៅសម័យអាពតហ្នឹង គឺមានអ៊ីចឹងតែម្តង សហករណ៍។ បាទ ដូចជាសហករណ៍ត្នោតជុំ សហករណ៍តាមកង តាមកងហាកងរយហ្នឹង គឺមានអ៊ីចឹងតែម្តង។ ការប្រមូលផ្តុំមានសហករណ៍ទាំងអស់។

**ស៖** តើលោកដែលឮគេនិយាយអំពីសហករណ៍គំរូ ឬស្រុកគំរូ អីដែរ?

**ឆ៖** បាទ រាល់ការងារទាំងឡាយហ្នឹង ខ្ញុំអត់បានដឹងទេ ព្រោះអីអាហ្នឹងទាល់តែថ្នាក់ដឹកនាំ

របស់គេបានគេដឹងភូមិណា ឃុំណាជាភូមិគំរូ ហើយដោយឡែកយើងជាអ្នកតូចតាចយើងមិននឹងបានដឹង គេមិនដែលប្រជុំប្រាប់។ គេមិនដែលនិយាយឲយើងដឹងផងបាទ។

[១១:០៨:៤០]

**ស៖** លោកប្រធាន ដើម្បីជាប្រតិចារឹកខ្ញុំសូមអនុញ្ញាតដកស្រង់ឯកសារខ្លីមួយ គឺឯកសារ E3/135 ដែលមានចំណងជើងថា "ទង់បដិវត្ត" ចុះលេខ៦ ខែមីនា ឆ្នាំ១៩៧៧។ ត្រង់ ERN ជាភាសាខ្មែរ00062793 រហូតដល់ 94, ERN ជាភាសាអង់គ្លេស 00446849 រហូតដល់ 50, ERN ជាភាសាបារាំង 00487710 រហូតដល់ 11។ ខ្ញុំសូមដកស្រង់៖ "សំបុត្រជូនទង់ក្រហមកិត្តិយសរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ជូនដល់កម្មាភិបាលយុទ្ធជន យុវនារី ប្រជាកសិករទាំងអស់នៃស្រុកប្រសូត្រ (ភូមិភាគបូព៌ា) ស្រុកកំពង់ត្រឡាចលើ (ភូមិភាគបស្ចិម) និងស្រុកត្រាំកក់ (ភូមិភាគនិរតី)"។ សំណួរតទៅទៀតរបស់ខ្ញុំៗចង់ឲ្យបញ្ជាក់ថា តើនៅសម័យហ្នឹងលោកមានដឹងថា មានមេដឹកនាំខ្មែរក្រហមណាទៅទស្សនកិច្ចស្រុករបស់លោកដែរឬទេ?

**ឆ៖** បាទ តាម នៅក្នុងការដ្ឋានខ្ញុំធ្លាប់ឃើញ តាម៉ុក ហ្នឹងគាត់ឧស្សាហ៍ -- គាត់មកចំនួនពីរដងតាំងពីសម័យនោះគាត់មកពិនិត្យការដ្ឋានបាទ។

**ស៖** គាត់មកពិនិត្យការដ្ឋាន។ លោកដឹងឆ្នាំទេ គាត់មកពីឆ្នាំ -- នៅឆ្នាំណា?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយៗ តប។

**លោក រី ពៅ៖**

**ឆ៖** ឆ្នាំ១៩៧៧ គាត់មកត្រពាំងគុលបាទ។

**សួរដោយលោក សេង លាង៖**

**ស៖** ក្រៅពី តាម៉ុក តើមានអ្នកណាមកជាមួយគាត់ដែរ? លោកអាចស្គាល់ទេ?

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតប។

**លោក រី ពៅ៖**

**ឆ៖** បាទក្នុងនោះមានមេកង មេឃុំរបស់ពួក តាម៉ុក ហ្នឹង។

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំឈានចូលដល់ប្រធានបទមួយទៀត គឺការប្រព្រឹត្តចំពោះអតីតទាហានលន់នល់ និងមន្ត្រី និងទាហានលន់នល់។ លោកអាចប្រាប់បានទេថាតើ នៅក្នុងចំណោមប្រជាជននៅក្នុងស្រុកត្រាំកក់របស់លោកហ្នឹង តើនៅសម័យប៉ុលពតនោះ លោកមានដឹងថាតើពួកខ្មែរក្រហមមានព្យាយាមកំណត់អត្ត-សញ្ញាណថា អ្នកណាជាមន្ត្រី អ្នកណាជាទាហាននៃរបបលន់ នល់ដែរឬទេ?

[១១:១៣:១៣]

**ឆ៖** បាទ ក្នុងរឿងនេះ ខ្ញុំអត់ដឹងទេ លោកប្រធាន។

**ស៖** ឥឡូវបែរមកលើ ខ្ញុំចង់សួរបញ្ជាក់លោកទៅលើឯកសារមួយ លោកប្រធានខ្ញុំមានបំណងជូនឯកសារមួយដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ឯកសារនេះគឺឯកសារក្នុងរឿង សំណុំរឿង ០០២/០២ ឯកសារ E3/2917 ដែលមាន ERN ជាភាសាខ្មែរ 00079090, ERN ជាភាសាអង់គ្លេស 00742890 និង ERN ជាភាសាបារាំង 00810574។ តើខ្ញុំអនុញ្ញាតដែរ?

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក សេង លាង៖**

**ស៖** លោកសាក្សីឯកសារនេះ គឺជា --អ៉ំ! លោកដើមបណ្តឹងរដ្ឋប្បវេណី ឯកសារនេះគឺជាសេចក្តីរាយការណ៍បញ្ជាក់ជម្រាបជូនអង្គការស្រុក ដែលផ្ញើមកពីឃុំពពេល។ ខ្ញុំសូមឲ្យលោកមើលចំណុចទី១ ដែលមានគូរក្រហមក្នុងក្រឡោនទី១ ហ្នឹង។ ខ្ញុំសូមអានជូនលោកតែម្តង "ប្រជាជនកម្ពុជាក្រោម និងប្រជាជនដែលឃ្លូនដូរមកមាន ៦៤គ្រួសារ ចំនួនមនុស្ស២២៨នាក់"។ លិខិតនេះបញ្ជាក់ការបរិច្ឆេទឆ្នាំ៧៧។ តើៗលោកអាចបញ្ជាក់បានទេថាតើការដោះដូរខាងលើនេះគឺជាការដោះដូរលើកទី២ ដែលលោកបាននិយាយនោះឬក៏យ៉ាងណា? ឬក៏ថាការដោះដូរនោះគឺជាការដោះដូរលើកទី៣ឬក៏លើកទី៤អី បើតាមដែលលោកអាចដឹង?

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនថា--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

[១១:១៦:០៦]

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនលោកប្រធានថា ក្រោយពីពេលដែលខ្ញុំបានឡើងមកដល់ទឹកដីកម្ពុជា។ អ៊ីចឹងបញ្ហាដោះដូរលើកទី១ -- លើកទី១ខ្ញុំដឹងថាបានមកដល់ ពេលខ្ញុំមកដល់ហ្នឹង មកដល់ដីខ្មែរហើយដូចបិទមុខអ៊ីចឹង ខ្ញុំអត់ដឹងស្ថានភាពផ្លាស់ប្តូរអី ខ្ញុំអត់មានដែលបានដឹងទៀតទេ អត់បានដឹងបន្តទៀតទេ។ មិនដឹងជាមកថ្ងៃណាខែណា ហ្នឹងអត់បានដឹងទេ ដឹងតែពេលខ្ញុំមកហ្នឹង ព្រោះអីពេលយើងមកអ៊ីចឹង មកដល់ហ្នឹងមិនមែនដើរទៅរហេតរហូតណាបាទ។

**ស៖** អរគុណៗលោក ខ្ញុំទៅ ដោយសារពេលវេលា ខ្ញុំចង់ទៅសំណួរមួយទៀត ប្រហែលជាសំណួរចុងក្រោយរបស់ខ្ញុំបាទ។ សូមលោកមើលទៅបន្ទាប់លេខ២ ដែលមានគូសក្រហមក្នុងប្រអប់ហ្នឹងដែរ ខ្ញុំសូមអានជូនលោកថា៖ "គ្រួសារទាហានដែលត្រូវអង្គការកម្ទេច និងសម្លាប់មាន១០៦គ្រួសារ មានចំនួន៣៩៣នាក់"។ ខ្ញុំចង់សង្កត់ធ្ងន់ទៅលើពាក្យនេះថាពាក្យ"ទាហាន"។ ពាក្យទាហាននោះគឺសំដៅទៅលើក្រុមណាមួយ? ជាទាហានរបស់អតីតលន់នល់ ឬក៏ទាហានរបស់ពួកខ្មែរក្រហម លោកអាចបញ្ជាក់បានដែរទេ នៅពេលដែលគេប្រើពាក្យថា"ទាហាន"?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១១:១៨:00]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមឲ្យលោកតំណាងសហព្រះរាជអាជ្ញាពិនិត្យទៅលើអត្ថបទនេះសាជាថ្មីដោយពាក្យជាភាសាខ្មែរ ខ្ញុំឃើញថាពាក្យថា"ស្លាប់" មិនមែន "សម្លាប់"ទេ។ ហើយម៉្យាងទៀត ដើមបណ្តឹងរដ្ឋប្បវេណីនេះប្រហែលជាមិនមានសមត្ថភាពយល់ដឹងពីបញ្ហានេះទេ។ បាទ សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន ខ្ញុំក៏មានការជំទាស់ផងដែរ។ សាក្សីមិនបានដឹងអំពីឯកសារនេះ។ ហើយខ្ញុំគិតថាដូចជាគ្មានហេតុផលអីដែលយើងត្រូវសាកសួរសាក្សីអំពីឯកសារនេះឡើយ។ ដំបូងបំផុត ចាំបាច់យើងត្រូវសួរថាតើសាក្សីដឹងអំពីបញ្ជីនេះឬក៏អត់ មុននឹងយើងសួរបន្តទៅទៀត។ ហេតុដូច្នេះ ខ្ញុំសូមជំទាស់ចំពោះការសួរសំណួរបែបនេះ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំសូមបំពេញបន្ថែមទៅនឹងការជំទាស់ៗរបស់លោក កូប៉េ។ មិនត្រឹមតែប៉ុណ្ណឹងទេ គឺថាអត់មានមូលដ្ឋាននៅក្នុងការប្រើឯកសារនេះទៅទៀតផង ពីព្រោះថាសហព្រះរាជអាជ្ញាបានសួរសំណួរមុនពាក់ព័ន្ធទៅនឹងការដឹងឮរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទៅលើគោលនយោបាយចំពោះទាហាន ហើយគាត់ឆ្លើយអត់ដឹងទេ។ អ៊ីចឹង មិនឃើញមានហេតុផលដែលគាត់នៅបន្តសួរសំណួរបែបហ្នឹងទេ ពីព្រោះថាដើមបណ្ដឹងរដ្ឋប្បវេណីគាត់បញ្ជាក់ហើយថា គាត់ដូចជាមិនដឹងអ្វីសោះពាក់ព័ន្ធនឹងប្រធានបទនេះនោះ។

[១១:១៩:៣៤]

**លោក សេង លាង៖**

លោកៗប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំសួរសំណួរនេះគ្រាន់តែចង់ដឹងថាតើគាត់មានធ្លាប់ឮថាពាក្យថា“ទាហាន”ហ្នឹង នៅៗក្នុងរបបខ្មែរក្រហមហ្នឹង តើពាក្យ“ទាហាន”នៅក្នុងតំបន់គាត់ហ្នឹង ពួកខ្មែរក្រហមប្រើគឺសំដៅលើក្រុមណាមួយ? ដោយសារថាឯកសារនេះវាមានពាក្យ“ទាហាន” នៅក្នុងហ្នឹង ហើយខ្ញុំបានជាបង្ហាញហើយ ខ្ញុំសួរពាក់ព័ន្ធទៅនឹងបញ្ហាហ្នឹងតែម្ដង។

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី មិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ ព្រោះលោកបានឆ្លើយរួចហើយថាលោកបានអត់ដឹងពាក់ព័ន្ធនឹងបញ្ហាអតីតទាហាន លន់ នល់ នោះទេ។

**លោក សេង លាង៖**

អរគុណលោកប្រធាន ខ្ញុំសូមអស់សំណួរត្រឹមហ្នឹង ហើយសូមទុកពេលវេលាសម្រាប់សហសេវិករបស់ខ្ញុំ។ សូមអរគុណ។

[១១:២០:៤០]

**សួរដោយលោក សាលីម ណាកចាវ៉ានី៖**

**ស៖** ខ្ញុំសូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រម។ ខ្ញុំសូមគោរពលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនសួរទៅខាងលោកជាភាសាអង់គ្លេស។ លោកដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងពាក្យសុំតាំងខ្លួនរបស់លោក ព្រមទាំងចម្លើយរបស់លោក ចំពោះអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ព្រមទាំងសក្ខីកម្មរបស់លោក លោកនិយាយអំពី ពងទឹក ភូមិ។ នៅក្នុង

ចម្លើយរបស់លោកជាមួយនឹងសហចៅក្រមស៊ើបអង្កេត លោកនិយាយអំពីព្រៃតាកុក គឺឯកសារមានលេខ E319.1.22 ដែលចម្លើយទាំងពីរ គឺចម្លើយ២៤ និង ៣៨។ តើលោកអាចបញ្ជាក់បានទេ ថាតើគេចាត់តាំងឲ្យលោកទៅធ្វើការនៅភូមិទាំងពីរ គឺ ភូមិពងទឹក និងភូមិព្រៃតាខាប ដែរឬទេ? តើស្ថានភាពនៅទីនោះ វាមានលក្ខណៈបែបណាដែរ?

**លោក រី ពៅ៖**

**ឆ៖** បាទកាលពីសម័យនោះ ខ្ញុំផ្លាស់ប្តូរពីភូមិស្ទឹងទៅ ពីឃុំខ្ពបត្របែកទៅនៅឃុំសំរោង ហ្នឹង ខ្ញុំបានទៅនៅភ្លូរដី ធ្វើស្រែធ្វើប្រឡាយនៅភូមិពងទឹក។ ភូមិពងទឹក និង ភូមិព្រៃតាខាបវានៅក្បែរគ្នា។ បាទ។ វានៅគម្លាតពីគ្នា គឺជាប់គ្នាតែម្តង មិនឃ្លាតឆ្ងាយពីគ្នាទេ។ អ៊ីចឹង គេឲ្យចុះទៅភ្លូររាស់ក្នុងភូមិហ្នឹង និងជីកប្រឡាយរែកដីនៅទីតាំងហ្នឹងបាទ។

**ស៖** សូមអរគុណ។ ថាតើទីតាំងទាំងពីរហ្នឹង នៅឆ្ងាយប្រហែលប៉ុន្មានដែរពីក្រាំងតាចាន់?

**ឆ៖** បាទ បើខ្ញុំគិតប៉ុន្មានចម្ងាយ ប្រហែលជា៥០០មែត្រ ពីក្រាំងតាចាន់ ឃុំព្រៃតាខាប ហើយ និងក្រាំងតាចាន់ហ្នឹង គម្លាតគ្នាប្រហែលប៉ុណ្ណឹងបាទ ៥ ឬ៦០០ មែត្រ ហ្នឹងបាទ។

[១១:២៣:០៦]

**ស៖** ឥឡូវនេះ ខ្ញុំនឹងផ្លាស់ប្តូរទៅប្រធានបទថ្មីមួយ។ លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកគិតថាខ្លួនលោកផ្ទាល់ហ្នឹង គឺជាខ្មែរកម្ពុក្រោមឬទេ?

**ឆ៖** បាទ បើខ្ញុំនិយាយពីអត្តសញ្ញាណខ្ញុំពិតប្រាកដ គឺខ្ញុំខ្មែរៗកម្ពុជា ប៉ុន្តែខ្ញុំនៅក្បែរជាយដែន បាទ។ ស្រុកកំណើតគឺនៅខ្មែរ ប៉ុន្តែដល់ពេលស្រុកកើតសង្គ្រាម អាហ្នឹងខ្ញុំភៀសខ្លួនរត់ទៅនៅប្រទេសវៀតណាម បាទ។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។

**លោក សាលីម ណាសចាវ៉ានី៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារជូនដើមបណ្តឹងរដ្ឋប្បវេណី គឺឯកសារដែលលោកបានទទួលស្គាល់គឺ E3/2428 ។ ឯកសារនេះគឺរាយនាមជាគ្រួសារ៥៤ ដែលមកពីកម្ពុជាក្រោម ហើយរស់នៅក្នុងភូមិសំរោង គឺនៅជិតកន្លែងដែលដើមបណ្តឹងរដ្ឋប្បវេណីរស់នៅ។ ហើយភូមិទាំងនោះ មានដូចជា តាស្មាន , ប៉ែន មាស , តាសោម , ព្រៃគគី និង អង្គតាធិល ជាដើម។ល។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន ដាក់បង្ហាញឯកសារនេះ ជូនដើមបណ្តឹងរដ្ឋប្បវេណីឯកសារជាភាសាខ្មែរ។

សូមលោកប្រធានអនុញ្ញាត។

[១១:២៤:៣៦]

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក សាលីម ណាកចាវ៉ានី៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកអាចពិនិត្យមើលទៅលើខ្លឹមសារនៃឯកសារនេះបាន។ នៅពេលដែលលោកពិនិត្យរួចរាល់ហើយ សុំលោកប្រាប់ថា តើលោកស្គាល់ឈ្មោះខ្មែរក្រោមណាមួយនៅក្នុងបញ្ជីនេះដែរឬទេ?

**លោក រី ពៅ៖**

**ឆ៖** បាទ ឈ្មោះទាំងអស់នេះ សរសេរអក្សរតូចៗពេក ខ្ញុំមើលមិនច្បាស់ មិនឃើញ។

**ស៖** អត់បញ្ហាទេលោកដើមបណ្ដឹងរដ្ឋប្បវេណី។ នៅខាងឆ្វេងដៃរបស់លោក លោកឃើញឈ្មោះដូចជា ថាច់ និង ថៅ ដែលជានាមត្រកូល។ តើលោកស្គាល់ដូចជា ថាច់ និង ថៅ នេះដែរឬទេ?

**ឆ៖** បាទ កាលពីសម័យមុននៅតាមព្រំដែន មិនមែនថាត្រឹមសម័យខ្មែរក្រហមទេ កាលពីមុនមក បើតាមខ្ញុំដឹងអ្នកនៅតាមព្រំដែន នៅក្បែរព្រំដែន គេច្រើនតែយកត្រកូល ថាច់ ត្រកូល ថៅ ហ្នឹងដាក់ជានាម-គោត្តនាម បាទ។

**ស៖** សូមអរគុណលោក។ នៅក្នុងបញ្ជីគ្រួសារ៥៤គ្រួសារនេះ គ្រួសារ៣០គ្រួសារមកពីភូមិតាសោម ហើយ ១២គ្រួសារមកពីអង្គតាងិល។ តើលោកចាំដែរឬទេថា ភូមិទាំងអស់នេះ គឺជាភូមិដែលមានខ្មែរក្រោមជាច្រើនរស់នៅ នៅពេលដែលលោករស់នៅនៅក្នុងឃុំសំរោងជាមួយគ្នានោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងកុំទាន់អាលឆ្លើយតប។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំជំទាស់ដោយសារដំបូងសាក្សីត្រូវសាកសួរអំពីបញ្ជីសិន។ បន្ទាប់មកសួរអំពីសមាជិកគ្រួសារ៣៤, ៣៣ ដូច្នេះគាត់ត្រូវការនេះ --

**លោក សាលីម ណាកចាវ៉ានី៖**

ជាការឆ្លើយតបលោកប្រធាន គឺថាដើមបណ្ដឹងរដ្ឋប្បវេណីស្ថិតនៅក្នុងកងចល័ត គាត់ធ្វើដំណើរ

នៅគ្រប់ទីកន្លែងនៅគឺនៅឃុំសំរោង ហើយគាត់បានទៅដល់ភូមិពីរ ដែលខ្ញុំបានបញ្ជាក់។ ដូច្នេះគាត់អាចប្រាប់ ប្រហែលជាគាត់អាចដឹងអំពីសមាជិកគ្រួសារខ្មែរក្រោមដែលរស់នៅក្នុងភូមិទាំងអស់នោះ។ ប្រសិនបើគាត់ដឹង ហ្នឹងជាការដឹងផ្ទាល់របស់គាត់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់ បាទសេចក្ដីជំទាស់ហ្នឹងមិនសមស្របទេ ហើយដោយសារដើមបណ្ដឹងរដ្ឋប្បវេណីនេះ មានមូលដ្ឋានសមស្របដែលនឹងអាចយល់ដឹងអំពីបញ្ហានេះបាន ព្រោះគាត់បាននៅភូមិនោះមួយរយៈពេលនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។

ដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបនឹងសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

[១១:២៨:២៥]

**លោក រី ពៅ៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនថា ឈ្មោះដែលមាននៅក្នុងនេះ គឺខ្ញុំអត់បានចងចាំងទេ ព្រោះអីកាលពីសម័យនោះអ្នកខ្លះអាយុប្រហាក់ប្រហែលខ្ញុំ ហ្នឹងបានខ្ញុំនៅស្គាល់ អ្នកខ្លះជួនក្មេង កាលនៅតាមកងនានាអ៊ីចឹង វាអត់មាន ជួនទៅ១០នាក់អ៊ីចឹង ជួនមិនបាននៅជាមួយគ្នាម្នាក់ផង ជួនបែកទៅនេះទៅនោះ។ អ៊ីចឹងអាស្រ័យលើការចាត់តាំងរបស់មេកង។

**សួរដោយលោក សាលីម ណាសចាវ៉ានី៖**

**ស៖** បញ្ជីបានរៀបរាប់ពីស្ត្រីមួយរូបមកពីភូមិពងទឹក ដែលលោកបានបញ្ជាក់ថាលោកនៅទីនោះ ហើយនៅក្នុងបញ្ជីទី២៧ ឈ្មោះថា នាង ស្រី។ តើលោកស្គាល់ឈ្មោះ នាង ស្រី នេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនម្ដងទៀតថា បញ្ហាអ៊ីចឹងខ្ញុំរៀបរាប់ប្រាប់ថា ពេលសម័យនោះប្រុសនៅដោយប្រុស ស្រីនៅដោយស្រី ហ្នឹងការរស់នៅតាមវ័យ។ អ៊ីចឹង វ័យយុវជននៅកន្លែងយុវជន វ័យកុមារនៅតាមកងកុមារ វ័យចាស់នៅតាមចាស់ វ័យកសិករនៅតាមកសិករអ៊ីចឹងបាទ។ នៅរៀងៗគ្នា មិនមែនមនុស្ស ១០០នាក់ហ្នឹងឲ្យខ្ញុំស្គាល់ គឺមិនអាចទេ ជួនវាវ័យខុសគ្នាអ៊ីចឹង មិនអាចស្គាល់បានទេបាទ។

**ស៖** អត់បញ្ហាទេលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរចុងក្រោយមួយទៀត។ យើងឃើញថាបញ្ជីហ្នឹងបែងចែកគ្រួសារខ្មែរក្រោមទៅជាបីប្រភេទ គឺប្រភេទទី១ គឺហៅថាប្រភេទទី១ ប្រភេទទី២ និងប្រភេទទី៣។ ពាក្យខ្មែរគេសរសេរថា “ប្រភេទទី១ ប្រភេទទី២ និងប្រភេទទី៣”។ ផ្នែក

ទៅតាមអ្វីដែលលោកធ្លាប់ឮ ដឹងនៅពេលនោះ ថាលោកធ្លាប់ឮពាក្យថា ប្រភេទទី១ ទី២ ទី៣ នេះដែរឬទេ?

[១១:៣០:២៥]

**ឆ៖** បាទ កាលពីសម័យនោះ គេបែងចែកអ៊ីចឹង។ កម្ពុជាក្រោម និង១៧មេសា និងមូលដ្ឋាន។ អ៊ីចឹង ការបែងចែកហ្នឹង ទោះបីមកភ្នំពេញក៏ដោយ ថាអ្នកភ្នំពេញទៅមូលគ្នាទាំងអស់ គឺអត់ អត់មានទេ គឺទៅតាមវ័យៗរៀងខ្លួន។ អ៊ីចឹងបើអ្នកណាដូចថាអាយុប្រហាក់ប្រហែលខ្ញុំហ្នឹង អាហ្នឹងជូនគេរៀបនៅជាមួយខ្ញុំទៅ ហើយបើអ្នកខុសពីហ្នឹង អាយុប្អូន ឬអាយុតិចជាង គេនៅតាមកងដោយឡែក។ ស្ត្រីនៅដោយស្ត្រី បុរសនៅដោយបុរស រៀងៗគ្នាអ៊ីចឹង មិនអាចស្គាល់បានអស់ទេ។

**ស៖** សូមអរគុណ។ ដោយសារខ្ញុំនៅសល់ពេលបន្តិចបន្តួច ខ្ញុំមានសំណួរខ្លីៗចំនួនពីរ។ នៅក្នុងចម្លើយរបស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺ E3/119.1.22 នៅចម្លើយ ៦១ និង៦២ លោកបានបញ្ជាក់ថា នៅក្នុងឆ្នាំ៧៨ លោកបានឃើញក្រុមខ្មែរក្រោម៣០ក្រុម ត្រូវបានគេចង ហើយត្រូវបណ្ដើរទៅក្រាំងតាចាន់។ តើលោកអាចរៀបរាប់អំពីហេតុការណ៍នេះបានដែរឬទេ ដើម្បីឲ្យតុលាការបានជ្រាប។

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនថា ពេលខ្ញុំផ្លាស់ប្ដូរទៅកន្លែងពីភូមិស្ទឹងទៅ នៅភូមិពងទឹកហ្នឹង ពេលខ្ញុំទៅ ខ្ញុំបានឃើញមែន ប៉ុន្តែមិនដឹងគេយកទៅពីណាទេ។ អ៊ីចឹងឃើញគេចងហ្នឹងចំនួនប្រហែល ៣០នាក់ គេចងចេញ កាលនោះអ្នកដែលនៅក្នុងឃុំសំរោងហ្នឹង អ៊ីចឹងគេបណ្ដើរតាមថ្នល់ប្រឡាយពួកខ្ញុំមកពីអ៊ីចេះ គេទៅពីអ៊ីចេះ ហើយវែកបញ្ច្រាសមុខគ្នាអ៊ីចឹង។ អ៊ីចឹងការគេយកទៅសម្លាប់នៅកន្លែងណា ឬមួយក៏យកទៅធ្វើទារុណកម្មនៅកន្លែង អាហ្នឹងក៏ខ្ញុំមិនអាចសន្និដ្ឋានបានដែរបាទ។ ប៉ុន្តែគ្រាន់តែដឹងថា ក្រោយមក គ្រាន់តែដឹងថា ចំណុចក្រាំងតាចាន់ហ្នឹង គឺកន្លែងពិឃាដមនុស្ស បាទ ធ្វើឃាដមនុស្ស។

[១១:៣៣:០០]

**ស៖** តើលោកចាំដែរឬទេថា ហេតុអ្វីបានជាគេចាប់ពួកទាំងអស់នោះ?

**ឆ៖** បាទ កាលពីសម័យនុ៎ង គេបែងចែកអ៊ីចឹង គេបែងចែកប្រជាពលរដ្ឋជាបីប្រភេទ ហើយអ៊ីចឹងកាលណាអ្នកណាធ្វើវិទ្ធង្សនា ឧទាហរណ៍ថាយើងធ្វើអីខុស ឬមួយយើងមិនទៅធ្វើការ យើងមានសតិអារម្មណ៍ សម័យនោះ គេចោទយើងថា ពិសេសមេកង មេឃុំ មេក្រុមហ្នឹង គេចោទយើងថា យើងយួនបាទ។ គេចោទយើងថា “អាយ៉ងយួន”, ជាសេ.អ៊ី.អា របស់យួន, ជាភ្នាក់ងាររបស់យួន អ៊ីចឹងកាល

ពីសម័យនោះ គេចោទប្រកាន់យើងអ៊ីចឹងបាទ។

**ស៖** សូមអរគុណលោក ហើយសំណួរចុងក្រោយរបស់ខ្ញុំ គឺនិយាយទៅនឹងចម្លើយដែលលោកផ្ដល់ទៅដល់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឯកសារ E3/19.1.22 នៅចម្លើយ៥៨ លោកបានបញ្ជាក់ថា៖ មានតែខ្មែរក្រហមប្រាំមួយនាក់ប៉ុណ្ណោះ ដែលនៅរស់រួមទាំងលោកផង។ ខ្ញុំចង់សួរលោកឲ្យបញ្ជាក់ទៅលើចំណុចនេះ ថាតើលោកមានន័យយ៉ាងម៉េច នៅពេលលោកនិយាយថា អ្នកមកពីកម្ពុជាក្រោមជាមួយខ្ញុំទាំងអស់នៅតែប្រាំមួយនាក់តែប៉ុណ្ណោះ។ ថាតើលោកចង់និយាយពីអ្នកដែលគេបញ្ជូនមកត្រាំកក់ឆ្នាំ៧៦ ឬក៏លោកចង់និយាយអំពីចំនួនប្រជាជនដែលនៅសល់ក្នុងឃុំរបស់លោកក្រោយរបបហ្នឹងបានដួលរលំ តើលោកអាចបញ្ជាក់បានដែរឬទេ តើលោកមានន័យយ៉ាងម៉េចដែលថា នៅរស់តែប្រាំមួយនាក់ប៉ុណ្ណោះនោះ?

[១១:៣៤:៤៧]

**ឆ៖** បាទ អាហ្នឹងបើខ្ញុំជម្រាបជូនលោកប្រធានឲ្យបានជ្រាបថា អ្នកដែលទៅរស់នៅជាមួយខ្ញុំហ្នឹងណ៎ា អ្នកមកពីវៀតណាមហ្នឹង មកពីវៀត-- មកនៅខ្មែរហ្នឹង ពេលយើងរំដោះហើយ អាហ្នឹងអ្នកនៅជិតៗខ្ញុំហ្នឹងនៅសល់ប្រាំមួយនាក់បាទ។ ខុសពីហ្នឹងមិនដឹងគេទៅនៅទីណា ឬមួយគេយកទៅសម្លាប់អាហ្នឹងខ្ញុំអត់បានដឹងទេ។ អ៊ីចឹងនៅក្បែរខ្ញុំហ្នឹងវាមានប្រាំមួយនាក់ទាំងខ្ញុំ ឥឡូវហ្នឹងបាទ។

**លោក សាលីម ណាកចាវ៉ានី៖**

សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះការឆ្លើយតបរបស់លោក។ លោកប្រធានខ្ញុំសូមបញ្ចប់ហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ត្រលប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយនិងសាមសិបនាទី។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាល

សវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៦ នាទី ដល់ម៉ោង ១៣:៣២នាទី)*

[១៣:៣២:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ មុននឹងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី សូមសួរទៅចៅក្រម តើអស់លោក លោកស្រីមានសំណួរអ្វីចង់សួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? បើមានសូមអញ្ជើញបាទ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរសួរបន្តពាក់ព័ន្ធទៅនឹងព្រឹកមិញលោកឆ្លើយទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិថា លោកស្ថិតនៅសហគមន៍កម្ពុជាក្រោម ព្រឹកមិញនេះលោកក៏បានឆ្លើយព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងកន្លែងទីកន្លែងកំណើត លោកបញ្ជាក់ថាលោកកើតនៅប្រទេសកម្ពុជា ក៏ប៉ុន្តែនៅពេលដែលគេស្តាប់ចម្លើយលោកគឺឯកសារ១នោះគេសួរលោកអំពីថ្ងៃខែឆ្នាំកំណើតនោះ លោកបានឆ្លើយថាលោកបានកើតនៅភូមិរំពាយ ភូមិ -- សូមទោសភូមិអំពាយស្វាយ ឃុំឡេទ្រី ស្រុកស្វាយទង។ ហើយឥឡូវនេះបញ្ជាក់ថាឥឡូវនេះ ឃុំអាន -- ខេត្តអានយ៉ាង កម្ពុជាក្រោម។ អ៊ីចឹងខ្ញុំចង់ដឹងថាតើលោកកើតនៅកម្ពុជាក្រោម ឬក៏កើតនៅប្រទេសកម្ពុជា? ឯកសារដែលខ្ញុំនិយាយអម្បាញ់មិញនេះគឺលេខ E319.1.22។

**លោក រី ពៅ៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំកើតនៅកម្ពុជាលើបាទ ប៉ុន្តែភៀសខ្លួនទៅនៅប្រទេសវៀតណាម។

**ស៖** អ៊ីចឹងកន្លែងដែលខ្ញុំនិយាយអម្បាញ់មិញ ហើយនិងកន្លែងដែលលោករត់គេចទៅនៅវៀតណាមហ្នឹង កន្លែងណាមួយ? ខ្ញុំចង់ដឹងថានៅពេលដែលលោកចាកចេញប្រទេសកម្ពុជាហ្នឹង លោករត់គេចទៅវៀតណាមហ្នឹងទៅដល់កន្លែងណា?

**ឆ៖** បាទទៅនៅ ភូមិអំពាយស្វាយ ឃុំឡេទ្រី ស្រុកស្វាយទង បាទ។

**ស៖** អ៊ីចឹងលោកចាត់ទុក ពីព្រោះថាលោកៗបានរត់គេចទៅកម្ពុជាក្រោម អ៊ីចឹងលោកចាត់ទុកថាលោកជាជនជាតិកម្ពុជាក្រោម ដោយសារគ្រួសារលោកមានដើមកំណត់នៅកម្ពុជាក្រោម ឬក៏យ៉ាងម៉េច? ហេតុអ្វីបានជាលោកចាត់ទុកខ្លួនឯងថាលោកជាកម្ពុជាក្រោមនោះ?

**ឆ៖** បាទ ខ្ញុំមិនដែលជម្រាបជូនថាខ្ញុំកម្ពុជាក្រោមទេ ខ្ញុំបានប្រាប់ថាកម្ពុជាលើជារៀងរហូត បាទ ប៉ុន្តែខ្ញុំរត់ទៅនៅប្រទេសវៀតណាម។

**ស៖** នៅពេលដែលលោកត្រឡប់មកកម្ពុជាវិញ នៅឆ្នាំ១៩៧៦ បើតាមអ្វីដែលលោកនិយាយកាលព្រឹកមិញនោះ គឺថាពេលនុ៎ងគេចាត់ទុកលោកថាជាកម្ពុជាក្រោម គឺពួកខ្មែរក្រហមចាត់ទុកលោកជាកម្ពុជាក្រោម។ អ៊ីចឹងចំពោះលោកខ្លួនឯងផ្ទាល់នោះ លោកចាត់ទុកខ្លួនឯងជាកម្ពុជាក្រោមទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបជូនថា សម្រាប់ខ្លួនខ្ញុំផ្ទាល់ខ្ញុំមិនដែលថាខ្ញុំខ្មែរកម្ពុជាក្រោមទេ ប៉ុន្តែសម័យប៉ុលពត ពេលខ្ញុំឡើងទៅ -- គេយកខ្ញុំទៅរស់នៅជាមួយគេ ៗហៅខ្ញុំខ្មែរកម្ពុជាក្រោម។ គេហៅខ្ញុំថាយួនអ៊ីចឹងហ្មង។

[១៣:៣៧:៣២]

**ស៖** តើលោកធ្លាប់ឮគេប្រើពាក្យថា "ក្បាលយួនខ្លួនខ្មែរ" ហើយគេ -- អ្នកណាដែលគេហៅថាអ៊ីចឹង គេហៅក្បាលយួនខ្លួនខ្មែរហ្នឹង? លោកធ្លាប់ឮពាក្យហ្នឹងទេ ហើយគេហៅហ្នឹងគេសំដៅលើអ្នកណាដែរ?

**ឆ៖** បាទបើតាមកាលពីសម័យប៉ុល ពត នោះ អ្នកដែលហៅខ្ញុំហ្នឹង គឺនិន្នាការខ្មែរក្រហមហ្នឹង គឺមេកង ពួកសកម្មជនរបស់ខ្មែរក្រហមហ្នឹង មានមេកង មានមេក្រុមរបស់វាហ្នឹង វាអ្នកហៅដាក់ឈ្មោះពួកខ្ញុំអ៊ីចឹង។

**ស៖** នៅពេលដែលលោកនិយាយថាយើង លោកសំដៅលើ មនុស្សទាំងអស់ដែលគេចាត់ទុកថាខ្មែរកម្ពុជាក្រោមឬក៏យ៉ាងម៉េច គឺថាអ្នកទាំងអស់ហ្នឹងហើយគេចាត់ទុកថាក្បាលយួនខ្លួនខ្មែរ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទជាការពិតណាស់លោកប្រធាន បាទ។

**ស៖** អ៊ីចឹងតើគេមានរបៀបផ្សេងទៀតក្នុងការហៅអ្នកដែលមកពីកម្ពុជាក្រោមទេ?ឧទាហរណ៍ ដូចជាគេហៅថា “ពួកបញ្ញើក្អែក” ឬក៏“ពួកគិញយួន” គេមានហៅអ៊ីចឹងទេ គេមានហៅផ្សេងពីៗយួនទេ គេមានហៅពាក្យអីផ្សេងទេ សំដៅលើខ្មែរកម្ពុជាក្រោមនៅពេលហ្នឹង?

**ឆ៖** បាទ កាលពីដំបូងគេមិនទាន់បានហៅពួកយួនទេ ដល់ពេលយើងទៅនៅបានយូរគេ -- កាលពីមុនដំបូងគេហៅថា “ប្រជាជនបញ្ញើ” និង “ត្រៀម” ដល់យូរៗទៅគេឈប់ហៅអ៊ីចឹង គេឈប់ប្រើពាក្យហ្នឹង គេហៅតែ “អាយ៉ងយួន” គេហៅអ៊ីចឹង។ “ក្បាលយួនខ្លួនខ្មែរ” គេហៅអ៊ីចឹង។

[១៣:៤០:០០]

**ស៖** ហើយគេមានចោទខ្មែរក្រោមថាជា គិញយួនទេ? គេមានចោទអ៊ីចឹងទេ?

**ឆ៖** បាទ កាលសម័យនោះ គេថាយើង សេ.អ៊ី.អា របស់យួន ឬមួយគិញយួនអ៊ីចឹងទៅ។ ស្រេចតែគេថាស្រេចគេហៅ។

**ស៖** តើលោកមានចាំថានៅពេលដែលលោកមកដល់ប្រទេសកម្ពុជា គេមានសុំឲ្យលោកសរសេរប្រវត្តិរូបទេ? ឬក៏លោកចាំទេថា នៅពេលដែលមនុស្សគ្រប់គ្នាមកពីវៀតណាមដល់កម្ពុជានោះ គេប្រាប់ឲ្យសរសេរប្រវត្តិរូប លោកមាននឹកឃើញ មានចាំថាមានអ៊ីចឹងទេ?

**ឆ៖** បាទ កាលខ្ញុំឡើងមក គេអត់បានឲ្យសរសេរឲ្យខ្ញុំអី ដឹងតែមក មកដល់គេអត់មានឲ្យបញ្ជាក់ពីអាសយដ្ឋានថានៅឯណាៗ អត់ទេព្រោះអីគេដឹងថាយើងយកមកពីយួនហើយ។

**ស៖** តើលោកមានចាំទេថាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនៅពេលណាមួយនោះ គេបានស្នើឲ្យខ្មែរកម្ពុជាក្រោមត្រលប់ទៅផ្ទះរបស់ខ្លួនវិញ? មានគេធ្លាប់ស្នើអ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំចងចាំថាកាលខ្ញុំរស់នៅកម្ពុជាក្រោម គេបានយកយួនយកទៅដូរយកខ្មែរយើងពីក្រោមមកវិញក្នុងអំឡុងឆ្នាំ១៩៧៦បាទ។

**ស៖** ចំណុចនេះខ្ញុំយល់ហើយ ក៏ប៉ុន្តែសំណួរដែលខ្ញុំចង់ដឹងគឺខុសពីហ្នឹងទេ។ ខ្ញុំចង់ដឹងថាខ្មែរដែលមកពីកម្ពុជាក្រោមហើយនោះ ហើយមករស់នៅៗតំបន់ដូចដែលលោកនៅនោះ។ តើនៅពេលណាមួយនោះ គេមានប្រាប់ថាឲ្យខ្មែរកម្ពុជាក្រោមហ្នឹងត្រលប់ទៅនៅកម្ពុជាក្រោមវិញ? អ៊ីចឹង ខ្ញុំចង់ដឹងថាតើខ្មែរក្រហមមានបានប្រាប់ខ្មែរក្រោមដែលមកពីវៀតណាមហ្នឹងថាឲ្យទៅនៅកម្ពុជាក្រោមវិញ។ មានៗអ៊ីចឹងទេ?

[១៣:៤៣:០៧]

**ឆ៖** បាទ កាលនោះ គេ មេកង មេក្រុមគេបានសួរបញ្ជាក់យើងដែរថា បងប្អូនណាចង់ទៅស្រុកគេឲ្យទៅ ប៉ុន្តែដល់ពេលនេះ ចាស់ៗម្ដាយឪពុករបស់ខ្ញុំ គាត់ដឹងថាហាម -- អ្នកដែលគេធ្លាប់ទៅមុន គេហាមថាតែគេឲ្យទៅស្រុកកុំចង់ទៅ តែទៅងាប់ហើយ។ អ៊ីចឹងពេលនោះ ដល់យើងដឹងខ្លួនមុនអ៊ីចឹង អត់ -- ទោះបីជាគេឲ្យទៅនៅឯណាក៏អត់ទៅដែរ នៅតាមដែលអង្គការប្រមូលផ្ដុំរបស់គេ។

**ស៖** អ៊ីចឹងមានន័យថាការស្នើឲ្យទៅនៅកម្ពុជាក្រោមនោះគឺមានមែន។ ក៏ប៉ុន្តែគ្មានអ្នកណាហ៊ានទៅទេ គេដឹងថាអាហ្នឹងគឺជាការដាក់អន្ទាក់របស់ខ្មែរក្រហម។ លោកចង់មានន័យថាអ៊ីចឹងមែនទេ?

**ឆ៖** បាទ ន័យរបស់គេអ៊ីចឹងបាទ។ កាលណាយើងចង់ -- គេប្រាប់ គេសួរនាំថាយើងទៅស្រុកចង់ទៅស្រុកវិញ បើយើងថាទៅ ដឹងតែស្លាប់ហើយសម័យនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ ឥឡូវនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា។

[១៣:៤៤:២៧]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក សួន វិសាល៖**

សូមគោរពលោកប្រធាន។ ខ្ញុំបាទឈ្មោះ សួន វិសាល ខ្ញុំជាមេធាវីការពារក្ដីឲ្យលោក នួន ជា។

**ស៖** សូមជម្រាបសួរលោក វី ពៅ។ ហើយខ្ញុំសួរលោកមួយចំនួនទាក់ទងទៅនឹងអត្តសញ្ញាណរបស់លោកដែលលោកទើបបានបញ្ជាក់អំម្បាញ់មិញនេះ។ ខ្ញុំចង់ដឹងថា នៅពេលដែលលោកទៅនៅភៀសខ្លួនពីប្រទេសកម្ពុជាយើងទៅនៅប្រទេសវៀតណាម តើនៅពេលនោះលោកមានបានដូរអត្តសញ្ញាណរបស់លោកជាខ្មែរទៅជាវៀតណាមទេ?

**លោក វី ពៅ៖**

**ឆ៖** បាទ នៅពេលនោះអត់បានដូរទេបាទ។ ខ្ញុំនៅទៅនៅជំរំជនភៀសខ្លួន អត់បានដូរអត្តសញ្ញាណទេបាទ។

**ស៖** សូមអរគុណ។ ចំណុចមួយទៀតខ្ញុំចង់ដឹងផងដែរ ថាតើនៅអ្នកដែលនៅជំរំភៀសខ្លួនទាំងអស់នោះ តើគេចាត់ទុកលោកជាខ្មែរៗដែលយើងប្រជាពលរដ្ឋខ្មែរ ឬក៏ជាប្រជាពលរដ្ឋកម្ពុជាក្រោមហើយមានសញ្ជាតិជាយួន?

**ឆ៖** បាទ កាលពីសម័យនោះ –សម័យ លន់ នល់– យើងភៀសខ្លួនពីកម្ពុជាទៅ អ៊ីចឹងគេមិនទាន់ចាត់ទុកយើងថា ជាជនជាតិយួន ឬជនជាតិវៀតណាមអីទេ គេហៅថាជនភៀសខ្លួន។ អ៊ីចឹង យើងខ្មែរ សញ្ជាតិជាខ្មែរ នៅតែខ្មែរដដែលបាទ អត់មានទាន់បញ្ចូលអត្តសញ្ញាណណាមួយទៅជនជាតិគេដទៃទេបាទ។

[១៣:៤៦:៣៩]

**ស៖** សូមអរគុណ។ នៅកន្លែងដែលលោករស់ហ្នឹង តើមានខ្មែរកម្ពុជាក្រោមដែលមានសញ្ជាតិជាៗវៀតណាមនៅទីនោះទេ?

**ឆ៖** បាទ មានបងប្អូនខ្មែរកម្ពុជាក្រោមភូមិនៅជាប់នុងច្រើន បាទ។

**ស៖** បាទសូមអរគុណ ខ្ញុំសូមសួរបន្តទៀត។ នៅពេលដែលលោកត្រូវបានរដ្ឋាភិបាលបញ្ជូនមកវិញ តើគេមានបានបញ្ជូនជនជាតិខ្មែរកម្ពុជាក្រោមមកទេ?

**ឆ៖** បាទពេលនោះ គេបញ្ជូនតែនៅ -- ខ្មែរនៅក្នុងកន្លែងដែលជនភៀសខ្លួនមកទេ បាទ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថា នៅពេលដែលលោកចេញមកនុងក្នុងនាមប្រជាពលរដ្ឋខ្មែរដែលរត់ភៀសខ្លួន មិនមែនជាជនជាតិវៀតណាមកម្ពុជាក្រោមអីទេ។ ហើយលោកមកវិញនេះក្នុងនាមដែលលោកត្រឡប់មកស្រុកកំណើតវិញ មិនមែនលោកចាកចេញពីស្រុកកំណើតរបស់លោកទេ។ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

សូមឆ្លើយលោក វី ពៅ! អំមិញ អត់បានឆ្លើយទេ ឆ្លើយអំមិញ ក្បាលមីក្រូហ្វូនអត់ប្រតិបត្តិការទេ។

**លោក វី ពៅ៖**

**ឆ៖** បាទពេលនោះ ជាការពិតណាស់ លោកប្រធានបាទ។

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមសួរទៅចំណុចមួយទៀតទាក់ទងនឹងការរៀបការ។ នៅពេល

លោកមកវិញ លោកបានបញ្ជាក់ប្រាប់អង្គសវនាការថាលោកបានចូលធ្វើការនៅកងយុវជន។ ក្នុងរយៈពេលប៉ុន្មានឆ្នាំដែលលោកធ្វើជាកងយុវជនមុនពេលឆ្នាំ១៩៧៩នោះ តើមានយុវជនប៉ុន្មាននាក់ដែលបានរៀបការនៅពេលដែលលោកធ្វើការជាមួយនោះ នៅក្រុមជាមួយលោកនោះបាទ?

**ឆ៖** បាទនៅក្នុងយុវជនពួកខ្ញុំនោះ កាលនុង់ទើបតែចាប់ផ្តើមជាលើកដំបូង ប៉ុន្តែវាមានភាពបរាជ័យដោយសារខ្ញុំឈឺ។ អ៊ីចឹង ការរៀបចំអាពាហ៍ -- ការ--

**ស៖** បាទៗប្រហែលជាលោកច្រឡំសំណួរហើយបាទ។ ខ្ញុំចង់មិនឱ្យវែងឆ្ងាយ ព្រោះពេលវេលាយើងមានកំណត់ណាស់។ ខ្ញុំចង់សួរថានៅកងរបស់លោក តើមាន ក្នុងរយៈពេលប៉ុន្មានឆ្នាំហ្នឹង តើមានប៉ុន្មាននាក់ដែលគេរៀបការ?

[១៣:៤៩:៥០]

**ឆ៖** បាទខ្ញុំសូមបញ្ជាក់ជូនថា ពីមុនមកវាមាន ប៉ុន្តែកងរៀងៗខ្លួន ដូចខ្ញុំប្រាប់អ៊ីចឹង។ នៅក្នុងឃុំជាមួយគ្នា ប៉ុន្តែពេលនោះ គេកងពិសេស កងគេថាកងពិសេសរបស់គេហ្នឹងណា។ ដូចអ្នកមានអាយុច្រើនជាងខ្ញុំ ឬមួយគេមានវ័យចំណាស់ ហ្នឹងគេរៀបមុនហ្នឹង មិនមែនកងរបស់ខ្ញុំហ្នឹង។ អ៊ីចឹងពេលរៀបអាពាហ៍ពិពាហ៍ ខ្ញុំដែលមិនមែនជាកងហ្នឹង មិនបានទៅរៀបគេទេ។ គេអត់ឱ្យចូលរួមទេបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបន្ថែមបន្តិចទៀតទាក់ទងរឿងហ្នឹង។ ខ្ញុំចង់ដឹងថា ឥឡូវក្នុងរយៈពេលដែលលោកនៅហ្នឹង តើមានបានឃើញគូស្រករណាខ្លះដែលរៀបការ ដោយខ្លួនលោកផ្ទាល់បាទ?

**ឆ៖** បាទ ខ្ញុំនៅមានឃើញពីរគូដែរនៅក្នុងឃុំរបស់ខ្ញុំសព្វថ្ងៃហ្នឹង ដែលខ្មែរក្រហមបានឱ្យប្តេជ្ញាហើយ មានជាប់លាប់គ្នារហូតមកដល់សព្វថ្ងៃហ្នឹង គឺមានពីរគូដែរបាទ។

**ស៖** អរគុណ។ ដូច្នេះ ក្នុងពេលដែលលោកចេញពីប្រទេសវៀតណាមមករស់នៅប្រទេសកម្ពុជានៅក្នុងកងហ្នឹង រហូតដល់ឃុំរបស់លោករស់នៅហ្នឹងគឺ លោកបានឃើញតែពីរគូតែប៉ុណ្ណោះ។ បាទ ខ្ញុំចង់បញ្ជាក់ឡើងវិញប៉ុណ្ណឹង បាទ។

**ឆ៖** បាទ ខ្ញុំនិយាយដែលអ្នកនៅជាប់លាប់នឹងគ្នា មិនបានដាច់ដោចគ្នាហ្នឹង នៅសល់ពីរគូ។ ខុសពីហ្នឹង អ្នកប្តេជ្ញាមុនៗហ្នឹង ខ្ញុំមិនបានទៅកន្លែងគេប្តេជ្ញាទេ ប៉ុន្តែគ្រាន់តែដឹងថាគាត់បានប្តេជ្ញានៅសម័យអាពតដែរ ក្រោយថ្ងៃរំដោះហើយ គេដាច់លះលែងគ្នាអស់ហើយបាទ។

**ស៖** ខ្ញុំចង់បញ្ជាក់ឡើងវិញបន្តិច ប្រហែលជាលោកមិនយល់សំណួររបស់ខ្ញុំ។ ខ្ញុំចង់ដឹងថា តើ

នៅក្នុងរយៈពេលដែលលោករស់នៅកងហ្នឹង ហើយលោកបានឃើញការរៀបការផ្ទាល់ភ្នែករបស់លោកតែម្តង។ បានន័យថាយើងឃើញផ្ទាល់ តើមានចំនួនប៉ុន្មានគូ? អ៊ីចឹងលោកសូមបញ្ជាក់ឡើងវិញបន្តិចបាទ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប។

**លោក រី ពៅ៖**

**ឆ៖** បាទ ពេលនោះពេលគេរៀបអាពាហ៍ពិពាហ៍ហ្នឹង ខ្ញុំអត់បានចូលរួមទេ ប៉ុន្តែគ្រាន់តែក្នុងមេឃុំគេហ្នឹង គេបានប្រកាសប្រាប់ថា ថ្ងៃទីប៉ុណ្ណោះៗ ខែនេះ ត្រូវរៀបចំប្តេជ្ញាចិត្តចំនួន ១០ ឬ ២០គូអ៊ីចឹង។ អាហ្នឹងដឹង យើងអាចដឹង ប៉ុន្តែអត់បានចូលរួម។

[១៣:៥២:៥៥]

**សួរដោយលោក សួន វិសាល៖**

**ស៖** ដូច្នេះការដឹងរបស់លោកទាក់ទងនឹងការរៀបការហ្នឹងគ្រាន់តែឮគេថាតែប៉ុណ្ណោះ មិនបានឃើញដោយផ្ទាល់ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ នៅកងខុសគ្នាគេអត់ឲ្យចូលរួមទេ ប៉ុន្តែក្រោយមកគេប្រជុំផ្សព្វផ្សាយប្រាប់ដែរ។ មេកងតាមកងហ្នឹង គេប្រជុំប្រាប់ថា “នែ៎! នៅកងនេះៗអ៊ីចឹង បានរៀបប្តេជ្ញាចិត្តចំនួនប៉ុណ្ណោះគូៗ” ហ្នឹងមេកងប្រាប់ដែរបាទ។ គេប្រជុំប្រាប់ ហ្នឹងគេហៅថាប្រជុំជីវភាពរបស់គេប្រចាំថ្ងៃហ្នឹង ប្រជុំទិតៀនស្វ័យទិតៀនហ្នឹង អ៊ីចឹងគេប្រាប់យើងដែរ។ គេឲ្យយើងជួយតាមដានគូណារៀបហើយត្រូវគ្នា មិនអ្នកណាខុសគ្នា អ្នកណាមិនស៊ីចុះដំណេកជាមួយគ្នា គេឲ្យយើងជួយតាមដានគេទៀត ដែលផ្ទះយើងកងយើងនៅក្បែរហ្នឹងគេឲ្យឃ្លាំមើល កងដែលដាក់ទីតាំង--

**ស៖** បាទៗ សូមអរគុណ ព្រោះលោកហាក់ដូចជាមិនឆ្លើយចំសំណួររបស់ខ្ញុំសោះ ប្រហែលជាមិនយល់សំណួរ ឬក៏យ៉ាងម៉េច។ ខ្ញុំចង់គ្រាន់តែបញ្ជាក់ទេថា តើលោកអ្វីដែលលោកបានដឹងហ្នឹង ដឹងតែតាមគេទេ មិនបានឃើញផ្ទាល់ភ្នែកទេ។ លោកយល់ពីពាក្យ “ផ្ទាល់ភ្នែក”ទេ?

**ឆ៖** បាទ មិនបានឃើញផ្ទាល់ភ្នែកទេបាទ។ គ្រាន់តែដឹង ហើយឮគេប្រជុំផ្សព្វផ្សាយប្រាប់។

**ស៖** សូមអរគុណបាទ។ ខ្ញុំចង់រំឭកលោកឡើងវិញបន្តិច នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០។ ខ្ញុំចង់ដកស្រង់សម្តីរបស់លោកបន្តិច លោកបានមកដាក់ពាក្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ

ការិយាល័យការពារជនរងគ្រោះ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណី។ ឯកសារលេខ D2221620 ហើយឯកសារជាភាសា -- ERN ជាភាសាខ្មែរ គឺ 00579113, ជាភាសាអង់គ្លេស គឺ 00585343។ ខ្ញុំសូមដកស្រង់ហើយលោកផ្ទៀតស្តាប់មើលថា តើអ្វីដែលលោក នៅពេលនុំងលោកបាននិយាយអ៊ីចឹង ឬក៏អត់។ "នៅឃុំសំរោង រូបខ្ញុំឃើញដោយផ្ទាល់ភ្នែកនូវការរៀបការដោយបង្ខំចំនួន ៣៤គូតែម្តង"។ តើលោកបាននិយាយអ៊ីចឹងមែនទេ?

[១៣:៥៥:៥៨]

**ឆ៖** ពេលនោះ ខ្ញុំអត់បាននិយាយទេ។ ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំគ្រាន់តែប្រាប់ថា ការរៀបអាពាហ៍ -- ប្តេជ្ញាចិត្តហ្នឹងចំនួនប៉ុណ្ណេះគូៗ។ ប៉ុន្តែខ្ញុំមិនបានឃើញទេ ប៉ុន្តែអ្នកកត់ត្រាមិនដឹងកត់ដោយរបៀបណាខ្ញុំមិនដឹងដែរ។

**ស៖** អ៊ីចឹងមានន័យថា អ្វីដែលលោកនិយាយកាលពីថ្ងៃនុំងមិនត្រឹមត្រូវទេ។ មានអ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាការពិតណាស់បាទ។ ខ្ញុំគ្រាន់តែបានប្រាប់ថា នៅក្នុងភូមិអង្គរលាយ ឃុំសំរោងហ្នឹង គេបានរៀបអាពាហ៍ពិពាហ៍ចំនួន៣៤គូ ប៉ុន្តែខ្ញុំអត់បានចូលរួមទេ។ ខ្ញុំបាននិយាយអ៊ីចេះ។

**ស៖** សូមអរគុណ ខ្ញុំទៅប្រធានបទមួយទៀតបាទ។ ទាក់ទងនឹងការធ្វើការនៅសហករណ៍កាលពីព្រឹកមិញលោកបានឆ្លើយនៅចំពោះមុខអង្គសវនាការថា ក្រុមការងាររបស់លោក និងអ្នក១៧ គឺធ្វើការធ្ងន់ជាងអ្នកមូលដ្ឋាន។ ខ្ញុំចង់ដឹងថា តើនៅពេលនោះ តើអ្នកមូលដ្ឋានគេធ្វើអីបានជាលោកចាត់ទុកថាគេធ្វើការស្រាលជាងលោក?

**ឆ៖** បាទ បានខ្ញុំចាត់ទុកថា ពួកខ្ញុំជន១៧មេសា និងប្រជាជនមកពីវៀតណាម ធ្វើការធ្ងន់មកពីពួកខ្មែរក្រហម ភ្នាក់ងាររបស់ខ្មែរក្រហមមានមេកង មេក្រុមហ្នឹង គេគ្រាន់តែដើរមើលយើង បញ្ជាយើងទេបាទ។ អ៊ីចឹង គេអត់មានចេញកម្លាំងពលកម្មញើសឈាមអីឲ្យហត់នឿយទេ គេចាំតែបញ្ជាយើង ឬមួយគេយកទោសយើងទេ។

[១៣:៥៨:១៥]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងលោក អ្វីដែលលោកសន្និដ្ឋានហ្នឹង គឺសំដៅទៅលើមេកងរបស់លោកម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ មិនសំដៅទៅលើប្រជាពលរដ្ឋទូទាំងឃុំ ដែលអ្នករស់នៅហ្នឹងទេ។ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

ដូចជាសាក្សីមិនបានឆ្លើយថាខ្លួនសន្និដ្ឋានទេ។ ខ្លួនដឹងប៉ុណ្ណឹង ការដឹង និងការសន្និដ្ឋានអត្ថន័យខុសគ្នាឆ្ងាយណាស់។ លោកមេធាវីកែសម្រួលនូវពាក្យប្រយោគដែលលោកមេធាវីប្រើតាំងសំណួរនេះឲ្យបានត្រឹមត្រូវ។

[១៣:៥៨:៤៥]

**លោក សួន វិសាល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងដូរសំណួរផ្សេងទៀតបាទ។

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទ ខ្ញុំចង់សួរឡើងវិញថា នៅ -- តើលោកមានបានឃើញប្រជាពលរដ្ឋផ្សេងទៀត នៅក្នុងឃុំរបស់លោកហ្នឹងធ្វើការដូចលោកឬទេ ឬក៏ធ្វើការផ្សេងពីលោក?

**លោក រី ពៅ៖**

**ឆ៖** អ៊ីចឹងខ្ញុំសូមគោរពសេចក្តីថា កាលពីសម័យខ្មែរក្រហមគ្មានជនណាម្នាក់ទំនេរទេ ឲ្យតែប្រជាពលរដ្ឋអ្នកដែល១៧ ឬអ្នកមកពីយួនហ្នឹង ដោយឡែកតែពួកមូលដ្ឋានហ្នឹង គឺគេជាមេរបស់យើង គេដឹកនាំច្រមុះយើងទាំងអស់ កុំថាឡើយតែកូនក្មេងតូច ឬមួយចាស់ជរា ក៏គេនៅមានសិទ្ធិជាងយើងដែរ។ បាទ ខ្ញុំសូមជម្រាបឲ្យបានជ្រាបអ៊ីចឹង ព្រោះអីអ្នក -- ឥឡូវបើខ្ញុំនិយាយទៅ អ្នកទាំងអស់អាយុវ័យៗប្រហែលខ្ញុំច្រើនណាស់ ដែលដឹងពីរបបហ្នឹង។ អ៊ីចឹងបើឲ្យខ្ញុំរឿងខ្មែរក្រហម ខ្ញុំនិយាយអត់ចប់ទេ។ រយៈពេលពេលខ្លីដែលគេត្រួតត្រាប្រទេសជាតិហ្នឹង។ អ៊ីចឹង៣ឆ្នាំ ៨ខែ ២០ថ្ងៃ យកមកនិយាយ ៣០ឆ្នាំ ៣៣ឆ្នាំ ក៏មិនអស់រឿងដែរបើ--

[១៤:០០:១២]

**ប្រធានអង្គជំនុំ៖**

លោកៗដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយនឹងសំណួរ តបនឹងសំណួរ លោកមិនគប្បីធ្វើអត្ថាធិប្បាយលើសពីភាពចាំបាច់នៃការឆ្លើយតបទៅនឹងសំណួរនោះឡើយ។ លោកស្តាប់សំណួរឲ្យបានហើយឆ្លើយតបទៅភាពចាំបាច់និងពេញលេញចំពោះសំណួរបានហើយ បើពុំដូច្នេះទេនោះ គឺលោកនឹងមានបញ្ហាប្រឈមដោយខ្លួនឯងកាលណាលោកអត្ថាធិប្បាយវែងឆ្ងាយហួសពីក្របខ័ណ្ឌនៃភាពចាំបាច់ឆ្លើយតបទៅនឹងសំណួរ។ ស្តាប់សំណួរ ហើយបើស្តាប់មិនបានសូមឲ្យគេសួរសាជាថ្មីម្តងទៀត។

សូមបន្តសំណួរលោកមេធាវី!

**សួរដោយលោក សួន វិសាល៖**

**ស៖** បាទសូមអរគុណ ខ្ញុំទៅសួរទៅប្រធានបទមួយទៀតបាទ។ កាលពីព្រឹកមិញលោកបាន លើកឡើងអំពីការដែលលោកឃើញមិត្តភក្តិរបស់លោកឈ្មោះ ចាន់ ត្រូវបានគេសម្លាប់។ តើ ចាន់ នោះ មានឈ្មោះពេញរបស់គាត់យ៉ាងម៉េចដែរ?

**លោក រី ពៅ៖**

**ឆ៖** បាទ រឿងជីតារបស់គេខ្ញុំមិនស្គាល់ទេ ខ្ញុំស្គាល់តែឈ្មោះ ចាន់ អ៊ីចឹងតែម្តងបាទ។

**ស៖** តើលោក ចាន់ នោះនៅធ្វើការក្នុងកងជាមួយលោក ឬក៏នៅកន្លែងផ្សេងក្នុងភូមិផ្សេងនៅ ជិតលោក?

**ឆ៖** បាទ មុនពេលបាត់ខ្លួនហ្នឹង លោក ចាន់ ហ្នឹងនៅជាមួយខ្ញុំនៅកងជាមួយគ្នា ប៉ុន្តែពេលគាត់ បាត់ខ្លួនក៏នៅអ្នកនៅក្នុងកងហ្នឹងក៏អត់ដឹងដែរស្មានតែគាត់ទៅនេះ ទៅណា ព្រោះអីសម័យនោះអ្នកខ្លះឈឺ អ៊ីចឹងទៅ អត់ដឹងអ៊ីចឹងទៅ អ្នកខ្លះទៅបត់ដៃបត់ជើងអ៊ីចឹង ទៅដួលនៅក្នុងព្រៃក៏មានដែរ។ អ៊ីចឹងបានខ្ញុំ មិនអាចដឹងអារឿងគេយកទៅវ៉ៃ យកទៅធ្វើទារុណកម្មហ្នឹងដែរ ទាល់តែឃើញអ៊ីចឹងបានដឹងតែម្តង។

[១៤:០២:១៧]

**ស៖** មុនពេលលោកឃើញនោះ តើលោកបាត់គាត់ពីក្រុមការងារ ឬកន្លែងរបស់លោកនៅហ្នឹង តើប៉ុន្មានថ្ងៃហើយ?

**ឆ៖** បាទ ការបាត់ប៉ុន្មានថ្ងៃៗខ្ញុំអត់ដឹងទេ ព្រោះអីយើងនៅសម័យនោះគ្រាន់តែម៉ោងបួន ឬ ម៉ោងបីហ្នឹងតែគេវាយជួង ដឹងតែយើងហ្នឹងរហ័សដៃរហ័សជើងហើយ ចប-បង្គី ទៅហើយ អត់មាននៅ ពិនិត្យអាណាបាត់អាណាបង់អី អត់បានទៅពិនិត្យទេ អាហ្នឹងមេកងគេៗអ្នកនៅត្រួតពិនិត្យខាងក្រោយ យើងៗដឹងតែទៅៗការដ្ឋានធ្វើការហើយបាទ។

**ស៖** តើលោកមានបានចាំបានទេ ថាតើនៅរដូវណាដែរនៅពេលហ្នឹង ដែលគេ គាត់លោកបាន ឃើញគេហ្នឹងតើនៅខែណា ឆ្នាំណា ឬក៏រដូវណាដែរ?

**ឆ៖** បាទ ខ្ញុំអត់ចាំខែថ្ងៃ អត់ចាំរដូវកាលទេ ព្រោះអីសម័យខ្មែរក្រហមយើងមិនដឹងថ្ងៃពុធ ថ្ងៃ អង្គារ ថ្ងៃព្រហស្បតិ៍ ថ្ងៃសុក្រអីទេ ដឹងតែថ្ងៃណាក៏ថ្ងៃបុណ្យដែរ គេហៅអ៊ីចឹង។ គឺថ្ងៃណាក៏ថ្ងៃពលកម្ម ដែរ អ៊ីចឹងអត់មាននរណាម្នាក់ដឹងថ្ងៃសុក្រ ថ្ងៃសៅរ៍ ថ្ងៃអីទេបាទ។

**ស៖** តើនៅពេលនោះជារដូវប្រាំង ឬក៏រដូវវស្សា? លោកប្រហែលជាលោកអាចកំណត់ចាំបាន ព្រោះរដូវភ្លៀងរដូវវស្សាមានភ្លៀង រដូវប្រាំងវាំងស្ងួតអីអ៊ីចឹង តើរដូវណាដែរ?

[១៤:០៤:00]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗឆ្លើយ!

**លោក រី ពៅ៖**

**ឆ៖** បាទ ពេលនោះគឺបើខ្ញុំដឹងខែយើងស្ទូងដកហ្នឹងនៅសម័យអាពត។ អ៊ីចឹងប្រហែលជារដូវវស្សា ខែធ្វើស្រែបាទ។

**សួរដោយលោក សួន វិសាល៖**

**ស៖** តើនៅពេលដែលលោកឃើញនោះ នៅតើនៅទីតាំងកន្លែងណាដែរ? ចម្ងាយប៉ុន្មានដែលពីកន្លែងអ្នកលោកធ្វើការ?

**ឆ៖** បាទ ខ្ញុំមិនបានប៉ាន់ប្រមាណរឿងចម្ងាយទេ ប៉ុន្តែថ្ងៃនោះខ្ញុំដាក់គោមួយនឹម អ៊ីចឹងគោវាស៊ីៗស្មៅដើរទៅអ៊ីចឹងទៅ វាសំដៅទៅព្រៃហ្នឹង អ៊ីចឹងខ្ញុំក៏រត់ទៅដេញគោ ដល់ទៅដេញគោហ្នឹងក៏វាស្រែក វាថា “ទៅប្រាប់ម្តាយខ្ញុំផង ខ្ញុំស្លាប់ហើយ” ខ្ញុំក៏ក្រឡេកទៅភាំងខ្លួនឯង ភ័យផង អីផងក៏ដេញគោមកវិញ។ ហើយគេប្រាប់ខ្ញុំថា “ទៅឲ្យលឿនកុំនៅយឺតយ៉ាវ” ហើយអ៊ីចឹង ខ្ញុំក៏ប្រញាប់ប្រញាល់ដែរ ព្រោះអីសម័យអាពត កាលណាវាឃើញដឹងថាស្លាប់ហើយ អត់មាននៅកន្លែងទីតាំងសម្លាប់របស់គេ យើងប៊ានទៅលូកលាន់ទៅបៀតទៅអី។ ហើយខ្ញុំទៅដំបូងទៅនៅនោះ មុនដំបូងអត់ដឹងថាហ្នឹងក្រាំងតាចាន់ មិនដឹងទីតាំងរបស់ឈ្លប របស់ទ័ពគេ អត់មានដឹងទេ ព្រោះអីវានៅជាប់ភូមិក្បែរៗ ហ្នឹងមានភូមិច្រើនដែរ នៅក្បែរហ្នឹង កន្លែង--

[១៤:០៥:៤៩]

**ប្រធានអង្គជំនុំ៖**

លោក រី ពៅ ចាំ -- រំឭកសំណួរម្តងទៀត។ ចាំស្តាប់សំណួរឲ្យបានច្បាស់ ហើយឆ្លើយតបកម្រិតត្រឹមភាពចាំបាច់ពេញលេញ តបទៅនឹងសំណួរបានហើយ កុំឲ្យឆ្លើយចាកវែងឆ្ងាយពេកណ៎ា។ នឹងមានសំណួរច្រើនរាប់រយទៀតសួរលោក។

**សួរដោយ លោក សួន វិសាល៖**

**ស៖** បាទខ្ញុំសូមសួរបន្តទៀត។ នៅពេលដែលលោកឃើញនោះ តើមានព្រៃជិត ឬក៏នៅកណ្ដាលវាលស្រែ?

**លោក រី ពៅ៖**

**ឆ៖** បាទ ពេលខ្ញុំឃើញហ្នឹង គឺនៅក្នុងព្រៃបាទ។ នៅក្បែរព្រៃ។

**ស៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូហ្វូនបាទ។

**សួរដោយលោក សួន វិសាល៖**

**ស៖** សុំទោសបាទ។ តើនៅក្បែរព្រៃហ្នឹងមានឃើញ លោកមានឃើញមានអគា ឬក៏មានឃើញរបងអីដែលលោកអាចចំណាបានទេ?

**ឆ៖** បាទ ខ្ញុំអត់បានពិនិត្យ អត់បានអង្កេតមើលទេបាទ ព្រោះអីខ្ញុំខ្លាច។

**ស៖** ជនរងគ្រោះដែលលោកលើកឡើងថាឈ្មោះ ចាន់ ហ្នឹង តើនៅពេលនោះគាត់នៅក្នុង លើដីវាបស្មើ ឬក៏នៅកន្លែងជង្ហុកគេជីកគេអីហើយ ឬយ៉ាងម៉េច?

[១៤:០៧:៤៣]

**ឆ៖** បាទ ពេលខ្ញុំឃើញហ្នឹង គឺនៅកន្លែងគេជីករណ្ដៅមួយរាងវែង បណ្ដោយវែង ជម្រៅប្រហែលជា -- បើខ្ញុំប៉ាន់ទៅវាជ្រៅដែរ ប៉ុនមិនដឹងប៉ុន្មាន។

**ស៖** ចុះឈ្មោះដែលលោក ឃើញហ្នឹងគាត់ធ្វើសកម្មភាពយ៉ាងម៉េចដែរ? ទៅដល់លោកឃើញភ្លាម ឬក៏គេស្រែកហៅមុន?

**ឆ៖** បាទពេលទៅដល់គេស្រែកប្រាប់ខ្ញុំអីចឹងបាទ។

**ស៖** លោកនៅ -- មុននឹងគេស្រែក លោកនៅចម្ងាយប៉ុន្មានពីជង្ហុកដែលគេ -- លោកៗបានបញ្ជាក់ថាគេកាយរណ្ដៅហ្នឹង តើចម្ងាយប៉ុន្មានម៉ែត្រ?

**ឆ៖** បាទព្រោះអី ខ្ញុំទៅដល់ហ្នឹង តាមភ្លឺស្រែអីចឹង គោរាស៊ី អីចឹងអាភ្លឺហ្នឹង គឺភ្លឺអាទំនប់កន្លែងគេជីករណ្ដៅហ្នឹងតែម្ដង ហើយខ្ញុំទៅទាញខ្សែ ទៅដេញគោចេញមក ទាញខ្សែដឹកវាមក ហើយអីចឹងបើខ្ញុំប៉ាន់ប្រមាណទៅ វាកាត់ដែរ ជិតដែរ បាទ។

**ស៖** ជនរងគ្រោះហ្នឹងដេកឬក៏អង្គុយ ឬក៏ធ្វើសកម្មភាពអ្វីនៅពេលដែលលោកឃើញនោះ?

**ឆ៖** ចុះ ខ្ញុំជម្រាបលោកប្រធាន បើគ្នារងគ្រោះហើយឲ្យគ្នានៅអង្គុយម៉េច សម័យហ្នឹងយើងគិត ជាអ្នករងគ្រោះវិញ--

**ស៖** លោកៗស្ដាប់សំណួរដូចលោកៗប្រធានអង្គជំនុំជំម្រះបានជម្រាបអ៊ីចឹង។ ដោយសារខ្ញុំចង់ -- បើយើងមានពេលវេលាមានកំណត់ អ៊ីចឹងខ្ញុំចង់ឲ្យឆ្លើយនូវអ្វីដែលខ្ញុំសួរបាទ។ សូមអរគុណ។

**ឆ៖** បាទ គឺវាដេកបាទ។

**លោក សួន វិសាល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយបាទ។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ សូមបន្តទៀត។ សូមអញ្ជើញក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន!

[១៤:១០:៥០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

បាទ លោកប្រធាន ដោយសារក្រុម នួន ជា មិនចោទសំណួរទេ។ ខ្ញុំសូមសួរតែម្ដង ហើយរយៈពេលខ្លីទេលោកប្រធាន បើសិនលោកប្រធានអនុញ្ញាត។ ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរបន្តិចបន្តួចទេដើម្បីសួរទៅលោក។

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតដើម្បីផ្ដល់ចម្លើយឯកសារ D22/2162 ជាចម្លើយរបស់ដើមបណ្ដឹរដ្ឋប្បវេណីរូបនេះលោកប្រធាន។ សូមផ្ដល់ឯកសារនេះទៅគាត់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៤:១១:៤១]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អរគុណ។ ខ្ញុំសូមធ្វើការអត្ថាធិប្បាយមួយទៅលើទំព័រ ERN ជាភាសាអង់គ្លេសគឺ 0010 47833, ជាភាសាខ្មែរគឺ 00546439 ហើយគួរឲ្យសោកស្ដាយដែរជាភាសាបារាំងនោះមិនមានទេលោកប្រធានជាភាសាបារាំង។ អ៊ីចឹងដោយសារខ្ញុំសួរតែទាក់ទងនឹងឈ្មោះទេ អ៊ីចឹងដូចមិនមានបញ្ហា

អីចោទទេ។ លោកដើមបណ្តឹងរដ្ឋប្បវេណី លោកមានឯកសារហ្នឹងនៅចំពោះមុខលោកហើយឬនៅ?

**លោក វី ពៅ៖**

**ឆ៖** បាទ ខ្ញុំអត់មានផង។

**ស៖** បាទ មានឈ្មោះដែលខ្ញុំគូសជាពណ៌លឿននេះ គឺឈ្មោះ ថៅ នី ជាភាសាអង់គ្លេសគឺថា-- ឈ្មោះសាក្សីជាភាសាអង់គ្លេស។ អ៊ីចឹងខ្ញុំសួរលោកថាតើឈ្មោះ ថៅ នី ជាអ្នកណាដែរ? ហើយម៉េចក៏ឈ្មោះ ថៅ នី នេះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកទៅវិញ?

**ឆ៖** បាទ រាល់សមាសភាពដែលចុះទៅសាកសួរខ្ញុំ ខ្ញុំមិនដឹងគាត់នៅខាងណាខាងណាទេ ប៉ុន្តែគាត់ចុះទៅសួរស្រាវជ្រាវពីប្រវត្តិខ្មែរក្រហមហ្នឹង អ៊ីចឹងគាត់ទៅយកចម្លើយពីខ្ញុំ។ អ៊ីចឹងគាត់ក្រោយពី -- ទីលំនៅរបស់គាត់ ខ្ញុំមិនដឹងនៅឯណា។ ក្រោយពីពេលដឹងមក ដឹង ថៅ នី ៗ ប៉ុនមិនដឹងថាផ្ទះនៅឯណាផង។

[១៤:១៤:២៦]

**ស៖** លោកស្គាល់គាត់ អ៊ីចឹងៗ ខ្ញុំគួរយល់យ៉ាងម៉េចថាវាជាឈ្មោះ ដែលជាឈ្មោះអ្នកដែលមកសួរលោកនៅថ្ងៃហ្នឹងឬក៏យ៉ាងម៉េច? ខ្ញុំត្រូវយល់ថាអ៊ីចឹងឬក៏យ៉ាងម៉េចលោក? លោកស្គាល់គាត់ឬក៏ថាជាឈ្មោះអ្នកដែលមកសួរលោកថ្ងៃហ្នឹង?

**ប្រធានអង្គជំនុំ៖**

លោកកុំអាលទាន់ឆ្លើយៗ។

**លោក វី ពៅ៖**

**ឆ៖** បាទ នៅពេលនោះ ឈ្មោះ ថៅ នី គាត់បានទៅសួរខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងគាត់នៅកន្លែងណាទីណាដែរបាទ។

**ស៖** លោក ពេលលោកនិយាយថាដោយសារ ថៅ នី បានមកសំណេះសំណាលជាមួយលោកហ្នឹង គឺថាគាត់ហ្នឹងមកសន្ទនាជាមួយលោកនៅពេលដែលលោក -- ពេលដែលលោកឆ្លើយទៅសំណួរអ្នកដែលជួយបំពេញកំណត់ហេតុរបស់លោក កំណត់ហេតុសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកនោះ ក្នុងថ្ងៃតែមួយ ឬក៏ថ្ងៃផ្សេងទៀត ថ្ងៃក្រោយទេ?

**ឆ៖** បាទខ្ញុំឃើញទៅហ្នឹងមាន ថៅ នី ហើយនិងខ្ញុំ មិនដឹងសកម្មជនណាខ្លះទេ ខ្ញុំមិនសូវស្គាល់គេបាទ។ មិនដឹងមកពីណាខ្លះ ឃើញទៅបីបួននាក់។

**ស៖** បាទ ខ្ញុំត្រឡប់មកសំណួរមុនវិញ។ តើ ថៅ នី ជាអ្នកណា? ហើយលោកស្គាល់គាត់តាមរបៀបណាដែរ?

**ឆ៖** បាទ ថៅ នី ហ្នឹងខ្ញុំស្គាល់តាមរយៈនេះ គាត់ចុះទៅសួរនាំខ្ញុំរឿងពីរបបខ្មែរក្រហមហ្នឹង ទើបតែស្គាល់ពេលនុង់បាទ។

[១៤:១៦:៤០]

**ស៖** អ៊ីចឹង គឺថាបានន័យថាលោកមិនបាន -- មិនស្គាល់គាត់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យទេ។ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

សូមៗឆ្លើយដើមបណ្ដឹងរដ្ឋប្បវេណី។ អំមិញអត់ទាន់បានឆ្លើយទេ លោកឆ្លើយ អត់ទាន់ក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការ។

**លោក រី ពៅ៖**

**ឆ៖** បាទខ្ញុំទើបនឹងស្គាល់គាត់ពេលបច្ចុប្បន្នហ្នឹងបាទ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ពេលដែលលោកនិយាយថា លោកទើបស្គាល់គាត់នោះ គឺថា ខ្ញុំចង់ដឹងថាតើពេលស្គាល់ហ្នឹង ស្គាល់ពេលដែលគាត់មកជាមួយអ្នកដែលមកសួរសំណួរលោកឬក៏យ៉ាងម៉េច?

**ឆ៖** បាទគាត់មក ស្គាល់ពេលគាត់មកសួរសំណួរជាមួយខាងអង្គការចុះទៅជាមួយហ្នឹងបាទ។

**ស៖** អ៊ីចឹង សំណួរខ្ញុំចង់ដឹងថាតើហេតុអ្វីក៏ឈ្មោះគាត់ហ្នឹង – ឈ្មោះ ថៅ នី ហ្នឹងនៅៗកន្លែងដាក់ថាឈ្មោះសាក្សី? ហេតុអីក៏អ្នកផ្សេងទៀតដែលមានវត្តមានជាមួយគាត់ដែរហ្នឹង មិនមានសរសេរដាក់ក្នុងកន្លែងឈ្មោះសាក្សីហ្នឹងដែរ?

**ឆ៖** បាទខ្ញុំអត់ដឹងដែរអាហ្នឹង ការងាររបស់គាត់ខ្ញុំអត់ដឹងទេ ប៉ុន្តែថាពេលគាត់ចុះទៅហ្នឹង គាត់ក្រោយពីខាងក្រុមការងារចុះទៅសរសេរហើយ គាត់ធ្វើសាក្សីទៅ ប៉ុន្តែខ្ញុំអត់បានស្គាល់គាត់ទេពីមុនមក។

**ស៖** តើលោកនៅពេលដែលលោកបានសំណេះសំណាលជាមួយ ថៅ នី ហ្នឹងតើ ថៅ នី ហ្នឹង គាត់មានប្រាប់លោកថាគាត់នៅឯណាដែរឬទេ? ថាហេតុអីបានជាគាត់នៅក្នុងចំណោមអ្នកដែលសួរសំណួរលោកដែរនៅពេលនោះ?

**ឆ៖** បាទ ពេលនោះខ្ញុំឃើញគាត់ដើរជាមួយខាងអង្គការចុះទៅស៊ើបអង្កេតអារឿងសាលាក្ដី

ខ្មែរក្រហមហ្នឹង ឃើញគាត់ដើរជាមួយគ្នា ខ្ញុំមិន -- ស្មានថាគាត់ក្រុមងារខាងហ្នឹងដែរ ខ្ញុំអត់ដឹងថាគាត់នៅទីណាៗអត់ដឹង។

**ស៖** តើលោក ចៅ នី ហ្នឹងមានបានប្រាប់លោកទេថា គាត់ហ្នឹងធ្លាប់បានសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការយើងនេះដែរទេ? តើគាត់មានបានធ្លាប់និយាយប្រាប់លោកពីការណ៍ដែលគាត់ធ្លាប់បានផ្ដល់សក្ខីកម្មនៅទីនេះដែរឬទេ?

[១៤:១៩:៥៣]

**ឆ៖** បាទ រឿងរបស់គាត់ គាត់មិនដែលយកទៅនិយាយប្រាប់ខ្ញុំ ហើយគាត់ក៏មិនដែលបង្ហាញពីអាសយដ្ឋានថាគាត់នៅកន្លែងណាៗគាត់អត់ដែលបានប្រាប់ខ្ញុំឲ្យដឹងផង បាទ។

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេថា លោកសព្វថ្ងៃនេះនៅស្រុកគីរីវង់?

**ឆ៖** បាទ ជាការពិតបាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

បាទ ខ្ញុំសុំទាញចំណាប់អារម្មណ៍ភាគី ហើយនិងអង្គជំនុំជម្រះទៅលើឯកសារ។

បាទសូមអភ័យទោស សូមរង់ចាំមួយភ្លែត។

គឺឯកសារ E319.1.1, ERN គឺនៅទំព័រទី២ នៃឯកសារហ្នឹង។ ខ្ញុំសូមជម្រាបជូនផងដែរថាលោក ចៅ នី នេះបានផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/១ ក្រោមឈ្មោះសម្ងាត់ CCP-187។ ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អស់ហើយ! បាទ អរគុណអ៊ីចឹង ហើយសវនាការថ្ងៃនេះបានធ្វើឡើង ហើយបានចប់មុនពេលកំណត់។ អង្គជំនុំជម្រះមិនបាន មិនមានដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏សាក្សីបម្រុងទេនៅថ្ងៃនេះ។ ដូច្នេះសវនាការថ្ងៃនេះដល់ពេល -- អូ! លោកដើមបណ្ដឹងរដ្ឋប្បវេណីមានអ្វីចង់ថ្លែងរៀបរាប់ទេ អំពីទុក្ខសោកវេទនារបស់ និងព្យសនកម្មដែលលោកទទួលរង ហើយនិងមានសំណួរអ្វីចង់សួរចុងជាប់ចោទដែរឬទេ? បាទ សូមអញ្ជើញ!

**លោក វី ពៅ៖**

បាទ ខ្ញុំក៏គ្មានសំណួរអីវែងឆ្ងាយដែរ ប៉ុន្តែខ្ញុំចង់សួរដែលកាលពីសម័យនេះ ដូចលោក អ៊ំ ខៀវសំផន គាត់ថាគាត់ជាមេថ្នាក់ដឹកនាំប្រទេស។ អ៊ីចឹង ខ្ញុំចង់សួរថាកាលពីសម័យនោះ អ៊ំគាត់នៅទីណា

បានអត់ដឹងប្រជាពលរដ្ឋយើងរងទុក្ខវេទនាដល់ថ្នាក់អត់ឃ្លានសម្លាប់គ្នា ធ្វើទារុណកម្មចំពោះខ្មែរនឹងខ្មែរ បាទ? ខ្ញុំចង់ដឹងកន្លែងហ្នឹង។ តើគាត់អាចស្រាយបំភ្លឺបាន ជូនចំពោះ ជូនសម្រាប់ខ្ញុំ និងជនរួមជាតិទេបាទ?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះកត់សម្គាល់ថា នៅសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ជនជាប់ទាំងពីររូបនៅតែរក្សាជំហររបស់ខ្លួនក្នុងការបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានច្បាស់លាស់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្តីជនជាប់ចោទ។ ដូច្នេះជនជាប់ចោទ និងមេធាវីការពារក្តីហ្នឹងមានកាតព្វកិច្ចក្នុងការទទួលខុសត្រូវជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងអំពីការកែប្រែនេះ ប៉ុន្តែរហូតដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងអំពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទក្នុងការសម្រេចលះបង់សិទ្ធិនៅក្នុងការនៅស្ងៀមមិនឆ្លើយតប ទៅជាយល់ព្រមឆ្លើយតបនឹងសំណួររបស់ភាគីទេ។ ក្រៅពីនេះ តើលោក ចៅ នី មានចង់ធ្វើសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្ម ដែលកើតមានចំពោះលោកក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ?

**លោក វី ពៅ៖**

បាទ បើនិយាយអំពីការទុក្ខសោកក្នុងរបបប្រល័យពូជសាសន៍នោះ បើខ្ញុំនិយាយទៅខ្ញុំមិនចង់បានអ្វីដែលគួរឲ្យសម្រាប់ខ្លួនខ្ញុំទេ។ ប៉ុន្តែខ្ញុំចង់ថា ខ្ញុំសព្វថ្ងៃនេះវាមានវិប្បដិសារីដល់ម្តាយដល់ឪពុក ដល់ប្អូនរបស់ខ្ញុំ និងបងប្អូនដែលបានរងទុក្ខ ដែលពួកខ្មែរក្រហមធ្វើទារុណកម្មកាប់សម្លាប់សាហាវព្រៃផ្សៃដោយអំពើអយុត្តិធម៌ធ្វើប្រតិកម្មមកលើក្រុមគ្រួសាររបស់ខ្ញុំនេះ។ អ៊ីចឹងខ្ញុំគ្រាន់ថា អ្វីទាំងឡាយណាសូមឲ្យខាងអង្គការសហប្រជាជាតិ ព្រមទាំងតុលាការសាលាក្តីខ្មែរក្រហមហ្នឹងមេត្តាជួយធ្វើយ៉ាងណាកុំឲ្យមានអារបបឃោឃៅព្រៃផ្សៃអ៊ីចឹងវិលត្រឡប់មកបានទៀត ហើយក៏សំណូមពរឲ្យខាងផ្នែកតុលាការហ្នឹង ជួយធ្វើការវិនិច្ឆ័យ កាត់ទោសពួកមេខ្លោងរបស់ខ្មែរក្រហមហ្នឹងឲ្យសមៗនឹងកំហុសឆ្គងដែលខ្លួនបានប្រព្រឹត្តទៅលើប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេសដែលគាត់បានធ្វើទុក្ខបុកម្នេញដល់បងប្អូនខ្មែរយើងកន្លងមក។ បាទ អ៊ីចឹងសូមអរគុណហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក រី ពៅ។ សវនាការថ្ងៃនេះបានធ្វើឡើងចប់មុនពេលកាល មុនពេលកំណត់អង្គជំនុំជម្រះក៏មិនមានដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីបម្រុងដែរ។ សវនាការថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃទី ថ្ងៃច័ន្ទទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃច័ន្ទដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាមTCW-954 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមកាលវេលាបានកំណត់នេះ។ ហើយអង្គជំនុំជម្រះសូមអរគុណលោក រី ពៅ ដែលបានចំណាយពេលវេលាដែលមានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងរួមវិភាគទានក្នុងការស្វែងរកការពិតស្ថិតនៅក្នុងរឿងក្តីនេះ ហើយការផ្តល់សក្ខីកម្មរបស់លោកដល់ទីបញ្ចប់ហើយ វត្តមានរបស់លោកលែងមានភាពចាំបាច់ទៀតហើយនៅ អ.វ.ត.ក នេះលោកអាចវិលត្រឡប់ទៅកាន់ទៅលំនៅរបស់លោកវិញបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូប នួន ជា, ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនៅនេះវិញ នៅថ្ងៃច័ន្ទដើមសប្តាហ៍ក្រោយឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:២៧ នាទី)*